សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droitet des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កិច្ចគាំពារកុមារទាក់ទងនឹងពេស្យាកម្ម និងរូបភាពអាសអាភាសនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៥

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **លោក.គង់ សុវណ្ណដេត**

**លោក.រឿង សីហា**

សាស្ត្រាចារ្យណែនាំ

**លោក ជុំ ចាន់វិត្ថា**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១១

ឆ្នាំសរសេរសារណា ២០១៥

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **គង់ សុវណ្ណដេត** និង ខ្ញុំបាទឈ្មោះ **រឿង សីហា** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា២០១៤-២០១៥។

ខ្ញុំបាទទាំងពីររូបមានសេចក្ដីសោមនស្សរីករាយ ជាទីបំផុតដោយយើងខ្ញុំទាំងពីរនាក់បានមានឱកាសថ្លែងអំណរគុណដល់លោកឪពុក **គង់ សាផាត** អ្នកម្ដាយ **ភោគ សារឿន** និង លោកឪពុក **ឡាច សូម៉ាណាក់** អ្នកម្ដាយ **ជួន សុខុម** លោកទាំងបួនជាអ្នកដែលមានគុណធំធេងរកទីបំផុតគ្មានហើយដែលគ្មានថ្ងៃណាមួយដែលកូនអាចបំភ្លេចបាននោះទេ។

លោកបានផ្ដល់កំណើតដល់កូន និង ចិញ្ចឹមបីបាច់ថែរក្សាកូនយ៉ាងល្អ ប្រកបដោយព្រហ្មវិហារធម៌។ លើសពីនេះ លោកបានពុះពារឧបសគ្គគ្រប់បែបយ៉ាង ដើម្បីអនាគតកូន មិនថាយប់ ឬថ្ងៃទោះបីជាលោកឈឺថ្កាត់យ៉ាងណាក៏លោកមិនដែលរាថយឡើយ។

លោកបានផ្ដល់ក្ដីសង្ឃឹម ការស្រឡាញ់ថ្នាក់ថ្នម លើកទឹកចិត្ត ដល់កូនគ្រប់កាលៈទេសៈ ទោះបីពេលខ្លះកូនមានកំហុសឆ្គងក្ដី ក៏លោកមិនដែលស្ដីបន្ទោសផ្ទុយទៅវិញលោកបានលើកទឹកចិត្តកូនអោយខិតខំបន្ថែមទៀត។ជាពិសេសលោក បានបង្កឱកាសឲ្យយើងខ្ញុំជាកូនបានសិក្សាពីថ្នាក់មតេយ្យរហូតបានបញ្ចប់បរិញ្ញាបត្រ ដោយជោគជ័យដោយរួមមានការផ្គត់ផ្គង់ទាំងសម្ភារៈថវិកា និងស្មារតី។

យើងខ្ញុំទាំងពីរ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោកគ្រូ អ្នកគ្រូ** ដែលជាសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានខិតខំអស់កំលាំងកាយចិត្តក្នុងការផ្ទេរនូវចំណេះដឹងដល់និស្សិតគ្រប់រូប ពិសេសរូបយើងខ្ញុំទាំងពីររហូតដល់ចប់មហាវិទ្យាល័យនីតិសាស្ត្រនេះ។

ពិសេសខ្ញុំបាទក៏សូមថ្លែងអំណរគុណផងដែរ ចំពោះលោកសាស្ត្រាចារ្យ **ជុំ ចាន់វិត្ថា**ដែលលោកមិនត្រឹមតែបានបង្រៀន ខ្ញុំបាទក្នុងពេលកន្លងមកនោះទេ តែលោកថែមទាំងណែនាំសារណាបញ្ចប់ការសិក្សាលើចំណងជើងមួយនេះទៀត។ លោកបានផ្ដល់នូវដំបូន្មានល្អៗ នូវរបៀបក៏ដូចជាគន្លឹះ ស្វែងរកឯកសារ វិធីសាស្ត្រនិងការចងក្រងសារណា និងការកែលំអរឲ្យកាន់តែល្អថែមទៀត។

ជាចុងបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យ ដល់លោក អ្នកមានគុណទាំងបួន លោកឯកឧត្តមសាកលវិទ្យាធិការ វិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង និងលោកសាស្ត្រាចារ្យទាំងអស់ជួបតែសេចក្ដីសុខជានិរន្តរ៍តទៅ។

# អារម្ភកថា

បញ្ហាកុមារគឺជាបញ្ហាមួយដ៏ចំបងបំផុតសម្រាប់ប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសនានាក្នុងសកលលោក។ ក្នុងពេលបច្ចុប្បន្នបញ្ហាកុមារកាន់តែមានភាពស្រួចស្រាលឡើងដែលទាមទារអោយមានការយកចិត្តទុកដាក់ខ្ពស់ ពីសំណាក់រាជរដ្ឋាភិបាលនិងប្រជាជនទូទៅផងដែរ។ ដោយមើលឃើញពីបញ្ហាទាំងអស់នេះក្រុមយើងខ្ញុំ ពិតជាមានក្តីបារម្ភយ៉ាងខ្លាំងជាពិសេសពួកយើងធ្លាប់បានជជែកគ្នាពីវិធីដើម្បីរួមចំណែកដោះស្រាយបញ្ហាទាំងនេះម្យ៉ាងវិញទៀតដើម្បីទាក់ទាញចំណាប់អារម្មណ៍មហាជនអោយមើលពីបញ្ហាទាំងអស់នេះ។ដោយមានការផ្តល់ឱកាសពីសាកលវិទ្យាល័យដើម្បីធ្វើកិច្ចការស្រាវជ្រាវ យើងខ្ញុំពិតជាមានក្តីរីករាយយ៉ាងខ្លាំងហើយក៏បានសម្រេចចិត្តជ្រើសរើសប្រធានបទសារណាស្តីពី**កិច្ចគាំពារកុមារទាក់ទងនឹងពេស្យាកម្ម និងរូបភាពអាសអាភាសកុមារនៅកម្ពុជា**។ កុមារគ្រប់ប្រភេទសុទ្ធតែត្រូវបានទទួលការការពារពីរដ្ឋដែលខ្លួនកំពុងរស់នៅពីការប្រព្រឹត្តអំពើមិនគប្បីមកលើខ្លួនដូចជាការរំលោភបំពានផ្លូវភេទ ពេស្យាកម្ម ការកេងប្រវ័ញ្ចពលកម្ម និងរូបភាពអាសអាភាសជាដើម។

ការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំមានគោលដៅចង់បង្ហាញពីមូលហេតុដែលនាំឲ្យកើតមានបញ្ហាពេស្យាកម្ម និងរូបភាពអាសភាសលើកុមារ ជាពិសេសបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងដោះស្រាយ ទប់ស្កាត់ និងបង្ការបញ្ហានេះ។ ម្យ៉ាងវិញទៀតយើងក៏ចង់បង្ហាញពីការផ្តល់ជាអនុសាសន៍នានាដោយ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិនិងបណ្តាប្រទេសដែលជាសមាជិកអង្គការមួយនេះផងដែរ។

ការលើកយកប្រធានបទនេះឡើង គឺពឹងផ្អែកលើចំនេះដឹងផ្ទាល់ខ្លួន បូករួម ឯកសារជាមូលដ្ឋានដទៃទៀតជាច្រើនដែលត្រូវបានរៀបរៀងដោយស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ រួមទាំងអនុសាសន៍របស់អង្គការសហប្រជាជាតិផងដែរ ដើម្បីជាការបំភ្លឺដល់កិច្ចការស្រាវជ្រាវរបស់យើងខ្ញុំ។

ក្នុងនាមយើងខ្ញុំជាអ្នកចងក្រងឯកសារនេះ សូមអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយណាដែល កើតឡើងដោយអចេតនា ទាំងអក្ខរាវិរុទ្ធក្តី ទាំងការប្រើពាក្យពេជន៍ខ្លឹមសារក្តី ឬ អត្ថន័យក្នុងអត្ថបទក្តី ។ យើងខ្ញុំដឹងថា ទោះបីជាមានការផ្ទឹតផ្ទង់ ផ្ទៀងផ្ទាត់ជាច្រើនដង ឬយកចិត្តទុកដាក់ក្តីតែកំហុស បន្តិចបន្តួចនោះនូវតែកើតមានជាអចេតនាជៀសមិនផុតឡើយ អាស្រ័យហេតុ នេះសូមលោកទាំង អស់មេត្តាអធ្យាស្រ័យ និងជួយកែតំរូវផងដើម្បីឲ្យស្នាដៃមួយនេះបានល្អប្រសើរជាងនេះហើយក៏សំរាប់ ទុកជាបទពិសោធន៍ទៅថ្ងៃក្រោយ។ ជាចុងក្រោយ យើងខ្ញុំមានតែពាក្យជូនពរដល់លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ប្រិយមិត្តអ្នកអាន មិត្តនិស្សិត អ្នកស្រាវជ្រាវ ដែលបានចំណាយពេលវេលា ដែលមានតំលៃយកចិត្តទុកដាក់លើប្រធានបទមួយនេះ និង សូមជូនពរនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**..........................................................................................................០១

## ជំពូកទី១
## ទិដ្ឋភាពទូទៅនៃការធ្វើពេស្យាកម្ម និង
## រូបភាពរំលោភបំពានលើកុមារ

**ផ្នែកទី១ ពេស្យាកម្មលើកុមារ**.........................................................................០២
និយមន័យ ១.១ ..........................................................................................០២
១រូបភាពនៃការធ្វើពេស្យាកម្ម ២...................................................................០២
១.២.១ រូបភាពនៃការធ្វើពេស្យាកម្មដោយផ្ទាល់....................................០៣
១.២.២ រូបភាពនៃការធ្វើពេស្យាកម្មដោយប្រយោល.............................០៣
១មូលហេតុនាំឲ្យមានការធ្វើពេស្យាកម្ម ៣. ....................................................០៤
១.៣.១ វិបត្តិគ្រួសារ ..........................................................................០៤
១.៣.២ វិបត្តិស្នេហា ..........................................................................០៥
១.៣.៣ ដោយស្ម័គ្រចិត្ត ......................................................................០៥
១.៣.៤ តាមរយៈឪពុកម្តាយ ................................................................០៥
១.៣.៥ សន្យារកការងារឲ្យធ្វើ ...........................................................០៦
១.៣.៦ ការសុំមកធ្វើជាកូនចិញ្ចឹម......................................................០៦
១.៣.៧ តាមរយៈមិត្តភក្តិ.....................................................................០៦
១.៣.៨ ការប្រើប្រាស់គ្រឿងញៀន និងថ្នាំសណ្តំ .................................០៦
១.៣.៩ កង្វះខាតនៃការអប់រំ ...............................................................០៧
១.៣.១០ ភាពធូររលុងនៃការអនុវត្តច្បាប់ ដោយមន្ត្រីអនុវត្តច្បាប់..........០៧
ទិន្នន័យស្តីពីបញ្ហាការធ្វើពេស្យាកម្មលើកុមារ ៤.១ ........................................០៨
**ផ្នែកទី២ រូបភាពអាសអាភាសលើកុមារ** ...........................................................១១
២.១ និយមន័យ ...........................................................................................១១
២.២ រូបភាពអាសអាភាសលើកុមារ ..............................................................១២
២.៣ មូលហេតុដែលនាំឲ្យមានរូបភាពអាសអាភាសលើកុមារ.........................១២
២.៣.១ កំណើននៃទេសចរណ៍ផ្លូវភេទ .................................................១២

២.៣.២ ភាពរីកចម្រើននៃបច្ចេកវិទ្យា ............................................... ១២
២.៣.៣ ចំណង់ផ្លូវភេទហួសព្រំដែន ............................................... ១៣
២.៤ ទិន្នន័យស្តីពីបញ្ហារូបភាពអាសអាភាសលើកុមារ ............................................... ១៣

## ជំពូកទី២

## អនុសាសន៍របស់អង្គការសហប្រជាជាតិ
## លើបញ្ហាពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារ

ផ្នែកទី១ អនុសាសន៍លើបញ្ហាការធ្វើពេស្យាកម្មលើកុមារ ............................................... ១៤
១ការអប់រំផ្សព្វផ្សាយ ១. ............................................... ១៤
១ការពង្រឹងផ្នែកច្បាប់ ២. ............................................... ១៥
១ ការរៀបចំគោលនយោបាយជាតិ ៣. ............................................... ១៦
ផ្នែកទី២អនុសាសន៍លើបញ្ហារូបភាពអាសអាភាសលើកុមារ ............................................... ១៦
២ការអប់រំផ្សព្វផ្សាយ ១. ............................................... ១៦
២ការពង្រឹងផ្នែកច្បាប់ ២. ............................................... ១៧
២ការរៀបចំគោលនយោបាយជាតិ ៣. ............................................... ១៧

## ជំពូកទី៣

## កិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហា
## ពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារ

ផ្នែកទី១ ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ............................................... ១៨
១ ១.លើការអប់រំផ្សព្វផ្សាយ ............................................... ១៨
១ការអន្តរាគមន៍ ២. ............................................... ២០
១ការរៀបចំលិខិតបទដ្ឋានជាតិ ៣. ............................................... ២១
ផ្នែកទី២ ការខិតខំប្រឹងប្រែង របស់អង្គការមិនមែនរដ្ឋាភិបាល ............................................... ២៤
ការចូលរួមចំណែកក្នុងការអប់រំផ្សព្វផ្សាយ ១.២ ............................................... ២៥
២ការចូលរួមចំណែកក្នុងការអន្តរាគមន៍ ២. ............................................... ២៥
២ ៣.ការចូលរួមចំណែកក្នុងការរៀបចំបទដ្ឋានជាតិ ............................................... ២៦

## ជំពូកទី៤

**លិខិតបទដ្ឋានគតិយុត្ត**

ផ្នែកទី១ លិខិតុបករណ៍អន្តរជាតិ........................................................................២៧

១.១ អនុសញ្ញា........................................................................................២៧

១.២ ពិធីសារបន្ថែម..................................................................................៣២

ផ្នែកទី២ បរិបទច្បាប់ជាតិ.....................................................................................៣៧

២.១ ច្បាប់ជាតិ.........................................................................................៣៧

២.២ លិខិតបទដ្ឋាននានា..........................................................................៥១

**សេចក្តីសន្និដ្ឋាន**......................................................................................៥៧

**អនុសាសន៍**...............................................................................................៥៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

សង្គ្រាមក្នុងប្រទេស ដែលអូសបន្លាយជាងម្ភៃឆ្នាំកន្លងមកនេះបានបន្សល់ទុកកុមារយ៉ាងច្រើនដោយកុមារទាំងនោះភាគច្រើនត្រូវរស់នៅដោយឯកកោ ព្រោះថាគ្មានឪពុកម្តាយបីបាច់ថែរក្សា។ ក្នុងខណៈពេលនោះ ប្រទេសជាតិត្រូវស្ថិតក្នុងកម្រិតមួយដែលត្រូវការស្តារ និងអភិវឌ្ឍន៍គ្រប់វិស័យជាបន្ទាន់ កុមារគ្រប់រូបត្រូវបានខិតខំប្រឹងប្រែងស្វះស្វែងដើម្បីចិញ្ចឹមជីវិត។ រហូតដល់ពេលបច្ចុប្បន្នសង្គមជាតិនៅតែប្រឈមមុខនឹង បញ្ហាចំបងៗជាច្រើនដែលក្នុងនោះបញ្ហាពេស្យាកម្ម និងរូបភាអាសអាភាសលើកុមារក៏ ជាបញ្ហាមួយក្នុងចំណោមបញ្ហាចំបងផងដែរហើយចេះតែកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ក្នុងឆ្នាំ១៩៩២កម្ពុជា បានក្លាយជារដ្ឋភាគីនៃអនុសញ្ញា ស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមពាក់ព័ន្ធនឹង សិទ្ធិកុមារស្តីពីការជួញដូរកុមារ ពេស្យាកម្មកុមារនិងរូបភាពឬសម្ភារៈអាសអាភាសកុមារក្នុងឆ្នាំ២០០២។ ការអនុវត្តគោលនយោបាយដ៏ត្រឹមត្រូវ របស់រាជរដ្ឋាភិបាលសហការជាមួយដៃគូអភិវឌ្ឍ អង្គការមិនមែនរាជរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្នុងការលើកស្ទួយកុមារ និងចាត់គ្រប់វិធានការសំដៅលើកកម្ពស់ផ្នែកសុខុមាលភាពកុមារជាពិសេសលុបបំបាត់ទម្រង់នៃការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។ ក្នុងការស្រាវជ្រាវនេះផងដែរយើងលើកទឹកចិត្តឲ្យមានការបង្កើនការយកចិត្តទុកដាក់ខាងផ្នែកសុខុមាលភាព និងស្វែងរកយុត្តិធម៌ឲ្យកុមាររងរណីកុមារបានក្លាយជាជនរងគ្រោះ នៃការកេងប្រវ័ញ្ចផ្លូវភេទពិសេសគឺបង្ការកុមារពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។

ក្នុងពេលអនាគតកុមារនឹងក្លាយជាយុវជន ដែលជាកម្លាំងចលករក្នុងការអភិវឌ្ឍប្រទេសជាតិហេតុនេះហើយយើងត្រូវតែ មានការការពារជាពិសេសចំពោះធនធានដ៏កម្រនេះ។ ហេតុនេះការស្វែងរកវិធានការការពារ ទប់ស្កាត់ការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារនៅកម្ពុជាជាការសំខាន់យើងនឹងសិក្សាទៅលើជំពូកទី១(ទិដ្ឋភាពទូទៅស្តីពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស) ជំពូកទី២ (អនុសាសន៍របស់បណ្តាប្រទេសជាសមាជិកអង្គការសហប្រជាជាតិលើបញ្ហាពេស្យាកម្មកុមារ និងរូបភាសអាភាសលើកុមារ) ជំពូកទី៣(កិច្ចខិតខំប្រឹងប្រែងនិងក្នុងការដោះស្រាយបញ្ហាការធ្វើពេស្យាកម្មនិងរូបភាពអាសអាភាស) និងជំពូកទី៤(លិខិតបទដ្ឋានគតិយុត្ត)។ តាមការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើគោលបំណងចំបងនោះគឺដើម្បីឲ្យសង្គមកម្ពុជាធ្វើការការពារកុមារ ពីផលប៉ះពាល់នៃការប្រើប្រាស់កុមារក្នុងការធ្វើពេស្យាកម្មនិងការប្រើប្រាស់កុមារ ក្នុងការសម្តែងអំពើអាសអាភាសនិងការផលិតសម្ភារៈ ឬ រូបភាពអាសអាភាសពិសេសគឺការការពារផ្នែកសុខុមាលភាពផ្លូវភេទកុមារ។

# ជំពូកទី១ ទិដ្ឋភាពទូទៅនៃ ការធ្វើពេស្យាកម្ម និង រូបភាពអាសអាភាសលើកុមារ

## ផ្នែកទី១ ពេស្យាកម្មលើកុមារ

បញ្ហាពេស្យាកម្មលើកុមារ ជាបញ្ហាដ៏ស្រួចស្រាវមួយសម្រាប់ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសផ្សេងៗទៀតក្នុងពិភពលោក ។ ដោយសារតែក្រុមកុមារគឺជាមនុស្សទន់ខ្សោយ ដូច្នេះក្រុមមនុស្សប្រភេទនេះងាយទទួលរងនូវការរំលោភបំពានផ្សេងៗ ជាពិសេស គឺពេស្យាកម្មនេះតែម្តង ។

### ១.១ និយមន័យ

តាមរយៈពិធីសារបន្ថែម នៃអនុសញ្ញអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារពេស្យាកម្មកុមារ និង រូបភាព ឬ សម្ភារៈអាសអាកុមារ ដែលបានចូលជាធរមាននៅថ្ងៃទី១៨ ខែមករាឆ្នាំ២០០២ បានឲ្យនិយមន័យថា៖

"ពេស្យាកម្មកុមារ"គឺ ជាការប្រើប្រាស់កុមារក្នុងសកម្មភាពផ្លូវភេទបំណងយកកម្រៃ ឬ អត្ថប្រយោជន៍តាមទម្រង់ផ្សេងៗ ។[1]

ក្នុងន័យនេះកុមារត្រូវបានក្លាយជាកម្មវត្ថុ ដែលអាចប្រៀបធៀបទៅនឹងទំនិញ ដែលកុមារគឺត្រូវលក់អោយបំរើផ្លូវភេទ ពាក្យកុមារក្នុងន័យនេះគឺមិនសំដៅលើតែកុមារីតែប៉ុណ្ណោះទេដែលក្នុងនោះកុមារាក៏ត្រូវបានរាប់បញ្ចូលផងដែរ ។

បើអនុលោមទៅតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ ត្រង់មាត្រា២៣ បានប្បញ្ញត្តិន័យមួយផ្សេងទៀតថា៖

"អំពើពេស្យាចារកុមារ" គឺជាអំពើរួមភេទ ឬ អំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទរវាងអនីតិជនជាមួយជនដទៃ ដើម្បីផ្តោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ ។[2]

ក្នុងន័យនេះកុមារត្រូវបានក្លាយជាកម្មវត្ថុមួយ ដែលត្រូវទទួលរងការរំលោភបំពានពីសំណាក់ជនដទៃផ្សេងទៀតតាមរយៈការយកទៅរួមភេទដោយផ្ទាល់ ឬ តាមរយៈសកម្មភាពផ្សេងទៀតដែលវាទាក់ទងភេទរវាងកុមារ ដែលជាអនីតិជនជាមួយជនដទៃទៀត។ គួរកត់សម្គាល់ផងដែរជនដទៃត្រង់ន័យនេះគឺជនានុជនទាំងអស់ដោយមិនបានកំណត់អំពីឋានៈរបស់ពួកគេនោះឡើយ ដោយវាអាចជាអនីតិជនដែលជាកុមារដូចគ្នា អាចជានីតិជន អាចជាឪពុកម្តាយ អាណាព្យាបាល ចង្កោមញាតិរបស់អនីតិជនដែលទទួលរងគ្រោះនៃពេស្យាកម្មនោះ ហើយជាពិសេសវាច្រើនជាសកម្មភាពដែលស្តែងចេញពីអ្នកប្រកបរបរលើអាជីវកម្មផ្លូវភេទ។

### ១.២ រូបភាពនៃការធ្វើពេស្យាកម្ម

[1]មាត្រា២ ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារឆ្នាំ២០០២

[2]មាត្រា២៣នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨

រូបភាពនៃការធ្វើពេស្យាកម្មលើកុមារមានពីរគឺ ដោយរូបភាពនៃការធ្វើពេស្យាកម្មលើកុមារដោយផ្ទាល់និងរូបភាពនៃការធ្វើពេស្យាកម្មលើកុមារដោយប្រយោល ។ គួរកត់សម្គាល់ផងដែរតាមរយៈរូបភាពនៃការធ្វើពេស្យាកម្មទាំងពីររូបភាពនេះគឺមានលក្ខណៈខុសគ្នាមួយចំនួនដូចតទៅ៖

### ១.២.១ រូបភាពនៃការធ្វើពេស្យាកម្មដោយផ្ទាល់

តាមរយៈការធ្វើពេស្យាកម្មដោយផ្ទាល់នេះគឺ មានភាគីពីរនៅក្នុងដំណើរការនេះគឺភាគីម្ខាងជាអ្នកប្រព្រឹត្តពេស្យាចារ និងភាគីម្ខាងទៀតជាអ្នករងគ្រោះដោយពេស្យាកម្មដែលជាកុមារ ហើយក៏ទទួលបានវត្ថុដែលមានតម្លៃអ្វីមួយ ពីអ្នកប្រព្រឹត្តអំពើពេស្យាចារនោះ។ មួយទៀតសោតតាមរយៈរូបភាពនៃការធ្វើពេស្យាកម្មដោយផ្ទាល់ មានរូបភាពមួយដែលបានកំណត់ជាក់លាក់នៅក្នុងមាត្រា ៣ ចំណុចខ នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និង រូបភាព ឬ សម្ភារៈអាសអាភាសកុមារដែលបានបញ្ញត្តិ″ ការឲ្យ ការទទួល ការផ្គត់ផ្គង់កុមារសម្រាប់ពេស្យាកម្មកុមារ″ ។ នៅក្នុងបញ្ញត្តិនៃមាត្រានេះគឺចង់សំដៅថាបុគ្គលដទៃទៀតអាចជាឪពុកម្តាយ អ្នកអាណាព្យាបាលបានឲ្យ ឬ ប្រគល់កុមារទៅ អ្នកប្រព្រឹត្តពេស្យាកម្ម ហើយអ្នកដែលប្រព្រឹត្តពេស្យាកម្មនោះ អាចទទួលយកកុមារនោះដើម្បីធ្វើជាសកម្មភាព និង ធ្វើការផ្គត់ផ្គង់កុមារនោះតាមការសន្យាថានឹង មានកម្មវត្ថុជាតម្លៃតបស្នង ដែលវាផ្តល់ប្រយោជន៍ដល់កុមារនោះ។ បើតាមច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ របស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ ចាប់ពីមាត្រា៣៤ ដល់មាត្រា៣៦ ក៏បានកំណត់ផងដែរអំពីរូបភាពនៃការធ្វើពេស្យាកម្មដោយផ្ទាល់ដែលមានដូចជា៖

-ការរួមភេទ ឬ ការធ្វើអំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទ ជាមួយអនីតិជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ដោយផ្តល់ ឬ សន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយ ឲ្យទៅអនីតិជននោះ ឬ ទៅឲ្យអន្តរការី ឪពុកម្តាយ អ្នកអាណាព្យាបាល ឬជនដទៃទៀតដែលគ្រប់គ្រង ឬ ត្រួតពិនិត្យអនីតិជននោះ ។

-ឲ្យជនដទៃខ្ចីប្រាក់ រួមបញ្ចូលទាំងឲ្យកុមារខ្ចីប្រាក់ផងដែរ ឬ វត្ថុមានតម្លៃអ្វីមួយដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឲ្យកុមារប្រកបរបរពេស្យាចារ ។

### ១.២.២ រូបភាពនៃការធ្វើពេស្យាកម្មដោយប្រយោល

តាមរយៈការធ្វើពេស្យាកម្មដោយប្រយោល ក៏មិនសូវខុសគ្នាឆ្ងាយប៉ុន្មាននោះទេពីការធ្វើពេស្យាកម្មដោយផ្ទាល់ ដោយការធ្វើពេស្យាកម្មដោយប្រយោល គឺមានការចូលរួមពីអន្តរការី ឬ សញ្ចារជនដើម្បីឲ្យសកម្មភាពនៃការធ្វើពេស្យាកម្មបានសម្រេច។ ហេតុនេះបើយោងទៅលើមាត្រា៣ ចំណុច″ខ″នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យា

កម្មកុមារ និង រូបភាពឬសម្ភារៈអាសអាភាសកុមារ ដដែលយើងសង្កេតឃើញមានពាក្យការធ្វើសញ្ចារកម្ម។ ហេតុនេះការធ្វើពេស្យាកម្មដោយប្រយោលពិតជាមានការចូលរួមពីតតិយជន ដែលជាសញ្ចារជន ហើយផលប្រយោជន៍គឺពុំបានទៅលើកុមារដូចជារូបភាពនៃការធ្វើពេស្យាកម្មដោយផ្ទាល់នោះទេតែវាបែរជាបានទៅសញ្ចារជនដែលជាអ្នកសម្រួល ក្នុងការដែលឲ្យសកម្មភាពនៃអំពើពេស្យាកម្មមួយបានសម្រេចទៅវិញ ។

បើអនុលោមតាមមាត្រា៣៥ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិង អំពើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ របស់ព្រះរាជាណាចក្រកម្ពុជា បានប្បញ្ញត្តិថា"ការអូសទាញជនដទៃសម្រាប់អំពើពេស្យាចារកុមារ ឬផ្សាយពាណិជ្ជកម្មនូវអំពើពេស្យាចារកម្ពុជាក្នុងគោលដៅធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារ។" តាមរយៈមាត្រានៃច្បាប់មួយនេះ បានបញ្ជាក់ថាការធ្វើពេស្យាកម្មទៅលើកុមារដោយប្រយោលពិតជាមានការចូលរួមពីអន្តរការី ឬសញ្ចារជន ហើយក្នុងច្បាប់ដដែលនេះត្រង់មាត្រា២៥ បានកំណត់យ៉ាងជាក់លាក់ពីសកម្មភាពដោយប្រយោលរបស់សញ្ចារជនមានដូចជា៖

-ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ

-ជួញ ឬ ការពារអំពើពេស្យាចាររបស់ជនដទៃ

-ជ្រើសរើស អូសទាញ ឬបណ្តុះបណ្តាលបុគ្គលណាមួយឲ្យធ្វើពេស្យាចារ

-ធ្វើការគាបសង្កត់លើបុគ្គលណាមួយដើម្បីឲ្យបុគ្គលនោះធ្វើពេស្យាចារ

-អំពើធ្វើជាអន្តរការីរវាងបុគ្គលដែលធ្វើពេស្យាចារនិងបុគ្គលដែលប្រកបអាជីវកម្ម ឬឲ្យលាភការដល់ពេស្យាចារជនដទៃ។

## ១.៣ មូលហេតុនាំឲ្យមានការធ្វើពេស្យាកម្ម

ការធ្វើពេស្យាកម្ម កើតឡើងដោយមានមូលហេតុជាច្រើន រួមមានដូចជា៖

### ១.៣.១ វិបត្តិគ្រួសារ

ជាការពិតជាក់ស្តែងគ្រប់មនុស្សទាំងអស់ តែងតែប្រាថ្នាចង់បានកម្រិតជីវភាពគ្រួសារមួយដែល ល្អប្រពៃ ហើយក៏មិនចង់រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រនោះទេ។ ប៉ុន្តែភាពក្រីក្រនូវតែដឹកនាំជីវភាពជាប្រចាំថ្ងៃរបស់មនុស្សទាំងអស់នោះ ដោយក្នុងនោះវាអាចធ្វើឲ្យមនុស្សទាំងអស់នោះឈានទៅដល់ការប្រព្រឹត្តអំពើទាំងឡាយ ដែលសង្គមតែងតែទទួលយកមិនបាន ទោះបីជាការប្រព្រឹត្តដោយស្ម័គ្រចិត្ត ឬមិនដោយការស្ម័គ្រចិត្តក្តី ។ តួយ៉ាងរដ្ឋជាភាគីនៅក្នុងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាចារកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសកុមារបានសម្តែងកង្វល់ថា ភាពរីកចំរើននៃអំពើពេស្យាចារកុមារ គឺបណ្តាមកពីភាពក្រីក្រពិសេសក្នុងនោះកម្ពុជាក៏បានសម្តែងកង្វល់យ៉ាងដូច្នេះដែរ ។ ដោយសារកត្តានេះហើយ បាន

ជារដ្ឋជាភាគីនៃពិធីសារនេះដោយរួមទាំងកម្ពុជាផងដែរ ជឿជាក់ថា នឹង លុបបំបាត់ភាពក្រីក្រ ឬ គម្លាតសេដ្ឋកិច្ចរវាងគ្រួសារ និងសង្គម ក៏ដូចជាបានចូលរួមលុបបំបាត់ពេស្យាកម្មលើកុមារផងដែរ។

ហេតុផលដែលវិបត្តិគ្រួសារ ជាកត្តានាំឲ្យមានអំពើពេស្យាកម្មលើកុមារ គឺមកពីមានការចូលរួមដោយកុមារផ្ទាល់តាមការស្ម័គ្រចិត្តរបស់ពួកគេ ពីព្រោះថាកុមារទាំងនោះមិនអាចប្រឈមចំពោះជីវភាពគ្រួសាររបស់ខ្លួន។ មួយវិញទៀតវាអាចនឹងកើតឡើងបានតាមរយៈ ឪពុកម្តាយដែលជាអ្នកយកកូនរបស់ខ្លួនដែលជាកុមារ ទៅធ្វើជាកម្មវត្ថុនៃពេស្យាកម្មដើម្បីទទួលបានកម្រៃ ។ លើសពីនេះវិបត្តិគ្រួសារ ដែលជាមូលហេតុនាំឲ្យកើតមានពេស្យាកម្មផងដែរ ការនេះមិនផ្អែកតែទៅលើស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារប៉ុណ្ណោះទេ តែវាក៏អាចមកពីវិបត្តិមួយចំនួនទៀត ក្នុងគ្រួសារ ដូចជាការប្រើប្រាស់អំពើហិង្សារវាងឪពុកនិងម្តាយ ការប្រើប្រាស់គ្រឿងស្រវឹង ជម្លោះ នៅក្នុងគ្រួសារ ក៏ជាប្រភពនាំឲ្យមានពេស្យាកម្មផងដែរ ។ ដោយហេតុថាកុមារដែលជាកូន មិនអាចទ្រាំទ្ររស់នៅបាននៅក្នុងគ្រួសារ ជាហេតុនាំឲ្យគេសម្រេចចាកចេញពីផ្ទះ ហើយដោះស្រាយជីវភាពរបស់ខ្លួនដោយខ្លួនឯង នោះហើយដែរជាហេតុនាំឲ្យកើតមានពេស្យាកម្ម ។

**១.៣.២ វិបត្តិស្នេហា**

ដោយសារតែសង្គមមានការវិវត្តន៍យ៉ាងឆាប់រហ័ស កុមារក្នុងសម័យបច្ចុប្បន្នងាយនឹងទទួលយកនូវវប្បធម៌បែបថ្មី ដែលក្នុងនោះយើងសង្កេតឃើញថាកុមារខ្លះមានមិត្តប្រុស ឬ មិត្តស្រីតាំងពីនៅបឋមសិក្សាដែលមូលហេតុនេះ ធ្វើអោយពួកគេងាយនឹងប្រឈមមុខក្នុងការរួមភេទ ។ ដោយសារតែពួកគេនៅវ័យក្មេងស្នេហារបស់ពួកគេមិនមានភាពយូរអង្វែងនោះទេ។ ក្រោយពេលបែកបាក់ស្នេហា កុមារភាគច្រើនបានក្លាយជាកម្មវត្ថុនៃអំពើពេស្យាកម្មក៏មាន ។

**១.៣.៣ ដោយស្ម័គ្រចិត្ត**

ពេស្យាកម្មលើកុមារកើតឡើង ក៏ដោយសារតែការស្ម័គ្រចិត្ត របស់កុមារនោះដោយខ្លួនឯង។ ពេលខ្លះគ្មាននរណាម្នាក់ ជំរុញកុមារនោះឲ្យធ្លាក់ ទៅក្នុងការប្រព្រឹត្តពេស្យាកម្មនោះទេតែវាជាការសម្រេចចិត្តដោយផ្ទាល់របស់កុមារនោះ ដើម្បីយល់ព្រមធ្វើជាកម្មវត្ថុនៃពេស្យាកម្មដោយរំពឹងថានឹងទទួលបានកម្រៃតបស្នង តាមរយៈការស្ម័គ្រចិត្តនោះ ។

**១.៣.៤ តាមរយៈឪពុកម្តាយ**

ជាការពិតណាស់ពេស្យាកម្មមួយ កើតឡើងមិនមែន វាកើតឡើងដោយសារតែការសម្រេចចិត្តរបស់កុមារតែមួយនោះទេគឺវាក៏មានការចូលរួមពីភាគីដទៃទៀត ពិសេសគឺមានការចូលរួមដោយឪពុកម្តាយដែលជាហេតុនាំឲ្យពេស្យាកម្មកើតឡើង ។ តាមរយៈឪពុកម្តាយវាអាចស្តែងឡើងតាមរយៈរូបភាពច្រើន ។ តាមរយៈរូបភាពទាំងអស់វា អាចជាការជំរុញឲ្យកូនដែលមានវ័យក្មេងទៅ

ឲ្យជនដទៃដើម្បីក្លាយទៅជាកម្មវត្ថុនៃពេស្យាកម្ម ។ មួយវិញទៀតវាអាចតាមរយៈការប្រើប្រាស់អំពើហិង្សា និងការគំរាមកំហែងជាដើម ។

**១.៣.៥ សន្យារកការងារឲ្យធ្វើ**

តាមរយៈការសន្យារកការងារឲ្យធ្វើ ក៏ត្រូវបានយកមកធ្វើជាមូលហេតុនៃពេស្យាកម្មដែរដោយព្រោះថាពេលខ្លះកុមារងាយស្រួលក្នុងការដែលត្រូវគេបោកប្រាស់ ។ ហេតុនេះដោយសារតែកុមារងាយស្រួលត្រូវគេបោកប្រាស់ ទើបបានជាអ្នកប្រព្រឹត្តពេស្យាកម្ម មួយចំនួនយកហេតុផលការរកការងារឲ្យធ្វើជាតម្លៃតបស្នង ឲ្យតែកុមារទាំងអស់នោះយល់ព្រមធ្វើជាកម្មវត្ថុនៃពេស្យាកម្ម ។

**១.៣.៦ ការសុំមកធ្វើជាកូនចិញ្ចឹម**

ជាការពិតការសុំកូនអ្នកដទៃមកធ្វើជាកូនខ្លួនឯង ដែលនាំឲ្យមានទំនាក់ទំនងគតិយុត្តរវាងគ្នាទៅវិញទៅមកនោះក៏ជាកត្តាមួយដែលនាំឲ្យមានពេស្យាកម្មផងដែរ ។ ហេតុនេះបានជាយើងលើកយកចំណុចមួយនេះមកធ្វើជាមូលហេតុ ដោយព្រោះថា ពេលខ្លះការសុំកូនអ្នកដទៃមកចិញ្ចឹមដោយឲ្យមានទំនាក់ទំនងគតិយុត្តគ្រាន់តែជារូបភាពមួយផ្សេងប៉ុណ្ណោះ តែបំណងវិស័យរបស់អ្នកសុំនោះពេលខ្លះគឺដើម្បីយកកូន ដែលជាកុមារនោះទៅធ្វើអ្វីមួយផ្សេង ដោយអាចយកទៅធ្វើជាកម្មវត្ថុនៃពេស្យាកម្មដើម្បីទទួលបានលាភការផ្សេងៗ ។

ដោយសារតែហេតុផលនេះទើបព្រះរាជាណាចក្រកម្ពុជាយើងបានបញ្ញត្តិនូវអត្ថបទច្បាប់មួយចំនួនទាក់ទងនឹងការសុំកូននេះ គួយ៉ាងដូចជាមានចែងចាប់ពីមាត្រា១០០៧ ដល់មាត្រា១០៣៣ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ និងមានច្បាប់មួយទៀតស្តីពីការសុំកូនអន្តរប្រទេស ក៏ឃើញមានចែងយ៉ាងច្បាស់ ពាក់ព័ន្ធនឹងការការពារកូនដែលត្រូវបានសុំ ។ ដោយហេតុនេះកូនដែលត្រូវបានសុំដើម្បីធ្វើជាកូនចិញ្ចឹមពេលខ្លះអាចក្លាយជាកម្មវត្ថុនៃពេស្យាកម្មផងដែរ ។

**១.៣.៧ តាមរយៈមិត្តភក្តិ**

មិត្តភក្តិ ក៏ជាកត្តាមួយដែលជំរុញឲ្យមានពេស្យាកម្មលើកុមារបានដែរ ព្រោះថាពេលខ្លះមិត្តភក្តិជាអ្នកជំរុញ និងលួងលោមឲ្យកុមារឈានដល់ហ៊ានប្រព្រឹត្តពេស្យាកម្ម ។ ពេលខ្លះវាអាចតាមការដើរលេងនៅតាមទីកន្លែងសប្បាយនានាមុនឈានដល់ការប្រព្រឹត្តពេស្យាកម្ម ។

**១.៣.៨ ការប្រើប្រាស់គ្រឿងញៀន និងថ្នាំសណ្តំ**

គ្រឿងញៀន និងថ្នាំសណ្តំគឺជាអាវុធដ៏មុតស្រួចបំផុត សម្រាប់បំផ្លាញជីវិតមនុស្ស ដោយហេតុនេះវាក៏ជាអាវុធ ឬឧបករណ៍សម្រាប់បង្កឲ្យមានពេស្យាកម្មលើកុមារផងដែរ ។ មូលហេតុថាកុមារភាគច្រើនត្រូវបានញៀនថ្នាំ ឬ ថ្នាំសណ្តំពីសំណាក់ជនផ្សេងទៀត ហើយធ្វើឲ្យបាត់បង់ស្មារតី ឬ ភាពជាម្ចាស់ការលើខ្លួនឯង ហើយក៏ធ្លាក់ខ្លួនទៅជាកម្មវត្ថុនៃពេស្យាកម្ម។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់អប់រំ និង ស្តារនីតិសម្បទាកុមារដែលបានប្រើប្រាស់គ្រឿងញៀន ដោយបាន

បង្កើតមណ្ឌលអប់រំចំនួន១០កន្លែង ( ភ្នំពេញ២កន្លែង ខេត្តបាត់ដំបង២កន្លែង បន្ទាយមានជ័យ ២កន្លែង កោះកុង១កន្លែង សៀបរាម១កន្លែង កំពង់ចាម១កន្លែង និងក្រុងព្រះសីហនុ១កន្លែង) ។ គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០០៧ អ្នកប្រើប្រាស់គ្រឿងញៀនមានចំនួន៣៥៧នាក់ ដែលបានចូលមកក្នុងមណ្ឌលទទួលការព្យាបាល ក្នុងនោះកុមារមានចំនួន១១៣នាក់ ។[3]

តារាងបែកចែកអាយុអ្នកប្រើប្រាស់គ្រឿងញៀន ដែលបានទទួលការព្យាបាលនៅក្នុងមណ្ឌលៈ

| អ្នកប្រើប្រាស់គ្រឿងញៀនបែកចែកតាមអាយុ | ចំនួនអ្នកប្រើប្រាស់គ្រឿងញៀន | ភាគរយ |
|---|---|---|
| អាយុ១២ឆ្នាំ ឬក្រោម | ៥នាក់ | ១% |
| អាយុ១៣ឆ្នាំ ដល់១៥ឆ្នាំ | ២៣នាក់ | ៦% |
| អាយុ១៦ឆ្នាំ ដល់១៨ឆ្នាំ | ៨៥នាក់ | ២៤% |
| សរុប | ១១៣នាក់ | ៣១% |

### ១.៣.៩ កង្វះខាតនៃការអប់រំ

ការអប់រំជាកម្លាំងចលករមួយដែរជំរុញឲ្យមនុស្សគ្រប់រូបរួចផុតពីអំពើអសកម្មនានា ព្រោះតែការអប់រំបានធ្វើឲ្យមនុស្សចេះគិតគូរបានល្អ ។ តែភាគច្រើនកុមារមួយចំនួនបានក្លាយជាកម្មវត្ថុនៃពេស្យាកម្មក៏ដោយសារតែកង្វះខាតនៃការអប់រំ ដោយពេលខ្លះកុមារទាំងអស់នោះ ពុំមានលទ្ធភាពចូលសាលាដើម្បីទទួលបាននូវចំនេះដឹង ។

### ១.៣.១០ ភាពធូរលុងនៃការអនុវត្តច្បាប់ដោយមន្ត្រីអនុវត្តច្បាប់

មូលហេតុមួយនេះជាមូលហេតុដ៏សំខាន់ដែរអាចកំណត់បានថាពេស្យាកម្ម ហើយភាពរីកចម្រើននៃពេស្យាកម្ម ក៏មកពីការអនុវត្តច្បាប់នៃមន្ត្រីអនុវត្តច្បាប់ នូវមានភាពធូរលុងនៅឡើយ ។ ជាការពិតជាក់ស្តែងច្បាប់ដែលប្រកាសឲ្យប្រើសុទ្ធសឹងតែល្អទាំងអស់ ដោយឡែកយើងនៅតែឃើញមានភាពអវិជ្ជមាន កើតចេញពីការអនុវត្តច្បាប់ដោយមន្ត្រីអនុវត្តច្បាប់ទាំងនោះទៀត ។ដោយសារតែហេតុនេះហើយ ទើបបានជាពេស្យាកម្មលើកុមារនៅកម្ពុជានៅតែមានកំណើនកើនឡើង ព្រោះតែការអនុវត្តច្បាប់នៅធូរលុង។ តួយ៉ាងគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិបានសម្តែងក្តីបារម្ភយ៉ាងខ្លាំងនៅក្នុងការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការដែលដាក់ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ដោយក្នុងនោះគណៈកម្មាធិការបានសម្តែងកង្វល់ថារាល់ការកេងប្រវ័ញ្ចលើ

[3] របាយការណ៍លើកទី២ និងលើកទី៣ របស់កម្ពុជាស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារឆ្នាំ២០០០ ដល់២០០៧

កុមារ ពេស្យាចារ ជនល្មើសនៃការបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទកម្រត្រូវបានចោទប្រកាន់ដែលតាមការសង្កេតគឺ ដោយសារបណ្តាលមកពីការរីករាលដាលនៃដំណោះស្រាយក្រៅតុលាការនិង សំណាងទៅលើករណីបំពានផ្លូវភេទ ដែលត្រូវបានជំរុញដោយអាជ្ញាធរអនុវត្តច្បាប់។ ត្រង់ចំណុចនេះហើយដែលគណៈកម្មាធិការ បានសម្តែងកង្វល់ចំពោះការអនុវត្តច្បាប់យ៉ាងធូររលុងដោយមន្ត្រីអនុវត្តច្បាប់ ។[4]

## ១.៤ ទិន្នន័យស្តីពីបញ្ហាការធ្វើពេស្យាកម្មលើកុមារ

ដោយយោងទៅលើរបាយការណ៍ជាតិលើកទី១ និងលើកទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឆ្នាំ ២០០២ ដល់ឆ្នាំ២០១០ ឃើញថាពុំបានផ្តល់ទិន្នន័យច្បាស់លាស់អំពីទិន្នន័យស្តីពីបញ្ហាការធ្វើពេស្យាកម្មលើកុមារនោះទេ បើតាមការស្រាវជ្រាវរបស់យើងឃើញថាចាប់តាំងពីមុន រហូតមកដល់ដើមឆ្នាំ២០០៩ ពុំមានទិន្នន័យណាមួយបានបង្ហាញយ៉ាងជាក់លាក់អំពីបញ្ហានេះនៅឡើយទេ។ ដោយសារចំណុចអវិជ្ជមានបែបនេះ យើងយល់ថាកាលពីមុនក្នុងសង្គមជាក់ស្តែងវាប្រាកដជាមានការធ្វើពេស្យាកម្មលើកុមាររួចទៅហើយ គ្រាន់តែវាកើតមានភាគតិច ឬ ច្រើនបើតាមការសន្មត។ មួយវិញទៀតអាចមកពីប្រទេសកម្ពុជាពុំទាន់មានច្បាប់ ជាមូលដ្ឋានដើម្បីដាក់ជាកំហិតទៅដល់ជនដែលបានប្រព្រឹត្តព្រោះថាប្រទេសយើងទើបវារួចផុតពីរបបយង់ឃ្នង និងមានសង្គ្រាមស៊ីវិលទៀតផងនោះ ទើបបានជារាជរដ្ឋាភិបាលកម្ពុជាយើងពុំបានគិតគូរល្អិតល្អន់ទៅលើបញ្ហានេះ។ ក្រោយមកសង្គមមានការវិវត្តន៍ដោយមានទាំងការស្តារ និងការអភិវឌ្ឍន៍លើគ្រប់វិស័យជាថ្មី យើងក៏ឃើញថាបញ្ហាស្តីពីការធ្វើពេស្យាកម្មលើកុមារក៏វាមានការវិវត្តន៍ដែរ។ ត្រង់នេះគឺមានន័យថាការធ្វើពេស្យាកម្មលើកុមារនៅកម្ពុជា ក៏មានការរីកចំរើនគួរឲ្យកត់សម្គាល់ដោយកត្តានេះ ហើយដែលជំរុញឲ្យកម្ពុជាមានច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទនៅឆ្នាំ២០០៨។ ដោយសារតែច្បាប់ក៏មានក្នុងការអនុវត្តន៍ និង បូកបញ្ចូលការដាក់ទោសទណ្ឌ ហើយជនល្មើសប្រព្រឹត្តពេស្យាកម្មលើកុមារ ក៏មានការរីកចម្រើនផងនោះទើបបានជាមានទិន្នន័យបង្ហាញពាក់ព័ន្ធ ពីបញ្ហាការធ្វើពស្យាកម្មលើកុមារច្បាស់លាស់ពីឆ្នាំ២០០៩។ ដោយទិន្នន័យនោះយើងបានស្រាវជ្រាវចេញពីរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែម នៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់២០១០ ដោយរបាយការណ៍បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី០៩

[4] ចំនុចទី៧១ទំព័រ៣៩សារាចរណែនាំស្តីពីការអនុវត្តអានុសាសន៍របស់គណៈកម្មាធិការសិទ្ធកុមារនៃអង្គការសហប្រជាជាតិ ខែកក្កដា ឆ្នាំ ២០០២

ខែកញ្ញា ឆ្នាំ២០១១ រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដោយបានបង្ហាញទិន្នន័យមានដូចតទៅៈ

ក្នុងចន្លោះខែតុលាឆ្នាំ២០០៩ ដល់ខែតុលាឆ្នាំ២០១០ អគ្គស្នងការដ្ឋាននគរបាលជាតិ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេសសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម[5]ៈ

| ល.រ | ប្រភេទបទល្មើស | ចំនួនករណីបទល្មើស | ចំនួនជនរងគ្រោះ | ចំនួនជនល្មើស |
|---|---|---|---|---|
| ១ | ការទិញពេស្យាចារកុមារ | ១៥ | ៤៣ | ២២ |
| ២ | អំពើអូសទាញពេស្យចារកុមារ | ៣ | ៥ | ៩ |
| ៣ | សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ៦ | ៥៥ | ៩ |
| ៤ | ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ១៥ | ១១១ | ២០ |
| | សរុប | ៣៩ | ២១៤ | ៦០ |

ក្នុងឆ្នាំ២០១០សាលាដំបូងរាជធានីខេត្ត បានចាត់វិធានការលើករណីជួញដូរមនុស្ស និង អំពើកេងប្រវ័ញ្ចផ្លូវភេទ ចំនួន៨៧ករណីក្នុងនោះ មានជនជាប់សង្ស័យចំនួន១២២នាក់ ។ ក្នុងចំនោមរឿងក្តីទាំងនេះ រឿងក្តីចំនួន៥៥ត្រូវបានជំនុះជម្រះក្នុងនោះជនល្មើសចំនួន៧៦នាក់ត្រូវបានផ្តន្ទាទោស ។

ដោយទិន្នន័យទាំងនេះមានទិន្នន័យជាប់ពាក់ព័ន្ធនឹងការធ្វើពេស្យាកម្មលើកុមារដូចតទៅៈ[6]

| ល.រ | ប្រភេទបទល្មើស | ចំនួនករណី | ចំនួនជនល្មើស |
|---|---|---|---|
| ១ | ការទិញពេស្យាកម្មកុមារ | ១០ | ១៣ |
| ២ | ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ២ | ២ |
| | សរុប | ១២ | ១៥ |

[6],[6] របាយការណ៍ជាតិលើកទី១ និងលើកទី២ស្តីពីការអនុវត្តពិធីសារនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរមនុស្ស ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ

គិតត្រឹមខែធ្នូ ឆ្នាំ២០១០ បទល្មើសពាក់ព័ន្ធនឹងផ្លូវភេទកុមារ ក្រោមច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពីអាជីវកម្មផ្លូវភេទ និងសេពសន្ថវៈនៅតាមសាលាជម្រះក្តី ឆ្នាំ២០១០ សរុប ៣៣៨ករណីមានជនជាប់ចោទ៣៥៩នាក់មានទិន្នន័យពាក់ព័ន្ធនឹងបញ្ហាពេស្យាកម្មលើកុមារចំនួន ៖[7]

| ល.រ | ប្រភេទបទល្មើស | ចំនួនករណី | ចំនួនជនរងគ្រោះ | | ចំនួនជនជាប់ចោទ | | |
|---|---|---|---|---|---|---|---|
| | | | អនីតិជន | នីតិជន | ឃុំខ្លួន | មិនឃុំខ្លួន | នៅក្រៅឃុំ |
| ១ | សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២ | ២ | ០ | ៣ | ០ | ០ |
| ២ | ផ្តល់កន្លែងសម្រាប់ធ្វើពេស្យាចារ | ១០ | ១ | ១០ | ១៩ | ៣ | ២ |
| ៣ | បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ០ | ០ | ០ | ០ | ០ | ០ |
| ៤ | ការទិញពេស្យាចារកុមារ | ១១ | ២៦ | ០ | ១៨ | ២ | ៣ |
| ៥ | អំពើអូសទាញពេស្យាចារកុមារ | ២ | ៥ | ០ | ៩ | ១ | ២ |
| ៦ | ការឲ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងនឹងអំពើពេស្យាចារកុមារ | ០ | ០ | ០ | ០ | ០ | ០ |
| ៧ | កិច្ចសន្យានៃអំពើពេស្យាចារកុមារ | ០ | ០ | ០ | ០ | ០ | ០ |
| សរុប | | ២៥ | ៣៤ | ១០ | ៤៩ | ៦ | ៧ |

[7] របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាឆ្លើយតបសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងរបាយកាណ៍លើកទី២ និងលើកទី៣របស់កម្ពុជាស្តីពីការអនុវត្តសិទ្ធិកុមារឆ្នាំ២០១១

## ផ្នែកទី២ រូបភាពអាសអាភាសលើកុមារ

រូបភាពអាសអាភាសលើកុមារនៅកម្ពុជា ជាបញ្ហាដ៏ធំបំផុតមួយដែលវាចាប់ផ្តើមកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ រូបភាពអាសអាភាសនេះទៀតសោតមិនត្រឹមកើតមានតែនៅក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ តែវាក៏ជាកង្វល់មួយរបស់បណ្តាប្រទេសលើសកលលោក ដែលគួរតែយកចិត្តទុកដាក់ផងដែរ ព្រោះថារូបភាពអាសអាភាសចាប់ផ្តើមកើតមានឡើងទៅលើកុមារជាពិសេស។ ដោយសារហេតុនេះគេបានយកកុមារដើម្បីធ្វើជាកម្មវត្ថុនៃរូបភាពអាសអាភាសគឺព្រោះថាកុមារមានសមត្ថភាពយល់ដឹង មិនទាន់មានកម្រិតល្អប្រសើរ នាំឲ្យមានការគិតគូរពុំបានល្អនូវឡើយ។ មួយវិញទៀតកុមារមិនសូវមានការយល់ដឹងខ្ពស់អំពីបញ្ហាសុខភាពផ្លូវភេទ និងការរក្សាកិត្តិយសសម្រាប់ខ្លួនឯងនៅឡើយទេ ដោយសារហេតុនេះទើបកុមារកម្ពុជាងាយរងគ្រោះ ត្រូវបានគេយកទៅធ្វើជាកម្មវត្ថុនៃរូបភាពអាសអាភាស ។

### ២.១ និយមន័យ

តាមរយៈពិធីសារបន្ថែមនៃអនុសញ្ញាអង្គការសហប្រជាតិស្តីពី សិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និង រូបភាពឬសម្ភារៈអាសអាភាសកុមារដែលបានចូលជាធរមាននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ បានឲ្យនិយមន័យថា៖

"រូបភាព ឬសម្ភារៈអាសអាភាសកុមារ" គឺជាការបង្ហាញទាំងឡាយណា ទោះតាមរយៈមធ្យោបាយអ្វីក៏ដោយ អំពីសកម្មភាពរួមភេទជារូបពិតឬ ដោយការចម្លងរូបភាពពិត ឬការបង្ហាញអវៈយវៈរបស់កុមារ សម្រាប់គោលបំណងចម្បងខាងផ្លូវភេទ ។[៥] ត្រង់ចំណុចនេះមានន័យថារូបភាព ឬសម្ភារៈអាសអាភាសរបស់កុមារត្រូវបានគេយកទៅបង្ហាញតាមរយៈទម្រង់ផ្សេងៗ ពេលខ្លះអាចជាការបង្ហាញដោយក្រដាសជារូបភាព ខ្លះទៀតអាចជាការបង្ហាញរូបភាពឬសម្ភារៈអាសអាភាសតាមរយៈប្រព័ន្ធបច្ចេកវិទ្យាពិសេសគឺតាមរយៈប្រព័ន្ធអ៊ីនធឺណែត ដែលអាចស្វែងតាមរយៈគេហៈទំព័រអាសអាភាសនានា និងពិសេសតាមរយៈគេហទំព័រសង្គមនានា ។ លើសពីនេះគេអាចឈានដល់យកកុមារតែម្តងដើម្បីធ្វើការបង្ហាញក្នុងគោលបំណងចម្បងខាងផ្លូវភេទ ។

បើយោងទៅតាមមាត្រា៤០នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ ត្រង់មាត្រា២៣ បានប្បញ្ញត្តិន័យមួយផ្សេងទៀតបានឲ្យនិយមន័យថា៖

"រូបភាព ឬសម្ភារៈអាសអាភាសកុមារ"គឺសម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជនដែលធ្វើឲ្យរំភើប

[៥] មាត្រា២ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារឆ្នាំ២០០២

ឬរំជួលដល់ចំណង់ផ្លូវភេទ។[9] ត្រង់ន័យនេះ គឺរិតតែបង្ហាញឲ្យយល់កាន់តែច្បាស់ពីនិយមន័យនៃរូបភាព ឬសម្ភារៈអាសអាភាសកុមារ ដោយកុមារក្លាយជាឧបករណ៍អរូបី ដើម្បីឲ្យគេមានចំណង់ខាងផ្លូវភេទ ដោយតាមការយករូបថត ខ្សែវីដេអូ គ្រឿងអេឡិចត្រូនិចដែលមានភាពអាក្រាតរបស់កុមារនោះក្នុងគោលដៅឲ្យគេមានចំណង់ខាងផ្លូវភេទ ។

**២.២ រូបភាពអាសអាភាសលើកុមារ**

ជាទូទៅរូបភាពដែលឆ្លុះបញ្ចាំងពីរូបភាពអាសអាភាសលើកុមារមានដូចជា៖

-ការចែកចាយ លក់ ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព ឬសម្ភារៈអាសអាភាសលើកុមារ

-ការកាន់កាប់ ការដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាព ឬសម្ភារៈអាសអាភាសលើកុមារក្នុងគោលបំណងយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស

-ការផលិតរូបភាព ឬសម្ភារៈអាសអាភាសលើកុមារ[10]

**២.៣ មូលហេតុដែលនាំឲ្យមានរូបភាពអាសអាភាសលើកុមារ**

មូលហេតុដែលនាំឲ្យមានរូបភាពអាសអាភាសលើកុមារបណ្តាលមកពី៖

**២.៣.១ កំណើននៃទេសចរណ៍ផ្លូវភេទ**

ការរីកចំរើននៃទេសចរណ៍ផ្លូវភេទជាកម្លាំងចលករដែលជំរុញឲ្យមានរូបភាព ឬ សម្ភារៈអាសអាភាសលើកុមារ គឺពីព្រោះថាទេសចរណ៍ផ្លូវភេទកាន់តែកាន់ច្រើន ភាពរីកចម្រើននៃរូបភាពអាសអាភាសលើកុមារក៏កាន់តែច្រើនឡើងដែលវានឹងលេចឡើងតាមរយៈគ្រឿងអេឡិចត្រូនិច និងតាមរយៈរូបថត ឬតាមរយៈខ្សែវីដេអូនានា ដើម្បីផ្គត់ផ្គង់នឹងសេចក្តីត្រូវការរបស់មនុស្ស ។

**២.៣.២ ភាពរីកចម្រើននៃបច្ចេកវិទ្យា**

បើតាមការវិវត្តន៍នៃបច្ចេកវិទ្យាវាប្រាកដជាផ្តល់នូវផលល្អសម្រាប់ដំណើរនៃជីវិតមនុស្ស តែទន្ទឹមនឹងភាពងាយស្រួល វាក៏ផ្តល់ផលអាក្រក់មួយចំនួនដល់សង្គមផងដែរ។ តួយ៉ាងភាពរីកចម្រើននៃបច្ចេកវិទ្យាជាហេតុនាំឲ្យមានរូបភាព ឬសម្ភារៈអាសអាភាសលើកុមារ ដោយសារថាមានការបញ្ចូលជារូបថត ឬវីដេអូទៅក្នុងប្រព័ន្ធអ៊ីនធឺណែតគ្រាន់ទុកដល់សាធារណជនចូលទៅមើលដើម្បីកំដរអារម្មណ៍។ ដោយសារហេតុនេះទើបកុមារងាយរងគ្រោះនឹងត្រូវបានគេអូសទាញដើម្បី ថតជារូបភាពឬវីដេអូផ្សេងៗ។លើសពីនេះដោយសារបច្ចុប្បន្នការរីកចម្រើននៃ ប្រព័ន្ធបច្ចេកវិទ្យា

[9] មាត្រា៥០នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨

[10] មាត្រា៣ (១)(គ) ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ មាត្រា៤១នៃច្បាប់ស្តីពីការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០០២

ដោយទូរសព្ទ និង គ្រឿងអេឡិចត្រូនិចផ្សេងទៀត មានកាម៉ារាមុខនាំឲ្យមានការថតរូបជាលក្ខណៈសេរីដោយហេតុនេះកុមារអាចត្រូវបានថតរូបអាក្រាត ដើម្បីធ្វើឲ្យគេមានចំណង់ផ្លូវភេទ ។

### ២.៣.៣ ចំណង់ផ្លូវភេទហួសព្រំដែន

ពេលខ្លះមនុស្សគ្រប់រូបប្រាថ្នាតែងតែចង់បានសុភមង្គលតាមមធ្យោបាយខុសៗគ្នា ដោយអ្នកខ្លះគេមានសុភមង្គលដោយសារតែអាចបំពេញចំណង់ផ្លូវភេទរបស់គេបានគ្រប់គ្រាន់ និងទៅតាមសេចក្តីត្រូវការរបស់គេ ដោយសារនេះទើបបានជាយើងលើកយកចំណង់ផ្លូវភេទហួសព្រំដែនមកធ្វើជាមូលហេតុដែលនាំឲ្យមានរូបភាពអាសអាភាសលើកុមារ ព្រោះថាបុគ្គលទាំងនោះអាចនឹងរក្សាទុកនូវរូបថត វីដេអូ និង សម្ភារៈផ្សេងៗទៀតនៃកុមារដើម្បីនឹងឲ្យចំណង់ផ្លូវភេទរបស់ខ្លួនកើតឡើង។ពេលខ្លះដោយសារតែចំណង់ចេះតែកើតមានឥតឈប់ឈរ បុគ្គលទាំងនោះអាចប្រើប្រាស់កុមារឲ្យបង្ហាញភាពអាក្រាតដើម្បីជាការដាស់អារម្មណ៍របស់ពួកគេ ។

### ២.៤ ទិន្នន័យស្តីពីបញ្ហារូបភាពអាសអាភាសលើកុមារ

ជាការពិតទិន្នន័យពាក់ព័ន្ធ នឹង រូបភាពអាសអាភាសលើកុមារគឺមានស្ថានភាពដូចបញ្ហាពេស្យាកម្មទៅលើកុមារដែរគឺពុំមានការផ្តល់ទិន្នន័យជាក់លាក់នោះទេតាំងពីពេលមុនមក វាទើបតែមានការផ្តល់ទិន្នន័យជាក់លាក់នៅដើមឆ្នាំ២០០៩ ប៉ុណ្ណោះ ខណៈពេលដែលព្រះរាជាណាចក្រកម្ពុជាយើងមានច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨។ ដោយក្នុងនោះមានទិន្នន័យបង្ហាញពីបញ្ហារូបភាពអាសអាភាសដូចតទៅ៖

ក្នុងចន្លោះខែតុលាឆ្នាំ២០០៩ ដល់ខែតុលាឆ្នាំ២០១០ អគ្គស្នងការដ្ឋាននគរបាលជាតិ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេសសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖[11]

| ល.រ | ប្រភេទបទល្មើស | ចំនួនករណីបង្ក្រាប | ចំនួនជនរងគ្រោះ | ចំនួនជនល្មើស |
|---|---|---|---|---|
| ១ | រូបភាពនិងសម្ភារៈអាសអាភាស | ៦ | ៥៤ | ១៨ |
| ២ | រូបភាពនិងសម្ភារៈអាសអាភាសលើកុមារ | ២ | ១ | ២ |
| សរុប | | ៨ | ៥៥ | ២០ |

[11] របាយការណ៍ជាតិលើកទី២ និងលើកទី៣ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ ២០០២ ដល់ឆ្នាំ២០១០

គិតត្រឹមខែធ្នូ ឆ្នាំ២០១០ បទល្មើសពាក់ព័ន្ធនឹងផ្លូវភេទកុមារ ក្រោមច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពីអាជីវកម្មផ្លូវភេទ និងសេពសន្ថវៈនៅតាមសាលាជម្រះក្តី ឆ្នាំ២០១០ សរុប ៣៣៨ករណី ជនជាប់ចោទ៣៥៩នាក់ ក្នុងមានទិន្នន័យពាក់ព័ន្ធនឹងបញ្ហារូបភាពអាសអាភាសលើកុមារដូចជា៖[12]

| ល.រ | ប្រភេទបទល្មើស | ចំនួនករណី | ចំនួនជនរងគ្រោះ | | ចំនួនជនជាប់ចោទ | | |
|---|---|---|---|---|---|---|---|
| | | | អនីតិជន | នីតិជន | ឃុំខ្លួន | មិនឃុំខ្លួន | នៅក្រៅឃុំ |
| ១ | រូបភាព និងសម្ភារៈអាសអាភាស | ២ | ៥ | ៥ | ៧ | ១ | ១ |
| ២ | រូបភាព និងសម្ភារៈអាសអាភាសលើកុមារ | ២ | ១ | ០ | ២ | ០ | ០ |
| សរុប | | ៤ | ៦ | ៥ | ៩ | ១ | ១ |

## ជំពូកទី២ អនុសាសន៍របស់អង្គការសហប្រជាជាតិលើបញ្ហាពេស្យាកម្មលើកុមារ និងរូបភាពអាសអាភាសលើកុមារ

អង្គការសហប្រជាជាតិជាស្ថាប័នអន្តរជាតិមួយដែលបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅដល់សុខសន្តិភាពអន្តរជាតិ ជាពិសេសគឺការការពារទៅដល់សិទ្ធិនិងសេរីភាពរបស់ប្រជាជនពិភពលោក ដែលជាសមាជិករបស់ខ្លួន ។ ក្នុងនោះអង្គការសហប្រជាជាតិបានផ្តល់ជាអនុសាសន៍ដល់កម្ពុជាផងដែរជុំវិញបញ្ហាការធ្វើពេស្យាកម្មលើកុមារ ។

### ផ្នែកទី១ អនុសាសន៍លើបញ្ហាការធ្វើពេស្យាកម្មលើកុមារ

#### ១.១ ការអប់រំផ្សព្វផ្សាយ

គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិបានស្នើឲ្យកម្ពុជា ធ្វើការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការផ្សព្វផ្សាយអនុសញ្ញានៅពាសពេញប្រទេស ដើម្បីលើកកម្ពស់ការយល់

[12] របាយការណ៍ឆ្លើយតបរបស់សំណួររបស់គណកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងរបាយការណ៍លើកទី២ និងលើកទី៣ របស់កម្ពុជាស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារឆ្នាំ២០១១

ដឹងរបស់សាធារណៈរួមទាំងកុមារខ្លួនឯង និងមាតាបិតា ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីគោលការណ៍ និងបទប្បញ្ញត្តិរបស់អនុសញ្ញា[13]។

ម្យ៉ាងវិញទៀតគណៈកម្មាធិការ បានស្នើអោយមានកិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្តកម្មវិធីអប់រំប្រកបដោយគុណភាពដែលមានលក្ខណៈជាប្រព័ន្ធនិងបណ្តុះបណ្តាលលើគោលការណ៍ និង បទប្បញ្ញត្តិនៃអនុសញ្ញាសម្រាប់រាល់ក្រុមអ្នកមានវិជ្ជាជីវៈទាំងអស់ដែលធ្វើការងារដើម្បីកុមារ និងធ្វើការជាមួយកុមារដូចជាចៅក្រមមេធាវីមន្ត្រីអនុវត្តច្បាប់ មន្ត្រីរាជការបុគ្គលិកដែលធ្វើការនៅក្នុងស្ថាប័នទីកន្លែងឃុំឃាំងកុមារ គ្រូបង្រៀន បុគ្គលិកសុខាភិបាលរួមទាំងអ្នកចិត្តវិទ្យា និងភ្នាក់ងារសង្គមកិច្ច។

## ១.២ ការពង្រឹងផ្នែកច្បាប់

គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិបានទទូចអោយកម្ពុជា ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការអនុវត្តច្បាប់របស់ខ្លួន ដោយកំណត់ទោសព្រហ្មទណ្ឌនូវអំពើធ្វើអាជីវកម្មផ្លូវភេទ និងបំពានផ្លូវភេទក្នុងគោលបំណងដើម្បីធានាថា ជនដែលបានប្រព្រឹត្តិល្មើសខាងផ្លូវភេទលើកុមារនឹងត្រូវបាននាំមកកាន់តុលាការ និងផ្តន្ទាទោសដ៏សមស្រប [14] ។

ធ្វើការថ្កោលទោសព្រមទាំងចាត់វិធានការដ៏សកម្មប្រឆាំងនឹងបុគ្គល និងសហគ្រាសដែលផ្តល់ការសម្របសម្រួល ឬបង្កឲ្យមានទេសចរណ៍ផ្លូវភេទកើតឡើង ។

ដោយឡែកតាមរយៈរបាយការណ៍របស់ក្រុមការងារអំពីការត្រួតពិនិត្យជាសកល តាមកាលកំណត់ជាទូទៅ ដែលត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី២៧ មីនា ២០១៤ក្នុងនោះប្រទេសប៊ែលហ្សិកបានធ្វើការស្នើឲ្យកម្ពុជាធ្វើការប្រយុទ្ធប្រឆាំងនឹងបញ្ហានៃការរំលោភសេពសន្ថវៈ និងពេស្យាចារលើអនីតិជន ដោយធានាពីការអនុវត្តន៍ដោយពេញលេញនូវច្បាប់នានា ដែលដាក់ទោសដល់អំពើរំលោភបំពាន និងអាជីវកម្មផ្លូវភេទ[15] ។

ប្រទេសអ៊ុយរុយហ្គាយក៏បានស្នើឲ្យកម្ពុជាចាត់គ្រប់វិធានការចាំបាច់ ដើម្បីទប់ស្កាត់ប្រយុទ្ធនឹងអំពើហិង្សា និងការបំពានផ្លូវភេទលើស្ត្រីនិងកុមារ រួមទាំងការរំលោភសេពសន្ថវៈដោយលើកស្ទួយយន្តការប្រកបដោយប្រសិទ្ធភាពមួយ ដើម្បីទទួល និងស៊ើបអង្កេតពាក្យបណ្តឹងអំពីអំពើហិង្សាផ្លូវភេទ ហើយផ្តល់ដល់ជនរងគ្រោះ នូវជំនួយផ្លូវចិត្ត និងផ្នែកសុខភាព ។

[13] ទំព័រទី១១ នៃសារាចរណែនាំការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិឆ្នាំ២០១២

[14] ទំព័រ៣៨នៃសារាចរណែនាំការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិឆ្នាំ២០១២

[15] របាយការណ៍ត្រួតពិនិត្យជាសាកលតាមកាលរបស់គណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិឆ្នាំ២០១៤

### ១.៣ ការរៀបចំគោលនយោបាយជាតិ

ក្នុងពេលកន្លងមកគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ក៏ដូចជាប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិទាំងអស់បាន ធ្វើការផ្តល់ជាអនុសាសន៍មកដល់កម្ពុជាក្នុងការធ្វើឲ្យកាន់តែមានភាពប្រសើរឡើងលើបញ្ហាកិច្ចការពារសិទ្ធិកុមារពីការរំលោភបំពាននានា ជាពិសេសលើការរៀបចំគោលនយោបាយជាតិរបស់ខ្លួនអោយបានកាន់តែប្រសើរឡើង និង ពង្រឹងលើការអនុវត្តចំពោះគោលនយោបាយដែលមានស្រាប់។ ក្នុងនោះផងដែរគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ បានទទូចអោយកម្ពុជាចាត់វាល់វិធានការដ៏សមស្របទាំងអស់ដើម្បីធានានូវការអនុវត្តដ៏ពេញលេញនូវគោលការណ៍និងបទប្បញ្ញត្តិទាំងឡាយរបស់អនុសញ្ញាទៅតាមលំដាប់លំដោយនៃច្បាប់ក្នុងស្រុករបស់ខ្លួនរួមទាំងបង្កើតនូវយន្តការក្របខណ្ឌ និង ប្រព័ន្ធដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់អនុវត្តច្បាប់ទាំងឡាយ ដែលពាក់ព័ន្ធជាមួយកុមារពីថ្នាក់ជាតិ ខេត្តនិងក្រុង។

គណៈកម្មាធិការក៏សូមទទូចបន្ថែមទៀត ឲ្យរដ្ឋភាគីបង្កើនល្បឿនក្នុងការធ្វើច្បាប់ស្តីពីកិច្ចការពារកុមារឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយដែលគ្របដណ្តប់រាល់គោលការណ៍ និងបទប្បញ្ញត្តិទាំងអស់នៃអនុសញ្ញា និងធានាថា ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលកំពុងបានធ្វើសេចក្តីព្រាងនាពេលបច្ចុប្បន្ន ត្រូវបានបញ្ចូលយ៉ាងពេញលេញទៅក្នុងច្បាប់នេះ [16] ។

ដោយឡែកតាមរយៈរបាយការណ៍របស់ក្រុមការងារអំពីការត្រួតពិនិត្យជាសកល តាមកាលកំណត់ជាទូទៅ ដែលត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី២៧ មីនា ២០១៤ប្រទេសព័រទុយហ្គាល់បានស្នើឲ្យកម្ពុជាអនុម័តនិង អនុវត្តច្បាប់ដែលហាមឃាត់ រាល់ទម្រង់នៃការប្រព្រឹត្តមិនគប្បីលើកុមារ និងដែលការពារពួកគេពីពលកម្មដោយបង្ខំការកេងប្រវ័ញ្ចផ្លូវភេទនិងការបំពាន[17]។

## ផ្នែកទី២ អនុសាសន៍លើបញ្ហារូបភាពអាសអាភាសលើកុមារ

### ២.១ ការអប់រំផ្សព្វផ្សាយ

គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិបានផ្តល់អនុសាសន៍ដល់កម្ពុជាដែលជារដ្ឋភាគីគួរដាក់បញ្ចូលគោលការណ៍និងបទប្បញ្ញត្តិនៃអនុសញ្ញា និងពិធីសារបន្ថែមពាក់ព័ន្ធទៅក្នុងកម្មវិធីសិក្សារដ្ឋ ដើម្បីកាត់បន្ថយ និងបង្ការនូវបញ្ហាទាំងនេះ [18] ។

គណៈកម្មាធិការមានការព្រួយបារម្ភសមត្ថភាព ដែលនៅមានកម្រិតរបស់រដ្ឋភាគីដើម្បីតាមដានការអនុវត្តអនុសញ្ញានេះនិងអវត្តមានយន្តការឯករាជ្យចុះឈ្មោះនិងដោះស្រាយពាក្យបណ្តឹងពី

[16] ទំព័រ៥សារាចរណែនាំការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិឆ្នាំ២០១២

[17] របាយការណ៍ត្រួតពិនិត្យជាសាកលតាមកាលរបស់គណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិឆ្នាំ២០១៤

[18] របាយការណ៍ត្រួតពិនិត្យជាសាកលតាមកាលរបស់គណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ចុះថ្ងៃ ២៨ ខែមិថុនា ឆ្នាំ ២០០០

កុមារពាក់ព័ន្ធនឹងការរំលោភសិទ្ធិរបស់ពួកគេស្ថិតក្រោមអនុសញ្ញានេះ ។ ពាក់ព័ន្ធបញ្ហានេះគណៈកម្មាធិការបានស្នើរអោយរដ្ឋភាគីពង្រឹងសមត្ថភាពមន្ត្រីរបស់ខ្លួន ដោយមានការសហការជាមួយអង្គការសង្គមស៊ីវិលដែលស្ថិតក្នុងប្រទេសរបស់ខ្លួន ។

### ២.២ ការពង្រឹងផ្នែកច្បាប់

ប្រទេសបែលហ្សិក ដែលជាសមាជិកអង្គការសហប្រជាជាតិមួយផងដែរនោះបានស្នើរដល់កម្ពុជាតាមរយៈរបាយការណ៍ត្រួតពិនិត្យជាសកលតាមកាលកំណត់ គឺស្នើអោយកម្ពុជាចាត់វិធានការចាំបាច់នានាដើម្បីធានាថាកុមារ និងអនីតិជននៅក្នុងមជ្ឈមណ្ឌល ស្តារនីតិសម្បទា និងមជ្ឈមណ្ឌលយុវជន ទោះយ៉ាងណាក៏ដោយ មិនត្រូវដាក់ឲ្យទៅជា កន្លែងធ្វើទារុណកម្ម ឬការប្រព្រឹត្តមិនគប្បីឡើយ ស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញា ស្តីពីសិទ្ធិកុមារ ។

ដោយឡែកអាល់ហ្សេរី បានស្នើឲ្យកម្ពុជាពង្រឹងវិធានការប្រយុទ្ធនឹងពលកម្មកុមារ និងការកេងប្រវ័ញ្ចលើកុមារ ។

ប្រទេសអ៊ុយរុយហ្គាយក៏បានស្នើឲ្យកម្ពុជាចាត់គ្រប់វិធានការចាំបាច់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធនឹងអំពើហិង្សា និងការ បំពានផ្លូវភេទលើស្ត្រី និងកុមារ រួមទាំងការរំលោភសេពសន្ថវៈ ដោយលើកស្ទួយយន្តការ ប្រកបដោយប្រសិទ្ធភាពមួយ ដើម្បីទទួល និងស៊ើបអង្កេតពាក្យបណ្ដឹង អំពីអំពើហិង្សា ផ្លូវភេទ ហើយផ្ដល់ដល់ជនរងគ្រោះ នូវជំនួយផ្លូវចិត្ត និងផ្នែកសុខភាព ។

ដោយឡែកឆ្លើយតបនឹងរបាយការណ៍ត្រួតពិនិត្យជាសកលតាមកាលកំណត់ អង្គការសង្គមស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជាបានស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជារបស់ខ្លួន គួរតែពង្រឹងការអនុវត្តច្បាប់និងការបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់ទោសជនល្មើសនៃការជួញដូរ និង ការរំលោភបំពានផ្លូវភេទក៏ដូចជាមន្ត្រីពុករលួយពាក់ព័ន្ធនឹងបទឧក្រិដ្ឋនេះ។ រាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើការអភិវឌ្ឍ រក្សាមូលដ្ឋានទិន្នន័យឲ្យ ទូលំទូលាយនឹងអាចជឿទុកចិត្ត ស្តីពីករណីការជួញដូរមនុស្សនិងធានាថាព័ត៌មានត្រូវបានបន្តចែករំលែកជាមួយក្រុមសង្គមស៊ីវិលដូច្នេះទំហំនៃ បញ្ហានេះអាចត្រូវបានកំណត់ឱ្យបានត្រឹមត្រូវនូវការការពារ ការស្តារនីតិសម្បទាសមស្របនិងកម្មវិធីសមាហរណកម្មអាចត្រូវបានរៀបចំ ។[19]

### ២.៣ ការរៀបចំគោលនយោបាយជាតិ

គណៈកម្មាធិការនេះបានផ្ដល់អនុសាសន៍ថារដ្ឋភាគីគួរពិចារណាបង្កើតយន្តការឯករាជ្យមួយដើម្បីតាមដានការអនុវត្តនៃអនុសញ្ញានិង ដើម្បីដោះស្រាយពាក្យបណ្ដឹងនៃការរំលោភបំពានសិទ្ធិរបស់កុមារ ដែលផ្ដល់ភាពងាយស្រួលនិងឆាប់រហ័សមួយដើម្បីធានាបាននូវយុត្តិធម៌ដល់កុមារ។

[19] ការដាក់ជូនរបាយការណ៍ត្រួតពិនិត្យជាសកលតាមកាលកំណត់ដោយអង្គការសង្គមស៊ីវិលស្តីពីសិទ្ធិកុមារ ឆ្នាំ២០០៩-២០១៣ ដោយសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(ស.អ.ស.ក)

ហើយជាពិសេសធានាបានថាយន្តការនេះត្រូវ តែមានលក្ខណៈបែបកុមារមេត្រីលើកកម្ពស់ការយល់ដឹង ដើម្បីជួយសម្រួលដល់ការប្រើប្រាស់មានប្រសិទ្ធភាពដោយកុមារ ។

## ជំពូកទី៣ កិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាពេស្យាកម្ម និង រូបភាពអាសអាភាសលើកុមារ

### ផ្នែកទី១ ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល

#### ១.១ ការអប់រំផ្សព្វផ្សាយ

- រាជរដ្ឋាភិបាលបានជម្រុញអោយមានការយល់ដឹងជាសាធារណៈអំពីច្បាប់ ការអនុវត្តច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមរយៈការបើកវេទិកាជាសាធារណៈតាមរាជធានីខេត្ត ។
- បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់មន្ត្រីអនុវត្តច្បាប់ រួមមាននគរបាលឯកទេសកងរាជអាវុធហត្ថ ព្រះរាជអាជ្ញា និងចៅក្រមអំពីបច្ចេកទេសស៊ើបអង្កេត ចោទប្រកាន់ ផ្តន្ទាទោស រួមទាំងបច្ចេកទេសលើកទឹកចិត្តដល់ជនរងគ្រោះដែលជាសាក្សីឲ្យហ៊ានឆ្លើយនៅចំពោះមុខតុលាការ ។
- ធ្វើការបណ្តុះបណ្តាលមន្ត្រីជួរមុខរួមមាន វរសេនាតូចការពារព្រំដែន កងកម្លាំងនគរបាល អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ។
- រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ បានដាក់បញ្ចូលមូលដ្ឋានសិទ្ធិកុមារ ទៅក្នុងវគ្គបណ្តុះបណ្តាលដល់សិស្សមេធាវីរបស់ខ្លួន ។
- បណ្ឌិតសភានគរបាលបានធ្វើការបណ្តុះបណ្តាល ដល់នគរបាលយុត្តិធម៌ជាង១៧០០នាក់ទាក់ទងនិងការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរកុមារ និងនីតិវិធីក្នុងការចាត់ការករណីទាំងនោះ [20]។
- គិតមកទល់ឆ្នាំ២០០៩ ៥៤ភាគរយនៃមន្ត្រីសង្គមកិច្ច ថ្នាក់ជាតិ ថ្នាក់រាជធានីខេត្ត និង ៨៣ភាគរយនៃមន្ត្រីសង្គមកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌបានទទួលវគ្គបណ្តុះបណ្តាលមូលដ្ឋាន និង ជំនាញស្តីពីកិច្ចការសង្គម ដែលក្នុងនោះមេរៀនស្តីពីតួនាទីមន្ត្រីសង្គមនៅក្នុងប្រព័ន្ធយុត្តិធម៌កុមារ ត្រូវបានដាក់បញ្ចូល[21]។

---

[20] ចំណុច២២នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[21] ចំណុច៦២នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

- មន្ត្រីរាជការរាជធានី ខេត្តបានទទួលវគ្គបណ្តុះបណ្តាលពីយុទ្ធសាស្ត្រទប់ស្កាត់ប្រឆាំងអំពើជួញដូរស្ត្រី និងកុមារ។
- ក្រសួងអប់រំយុវជន និងកីឡាបានដាក់បញ្ចូលអនុសញ្ញាអង្គការសហប្រជាជាតិទៅក្នុងកម្មវិធីសិក្សា ។
- ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការផ្សព្វផ្សាយអំពីវិធានការ និងផែនការប្រឆាំងទប់ស្កាត់អំពើជួញដូរមនុស្ស ដល់សិស្ស និស្សិតនៅតាមសាលា និងឧត្តមសិក្សាទូទាំងប្រទេសរួមទាំងកម្មវិធីអប់រំក្រៅប្រព័ន្ធ និងមានកម្មវិធីត្រួតពិនិត្យតាមដានសុវត្ថិភាពតាមសាលា ។
- ក្នុងឆ្នាំ២០០២ក្រុមប្រឹក្សាឃុំ សង្កាត់បានជ្រើសរើសជនបង្គោលដើម្បីទទួលខុសត្រូវការងារស្ត្រី និងកុមារដើម្បីបណ្តុះបណ្តាល និងទទួលបន្ទុកការងារស្ត្រីនិងកុមារ។
- ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌បានរៀបចំការបណ្តុះបណ្តាលរួមគ្នានិងដាច់ដោយឡែកពីគ្នាដល់នគរបាលយុត្តិធម៌ វេជ្ជបណ្ឌិត និងមន្ត្រីតុលាការ អំពីនីតិវេជ្ជវិទ្យា និងការស៊ើបអង្កេតលើករណីរំលោភបំពានផ្លូវភេទលើកុមារ។
- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យមួយក្នុងឆ្នាំ២០១១ស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច ដើម្បីធ្វើការបណ្តុះបណ្តាល និងស្រាវជ្រាវផ្នែកសង្គមកិច្ច ។
- សៀវភៅបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាល ត្រូវបានធ្វើបច្ចុប្បន្នកម្មដោយដាក់បញ្ចូលបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបញ្ញត្តិនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ។
- ក្នុងឆ្នាំ២០០១ មន្ត្រីនគរបាលរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចំនួន០៨នាក់ បានទៅចូលរួមនៅក្នុងការបណ្តុះបណ្តាលថ្នាក់តំបន់របស់អាស៊ាន ស្តីពីការបង្ការបទល្មើសឆ្លងដែន ការជួញដូរដើម្បីពលកម្មដោយបង្ខំ និងការកេងប្រវ័ញ្ចផ្លូវភេទ ទេសចរណ៍ផ្លូវភេទលើកុមារ ការស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះ ។
- ក្រសួងកិច្ចការនារីដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងចន្លោះឆ្នាំ២០០១ ដល់២០០៦ ក្រសួងបានធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន អំពីការជួញដូរមនុស្សការធ្វើចំណាកស្រុក និង ច្បាប់ដល់ប្រជាពលរដ្ឋនៅតាមសហគមន៍គោលដៅក្នុងទូទាំង២៤ រាជធានីខេត្ត តាមរយៈការបញ្ចាំងវីដេអូ សម្តែងរឿងកំប្លែង ពាក់ព័ន្ធការជួញដូរ

មនុស្សនិងមានការសួរសំណួរចម្លើយ[22]។

- ក្នុងឆ្នាំ២០០៧ គណៈកម្មធិការសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ របស់ក្រសួងទេសចរណ៍នៅរាជធានីភ្នំពេញនិងបណ្តាញទាំង២៤រាជធានីខេត្ត បានបណ្តុះបណ្តាលមនុស្សពេញវ័យបានចំនួន៥១៨៤នាក់ និង កុមារចំនួន៩៧០នាក់។ ក្នុងឆ្នាំ២០០៨អង្គភាពនេះបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការជាតិ អន្តរជាតិបានធ្វើការបណ្តុះបណ្តាលមនុស្សពេញវ័យចំនួន២៣៩១នាក់ និងកុមារចំនួន៤៥៨នាក់ ។ក្រៅពីការងារអប់រំ និងការបណ្តុះបណ្តាលបានផលិតសម្ភារៈអប់រំផ្សព្វផ្សាយដូចជា វីដេអូស្ប៉ុត ស្លាកបិទ សៀវភៅតូចៗ ផ្ទាំងរូបភាពខ្នាតតូចផ្ទាំងរូបភាពខ្នាតធំៗ សម្រាប់ចែកចាយ និងផ្សព្វផ្សាយតាមសហគមន៍ទេសចរណ៍ ទេសចរណ៍គោលដៅ រមណីយដ្ឋានទេសចរណ៍ និងនៅតាមរាជធានីខេត្ត មួយចំនួន[23]។
- តាមរយៈកម្មវិធីបណ្តាញសុវត្ថិភាពកុមារតាមសហគមន៍ បានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់ប្រជាជននៅក្នុងភូមិ លើប្រធានបទចំនួនបីគឺទី១ការចុះអាត្រានុកូលដ្ឋាន ទី២ការប្រឆាំងការរំលោភបំពានផ្លូវភេទ ទី៣ការប្រឆាំងការវាយដំលើកុមារ។ កម្មវិធីនេះបានធ្វើការផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងដល់ប្រជាជននៅក្នុងភូមិចំនួន១៤០៣៩ នៃ ១៨៤ស្រុកទូទាំងប្រទេសលើប្រធានទាំងបីខាងលើនេះ[24]។

### ១.២ ការអន្តរាគមន៍

- អាជីវករចំនួន២៦១៨គិតមកដល់ឆ្នាំ២០០៨ ដែលរកស៊ីលក់ឌីវីឌីរូបភាពត្រូវបានណែនាំនិងចុះកិច្ចសន្យាឈប់ប្រកបរបរខុសច្បាប់ទៀត ចំណែកហាងវីដេអូខុសច្បាប់ចំនួន១០២ត្រូវបានបិទអាជីវកម្ម [25] ។
- គណៈកម្មាធិការអន្តរក្រសួងនៅតាមរាជធានីខេត្តបាន បើកប្រត្តិបត្តិការចុះបង្ក្រាបដកហូត ដុតបំផ្លាញវីស៊ីឌី និងឌីវីឌីដែលហាមឃាត់ចំនួន៦៧៥៤៩ បន្ទះ រួមទាំងកាសែតវីដេអូ និង សម្ភារៈលួចចម្លងដែលជនដៃដល់បានប្រើប្រាស់សម្រាប់ផលិត និង

[22] ចំណុច៣នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[23] ចំណុច៣៥នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[24] ចំណុច៣៣នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[25] ចំណុច១២នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

ផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាសដែលក្នុងនោះដកហូតនូវវីស៊ីឌី និងឌីវីឌីជាច្រើនសែនបន្ទះ [26] ។

- គណៈកម្មាធិការជាតិដឹកនាំការបង្រ្កាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្រ្តីនិងកុមារ រាជធានីខេត្ត បានផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ ភាពយន្ត ប៉ាណូ បដា និងផ្សព្វផ្សាយដល់ម្ចាស់អាជីកម្មម៉ាស្សា ខារ៉ាអូខេ ផ្ទះសំណាក់ និងសណ្ឋាគារឲ្យរាយការណ៍និងចូលរួមធ្វើការទប់ស្កាត់ជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីមានការសង្ស័យពីការធ្វើសកម្មភាពទាក់ទង នឹងពេស្យាកម្មលើកុមារ និងរូបភាពអាសអាភាសលើកុមារ ។
- អគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ចំនួន ១២៣៧គូ និង សម្ភាសន៍ពរដ្ឋខ្មែរតែម្ខាងចំនួន ៥២៧នាក់ [27] ។
- ធ្វើសម្រង់ស្ថិតិនិងឲ្យម្ចាស់អាជីវកម្ម ដែលអាចពាក់ព័ន្ធនឹងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន១១៦១គោលដៅចុះកិច្ចសន្យា[28] ។
- ស្រង់ស្ថិតិភ្នាក់ងារ ជ្រើសរើសពលករខ្មែរធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសបានចំនួន៦០គោលដៅ។
- បង្ការទប់ស្កាត់សកម្មភាពប្រជាពលរដ្ឋខ្មែរ ធ្វើចំណាកស្រុកទៅរកការងារធ្វើនៅព្រះរាជាណាចក្រថៃបានចំនួន៣០៣នាក់ [29]។
- អគ្គស្នងការនគរបាលជាតិ បានបិទគោលដៅខារ៉ាអូខេបញ្ចាំងវីដេអូអាសអាភាសចំនួន ១៣គោលដៅ និងកម្ទេចចោលវីស៊ីឌីអាសអាភាសចំនួន២៣៤៥បន្ទះ[30]។

**១.៣ ការរៀបចំលិខិតបទដ្ឋានជាតិ**

ក្រោយពីបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងពិធិសារបន្ថែមនៃអនុសញ្ញានេះកម្ពុជា ក្នុងនាមជារដ្ឋហត្ថលេខីបានខិតខំពង្រឹងច្បាប់ជាតិនិងលិខិតបទដ្ឋាន

[26] ចំណុច១២នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[27] ចំណុច៣៥នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[28] ចំណុច៣៥នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[29] ចំណុច៣៥នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[30] ចំណុច៣៦នៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

ជាតិដែលមានស្រាប់ មិនតែប៉ុណ្ណោះថែមទាំងបានរៀបចំនិងបង្កើតនូវច្បាប់និងលិខិតបទដ្ឋានជាតិនានាបន្ថែមទៀតដែលក្នុងនោះរួមមាន:

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៣១ចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។
- ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដោយកំណត់ថា ច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមាររួមបញ្ចូលជាផ្នែកមួយនៃច្បាប់ជាតិ រួមទាំងច្បាប់ជាតិផងដែរ ដែលចៅក្រមត្រូវផ្អែកលើក្នុងការជំនុំជម្រះក្តី។
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈឆ្នាំ២០០៨ ក្នុងគោលបំណងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ម្យ៉ាងវិញទៀតដើម្បីការពារលើកកម្ពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អផូរផង់របស់ជាតិ ជាពិសេសដើម្បីអោយស្របទៅនឹងអនុសញ្ញា និងពិធីសារបន្ថែមនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ។
- ច្បាប់ស្តីពីទេសចរណ៍ត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ មានគោលបំណងកំណត់វិធាន និងយន្តការសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នរ/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌនីតិវិធី ទម្រង់បែបបទ និងអានុភាពនៃសុំកូនអន្តរប្រទេស ។
- គោលការណ៍ណែនាំលេខ ០០១ សណន បជរពត ចុះថ្ងៃ២៨ ខែតុលា ឆ្នាំ២០០៨ ស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីធានាអនុវត្តច្បាប់នេះឲ្យមានប្រសិទ្ធិភាព តម្លាភាព និងយុត្តិធម៌ ។
- អនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ ដែលកំណត់ពីការដាក់ពិន័យដល់ជនដែលបញ្ចាំង

កាត់ត ដំឡើងរូបភាព ថតចម្លង បញ្ចូលសម្លេង ជួល លក់និង ចែកចាយវីដេអូអាសអាភាស និង ការដាក់ពិន័យដល់ចារី និងសហចារី ដែលផលិតវីដេអូអាសអាភាស ។

- សេចក្តីសម្រេចលេខ១០ សសរ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្តនិងវីដេអូ ក្នុងព្រះរាជាណាចក្រកម្ពុជា។
- សេចក្តីណែនាំលេខ០១ ក.យ.ស.ណ.ន/០៩ ចុះថ្ងៃទី២៣ ខែកុម្ភៈឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ស្តីពីការអនុវត្តមាត្រា៤២"អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ" និង មាត្រា៤៣"អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ" ។
- ផែនការជាតិ៥ឆ្នាំ លើកទី១ត្រូវបានប្រកាសឲ្យប្រើដោយសេចក្តីប្រកាសលេខ០១ ស.ប្រ.ក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០ ស្តីពីវិធានការចាត់តាំងអនុវត្ត ផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរកុមារ និងកេងប្រវ័ញ្ចផ្លូវភេទកុមារ ។
- គោលនយោបាយនិងបទដ្ឋានអប្បរមាស្តីពី កិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្សលេខ០៦២ ស.អ.យ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ។
- សេចក្តីសម្រេចលេខ១០៧ ក.ជ.ក.ក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះ ដោយសារការជួញដូរ ដើម្បីជួយដល់កុមាររងគ្រោះដោយសារការជួញដូរឲ្យទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ទទួលបានសេវាសមស្របដែលធ្វើឲ្យពួកគេមានជីវិតរស់នៅប្រកបដោយភាពកក់ក្តៅ ទទួលបានការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈនិងធានាបាននូវនិរន្តភាពក្នុងជីវភាពរស់នៅ ហើយរួចផុតពីការបៀតបៀន និងការប្រមាថមើលងាយ ។
- អនុក្រឹត្យលេខ១៦២ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិដឹកនាំ ការបង្ក្រាបអំពើជួញដូរការរត់ពន្ធការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ។
- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៧១ ស.ស.រ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការរៀបចំក្រុមការងារកម្ពុជាប្រឆាំងនឹង អំពើជួញដូរមនុស្សនៅមហាអនុតំបន់ទន្លេមេគង្គហៅកាត់ថាក្រុមការងារខមមីតកម្ពុជា(Cambodia COMMIT Task Force) ។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានផ្តួចផ្តើម រៀបចំវិភាគច្បាប់ជាតិគោលនយោបាយលិខិតបទដ្ឋានដែលកំពុងនៅជាធរមាន និងសេចក្តីព្រាងច្បាប់ គោលនយោបាយដែលកំពុងរង់ចាំការអនុម័តផ្អែកតាមមូលដ្ឋានច្បាប់អន្តរជាតិ ដោយធ្វើការប្រៀបធៀបទៅ

នឹងច្បាប់ការពារកុមាររបស់ប្រទេសនានា ក្នុងគោលបំណងស្វែងរកភាពខ្វះខាត ដើម្បីកសាងច្បាប់ស្តីពីការការពារកុមារនៅក្នុង ប្រទេសកម្ពុជាឬដាក់ចេញជារបៀបវារៈគោលនយោបាយ ឬលិខិតបទដ្ឋាន ឬកំណែទម្រង់ច្បាប់ ឬលិខិតបទដ្ឋាន ។

- បន្ទាប់ពីផែនការជាតិ៥ឆ្នាំលើកទី១ស្តីពី ការប្រឆាំងការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ(ឆ្នាំ២០០០ដល់ឆ្នាំ២០០៨) បានអនុវត្តដោយជោគជ័យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកសាងសេចក្តីព្រាងផែនការជាតិទី២ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទដោយផ្តោតលើកម្មវិធីចំនួន៥ ។
- ពីឆ្នាំ២០០១ដល់ឆ្នាំ២០០៨ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដោយសហការជាមួយនឹងមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ បានបង្កើតកម្មវិធីបណ្តាញសុវត្ថិភាពការពារកុមារនៅតាមសហគមន៍ ។ កម្មវិធីនេះត្រូវបានអនុវត្តនៅក្នុងរាជធានីខេត្តចំនួន០៥ មានរាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ ស្វាយរៀង និងព្រៃវែង។កម្មវិធីនេះបានធ្វើឲ្យភ្នាក់ងារសង្គមកិច្ចអាជ្ញាធរដែនដី និង សហគមន៍បានធ្វើការរួមគ្នា ដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យថាបានប្រព្រឹត្តបទល្មើស ហើយតាមដានសកម្មភាពជនទាំងនោះ។ ទន្ទឹមនឹងនេះដែរ កុមារងាយរងគ្រោះមួយចំនួននៅតាមសហគមន៍ទទួលបានសេវាសង្គមកិច្ច ហើយមូលនិធិសង្គមកិច្ចត្រូវបានបង្កើតឡើងដើម្បីសង្គ្រោះបន្ទាន់នូវកុមារងាយរងគ្រោះ នៅក្នុងភូមិគោលដៅចំនួន៤០៨នៅក្នុងខេត្តស្វាយរៀងនិងព្រៃវែង [31]។

## ផ្នែកទី២ ការខិតខំប្រឹងប្រែង របស់អង្គការមិនមែនរដ្ឋាភិបាល

សង្គមស៊ីវិលបានចូលរួមវិភាគទានយ៉ាងច្រើន ចំពោះកិច្ចខិតខំដើម្បីលុបបំបាត់ការជួញដូរកុមារ ពេស្យាកម្មលើកុមារ និង រូបភាពអាសអាភាសលើកុមារ ។ សេវាផ្ទាល់ដូចជាសេវាស្តារនីតិសម្បទា សេវាសមាហរណកម្ម ការលើកកម្ពស់ការយល់ដឹង និងសេវាផ្នែកច្បាប់ជាអាទិ៍ត្រូវបានផ្តល់ឲ្យតាមរយៈអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ។ សេវាសំខាន់ៗដែលត្រូវបានផ្តល់ឲ្យរួមមាន[32]៖

[31] ចំណុចពពនៃរបាយការណ៍ការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពី ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

[32] ចំណុច២៥របាយការណ៍ជាតិលើកទី១ និងទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាសអាសអាភាសកុមារឆ្នាំ ២០០២ ដល់ឆ្នាំ២០១០។

### ២.១ ការចូលរួមចំណែកក្នុងការអប់រំផ្សព្វផ្សាយ

- អង្គការសង្គមស៊ីវិលបានធ្វើការអប់រំផ្សព្វផ្សាយពីសិទ្ធិកុមារ និង ពិធីសារបន្ថែមនៃអនុសញ្ញានេះដល់សហគមន៍
- ធ្វើការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មាន និងនគរបាលថ្នាក់រាជធានីខេត្តអំពីអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពីធិសារបន្ថែមនេះ
- ការផ្តល់សេវាពិគ្រោះយោបល់ដល់ជនរងគ្រោះ និងផ្តល់ថវិកាដើម្បីបង្កើតមុខរបរ និង បញ្ជូនទៅបណ្តុះបណ្តាលវិជ្ជាជីវៈទៅតាមស្ថានភាពសមស្រប ។
- រៀបចំទិវាប្រឆាំងការជួញដូរមនុស្សនៅថ្ងៃ១២ធ្នូ ជារៀងរាល់ឆ្នាំដើម្បីលើកកម្ពស់ការយល់ដឹងរបស់ពលរដ្ឋ និង លើកកម្ពស់ការចូលរួមទប់ស្កាត់បញ្ហាការជួញដូរមនុស្ស ។
- ការរៀបចំវេទិកាតុមូលតាមរយៈវិទ្យុ ទូរទស្សន៍ស្តីពីបញ្ហាការជួញដូរមនុស្សជាពិសេសកុមារ ។
- អង្គការទស្សនៈពិភពលោក(World Vision) គម្រោងអន្តរៈទីភ្នាក់ងារសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្ស(UNIAP) អង្គការមិត្តសំឡាញ់(Friend international)អង្គការអែដេទូស(Aide Détous)គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងការជួញដូរកុមារនៅកម្ពុជា(ECPAT)អង្គការពកម្មអន្តរជាតិ(ILO)អង្គការChild Wise Australia និងអង្គការផ្សេងទៀត បានសហការជាមួយគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍ ដើម្បីបង្កើតវគ្គបណ្តុះបណ្តាលកម្រិតថ្នាក់ជាតិថ្នាក់រាជធានី ខេត្តនិងមូលដ្ឋានជូនដល់មន្ត្រីរាជការ នគរបាល កងរាជអាវុធហត្ថ អាជ្ញាធរដែនដី និយោជិត និយោជក នៅតាមបណ្តាមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ជូននិស្សិត សិស្សសាលា គ្រូបង្រៀន និងមាតាបិតាសិស្សនៅតាមសហគមន៍ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងបានផ្សព្វផ្សាយដល់ឧស្សាហកម្មពាក់ព័ន្ធនឹងគោលនយោបាយទេសចរណ៍កម្ពុជា ។

### ២.២ ការចូលរួមចំណែកក្នុងការអន្តរាគមន៍

- ជម្រុញការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទតាមរយៈក្រសួងកិច្ចការនារី
- ធ្វើការការពារដោយសហការជាមួយនគរបាល ដើម្បីសង្គ្រោះនិងផ្តល់សេវាស្តារនីតិសម្បទាដល់កុមារ និងជនងាយរងគ្រោះ
- អង្គការពលកម្មអន្តរជាតិតាមរយៈគម្រោង មហាអនុតំបន់ទន្លេមេគង្គប្រឆាំងការជួញដូរស្ត្រីនិងកុមារបានសហការជាមួយរដ្ឋាភិបាល សមាគមនិយោជក សហជីព អង្គការ

សហប្រជាជាតិនិងអង្គការមិនមែនរដ្ឋាភិបាលក្នុង ទិសដៅលុបបំបាត់ការជួញដូរនិងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ

- អង្គការមូលនិធិអាស៊ីបានអនុវត្តកម្មវិធីប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន៤សមាសភាគគឺការទប់ស្កាត់ កិច្ចការពារ កិច្ចសម្របសម្រួល និងការផ្តន្ទាទោស ។
- ការផ្តល់សេវាផ្នែកច្បាប់ដោយផ្តល់ជាមេធាវីសម្រាប់ការពារដល់ជនរងគ្រោះ ។
- ធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារក្រីក្រក្នុងសហគមន៍មួយចំនួន ដើម្បីឲ្យពួកគេមានមុខរបរនិងដើម្បី កុំធ្លាក់ក្នុងភាពងាយរងគ្រោះនៃការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទ។
- ធ្វើការសម្របសម្រួលលើការគ្រប់គ្រងករណីក្នុងរាជធានីខេត្ត ។
- ការត្រួតពនិត្យតាមដានការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០៨ នៅទូទាំងប្រទេស ។
- អង្គការសង្គមស៊ីវិលបានសហការគ្នាក្នុងការចងក្រងទិន្នន័យរួមគ្នាស្តីពីការរំលោភ និងការជួញដូរផ្លូវភេទនៅព្រះរាជាណាចក្រកម្ពុជា ។

**២.៣ ការចូលរួមចំណែកក្នុងការការរៀបចំលិខិតបទដ្ឋានជាតិ**

- អង្គការមិនមែនរដ្ឋាភិបាលជាតិនិង អន្តរជាតិបានចូលរួមចំណែកនៅក្នុងដំណើររៀបចំសេចក្តីព្រាងច្បាប់នានាដែលពាក់ព័ន្ធនិងកុមារដូចជា ច្បាប់ស្តីពីយុត្តិធម៌អនីតិជន។
- ចូលរួមក្នុងក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ។
- ចូលរួមនៅក្នុងកិច្ចដំណើរការរៀបចំច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- ជាសមាជិកក្នុងក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ជាសមាជិកនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍យុវជនឆ្នាំ២០១៤-២០១៨

## ជំពូកទី៤ លិខិតបទដ្ឋានគតិយុត្ត

ជាសត្យានុម័តរាល់មនុស្សដែលរស់នៅក្នុងសង្គមមួយ មិនអាចវិវត្តន៍ទៅបានដោយគ្មានការការពារផ្នែកច្បាប់បាននោះឡើយ។ កត្តាទាំងនេះហើយការរស់នៅរបស់ពួកគេប្រកបទៅដោយចីរភាព តម្លាភាព សុខុមាលភាព និងសុវត្ថភាពក៏ព្រោះតែមានច្បាប់ដើម្បី ការពារពួកគេខណៈពេលដែលជនទាំងនោះទទួលរងការបំពាននានា ជាពិសេសគឺជនទន់ខ្សោយដែលមានកុមារជា

ឧទាហរណ៍។ ដោយមើលឃើញពីមូលហេតុទាំងនេះរាល់បណ្តាប្រទេសទាំងអស់លើសកលលោក តែងតែយកចិត្តទុកដាក់ចំពោះការបង្កើត ការធ្វើសេចក្តីព្រាង ការអនុម័ត និងការប្រកាសជាធរមាន នូវលិខិតបទដ្ឋានមួយចំនួនដូចជា សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា រដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាមួយចំនួនទៀតសម្រាប់គ្រប់គ្រង សណ្តាប់ធ្នាប់ និងដឹកនាំកោសិកាសង្គមបានល្អ។ តាមរយៈចក្ខុវិស័យបែបនេះយើងឃើញថា បណ្តាប្រទេសមួយចំនួនបានយកលិខិតបទដ្ឋានទាំងនោះទៅបញ្ចូលក្នុងច្បាប់ជាតិរបស់ខ្លួនសម្រាប់ដាក់ជាការប្រតិបត្តិ និងពិន័យករណីមានការបំពានចំពោះមនុស្សក្នុងប្រទេសជាតិរបស់ខ្លួននោះ។ ហេតុនេះចំពោះការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារយើងក៏ឃើញថាមានលិខិតបទដ្ឋានអន្តរជាតិ និងលិខិតបទដ្ឋានជាតិមួយចំនួនបានបញ្ញត្តិដើម្បីជាការគាំពារទៅលើកុមារ។ ជាលទ្ធផលដោយសារច្បាប់កម្ពុជាពុំទាន់មានភាពរឹងមាំនូវឡើយដោយសារមូលហេតុសង្គ្រាម និងរបបយង់ឃ្នងកម្ពុជាប្រជាធិបតេយ្យផងនោះ ហេតុនេះលិខិតច្បាប់មួយចំនួនធំត្រូវបានបំផ្លាញ ។ កត្តានេះហើយចំពោះការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារពុំទាន់មានច្បាប់សម្រាប់ការពារបានល្អនៅឡើយទេ ទើបបានជាកម្ពុជាបានចូលជាសមាជិកនិង ផ្តល់សច្ចាប័នទៅលើលិខិតបទដ្ឋានអន្តរជាតិ មួយចំនួនដើម្បីជាគ្រឹះសម្រាប់គាំពារកុមារទៅលើបញ្ហានេះ។

## ផ្នែកទី១ លិខិតុបករណ៍អន្តរជាតិ

ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារយើងឃើញថាមានលិខិតុបករណ៍អន្តរជាតិចំនួនពីរ ដែលបានយកចិត្តទុកដាក់ទៅលើការគាំពារបញ្ហានេះនោះគឺ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ។

### ១.១ អនុសញ្ញា

ចំពោះការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារគឺ មានអនុសញ្ញាស្តីពីសិទ្ធិកុមារដែលបានយកចិត្តទុកដាក់ ទៅលើបញ្ហានេះដោយព្រោះថា អនុសញ្ញាស្តីពីសិទ្ធិកុមារគឺជាសន្ធិសញ្ញាអន្តរជាតិ ដែលមានចែងពីបទដ្ឋានអប្បបរមាជាសកល និងពីគោលការណ៍សីលធម៌សម្រាប់ការប្រព្រឹត្តលើកុមារនៅក្នុងសង្គម។ អនុសញ្ញានេះ គឺជាសេចក្តីថ្លែងលំអិតមួយពីសិទ្ធិទាំងឡាយដែលកុមារគ្រប់ទិសទីត្រូវទទួលបាន ហើយរួមបញ្ចូលសិទ្ធិពលរដ្ឋ នយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ដែលពាក់ព័ន្ធនឹងកុមារ។

នៅក្នុងអតីតកាល កុមារត្រូវបានគេចាត់ទុកគ្រាន់តែជាអ្នករងអំពើ ឬកម្មវត្ថុដែលគេប្រព្រឹត្តទៅលើប៉ុណ្ណោះ។ ប៉ុន្តែឥលូវនេះ អនុសញ្ញាស្តីពីសិទ្ធិកុមារទទួលស្គាល់កុមារថាជាមនុស្សដែលមាន

សិទ្ធិរបស់គេផ្ទាល់គឺ ជាសិទ្ធិដែលគេទទួលបានអាស្រ័យដោយគេកើតជាមនុស្ស។ កុមារអាចទាមទារសិទ្ធិរបស់ខ្លួនពីអ្នកមានភារកិច្ចនានា ដូចជាឪពុក ម្តាយ និង រដ្ឋ ជាពិសេសមន្ត្រីនគរបាល និងតុលាការដែលមានភារកិច្ចគោរព ការពារ និងបំពេញតាមសិទ្ធិរបស់កុមារ។ដូចសិទ្ធិមនុស្សទាំងអស់ដែរ សិទ្ធិកុមារមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារមិនអាចបំបែកចេញពីគ្នាបានទេ។ នេះមានន័យថាសិទ្ធិទាំងអស់មានទំនាក់ទំនងគ្នា ហើយពុំមានសិទ្ធិណាសំខាន់ជាងសិទ្ធិណាឡើយ។ ទោះយ៉ាងណាក៏ដោយ អនុសញ្ញាស្តីពីសិទ្ធិកុមារ យកចិត្តទុកដាក់ចំពោះភាពខុសគ្នានៃវប្បធម៌ នយោបាយ និងស្ថានភាពពិតខាងផ្នែកសម្ភារៈក្នុងចំណោមរដ្ឋនានា។ អ្វីដែលត្រូវយកមកពិចារណាជាចំបងបំផុតនោះគឺ ឧត្តមប្រយោជន៍របស់កុមារ។[33] ជាពិសេសគោលបំណងនៃការបង្កើតអនុសញ្ញាស្តីពីសិទ្ធិកុមារ គឺបង្កើតជាបទដ្ឋានសម្រាប់ការពារកុមារប្រឆាំងនឹងការទុកចោលមិនយកចិត្តទុកដាក់ ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការរើសអើងដែលខ្លួនជួបប្រទះ ក្នុងកម្រិតផ្សេងៗ ជារៀងរាល់ថ្ងៃនៅគ្រប់ប្រទេស។[34] មួយវិញនោះគោលបំណង នៃការបង្កើតអនុសញ្ញាស្តីពីសិទ្ធិកុមារនេះគឺចង់ឲ្យមានការចែង និងការអនុវត្តឲ្យមានជាក់លាក់នូវសិទ្ធិទាំងបួនរបស់កុមារ ។ តែដោយឡែកចំពោះការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសទៅលើកុមារគឺ ចង់ទាមទារឲ្យមានការចែង និងអនុវត្តឲ្យមានខ្ជាប់ខ្ជួនពីសំណាក់រដ្ឋជាភាគី នូវសិទ្ធិទទួលបានការការពារ ដោយចង់មានន័យថាសិទ្ធិមួយនេះត្រូវតែពង្រីកវិសាលភាពរបស់វា ដើម្បីការការពារកុមារឲ្យរួចផុតអំពើនិងការប្រព្រឹត្តផ្សេងៗដែលបង្កអន្តរាយដល់កុមារ។ យោងទៅលើការបង្កើតអនុសញ្ញាស្តីពីសិទ្ធិកុមារនេះចង់ឲ្យ កុមាររួចផុតពីការកេងប្រវ័ញ្ច និង ការធ្វើទុកបុកម្នេញនានា ដែលនាំឲ្យកុមាររងគ្រោះជួបនឹងជីវិតអាប់អួរ ។ ពិសេសនោះគឺរាល់អំពើនានាដែលពាក់ព័ន្ធនឹងផ្លូវភេទរបស់កុមារ។[35]

អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបាន អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ គឺជាថ្ងៃដែលប្រារព្ធដោយសហប្រជាជាតិធ្វើជាទិវាកុមារសកល។ ហើយកម្ពុជាបានចូលជារដ្ឋភាគី នៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២។ តាមរយៈការចូលជាភាគីនេះ ព្រះរាជាណាចក្រកម្ពុជា ប្តេជ្ញាខ្លួនការពារ និងបំពេញតាមសិទ្ធិនានារបស់កុមារទាំងអស់នៅកម្ពុជា។

បើយោងទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារយើងឃើញថា មានមាត្រានៃអនុសញ្ញាមួយចំនួនបានឆ្លុះបញ្ចាំងឲ្យឃើញពីការការពារកុមារ ពីការធ្វើពេស្យាកម្មនិងរូបភាពអាសអាភាសលើកុមារ។ អ្វីដែលគួរឲ្យកត់សម្គាល់មាត្រាខ្លះមិនបានចង្អុលបង្ហាញឲ្យច្បាស់ជាក់លាក់នោះទេ តែវាក៏អាច

[33] ទំព័រ៧នៃអនុសញ្ញាអង្គការសហ្រប្រជាជាតិស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមឆ្នាំ១៩៨៩

[34] ទំព័រ៨ នៃអនុសញ្ញាអង្គការសហ្រប្រជាជាតិស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមឆ្នាំ១៩៨៩

[35] ទំព័រ១០នៃអនុសញ្ញាអង្គការសហ្រប្រជាជាតិស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមឆ្នាំ១៩៨៩

លើកយកមកធ្វើជាមូលដ្ឋានដើម្បីជាការការពារដល់កុមារផងដែរ។ ដោយសារហេតុតែព្រះរាជាណាចក្រកម្ពុជាពុំសូវមានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ដើម្បីដោះស្រាយលើបញ្ហានេះ វាជាការល្អប្រសើរដែលកម្ពុជាជារដ្ឋភាគីនៃអនុសញ្ញានេះ ទើបកម្ពុជាអាចលើកយកអនុសញ្ញានេះមកបកស្រាយបានករណីច្បាប់របស់ជាតិខ្លួនពុំអាចដោះស្រាយបាន។ ចំពោះការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារ បើយោងលើអនុសញ្ញានេះមានមាត្រាដូចតទៅះ

មាត្រា១ សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ។ មាត្រានេះចង់បង្ហាញឲ្យបានច្បាស់ អំពីអាយុដែលកំណត់ថាជាកុមារនោះ គឺមិនឲ្យលើសពី១៨ឆ្នាំឡើយ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយច្បាប់ផ្សេងៗទៀត។

មាត្រា១១ រដ្ឋជាភាគីត្រូវចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការផ្ទេរកុមារចេញក្រៅប្រទេសដោយខុសច្បាប់ និងការមិនប្រគល់កុមារពីក្រៅប្រទេសមកវិញ។ ក្នុងទិសដៅនេះ រដ្ឋភាគីត្រូវសម្រួលដល់ការចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ឬចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងដែលមានស្រាប់។ ត្រង់មាត្រានេះចង់សំដៅទៅលើការប្រឆាំង នឹងកុមារតាមរយៈការនាំកុមារចេញ ទៅក្រៅប្រទេសដោយមិនដើរតាមនីតិវិធី ឬ ខុសច្បាប់ និងការមិនប្រគល់កុមារពីក្រៅមកវិញ។ ការនាំចេញ និងការមិនប្រគល់មកវិញនេះមិនមែនមកពីដើមហេតុនៃការជួញដូរប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាដើមហេតុដែលយក ឬរក្សាទុកកុមារនោះដើម្បីយកធ្វើជាកម្មវត្ថុនៃការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។ ដោយមើលឃើញពីបញ្ហានេះ ទើបបានជារដ្ឋជាភាគីត្រូវតែសម្រួល ដល់ការចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីនិង អាចសុំចូលជាសមាជិកដល់កិច្ចព្រមព្រៀងដែលមានស្រាប់ដើម្បីកុំឲ្យមានអំពើអសកម្ម និងភាពខុសច្បាប់បន្តទៀត។ ត្រង់ចំណុចនេះហើយដែលកម្ពុជាបានអនុម័ត និងប្រកាសឲ្យប្រើនូវច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ដោយក្នុងច្បាប់នោះគឺមានបញ្ញត្តិយ៉ាងច្បាស់ពីការសុំកូនដើម្បីយកកូននោះទៅរស់នៅក្រៅមាតុភូមិប្រទេស។ ដោយក្នុងច្បាប់នោះកម្ពុជាបានប្បញ្ញត្តិយ៉ាងល្អិតល្អន់ពីនីតិវិធីនៃការសុំដោយគោរពទៅតាមច្បាប់កម្ពុជា។

មាត្រា២១ រដ្ឋភាគីដែលទទួលស្គាល់ និង/ឬអនុញ្ញាតឲ្យមានប្រព័ន្ធសុំកូន ត្រូវធានាថា ឧត្តមប្រយោជន៍របស់កុមារត្រូវស្ថិតក្នុងការពិចារណាខ្ពស់បំផុត ក្នុងវិស័យនេះ ហើយរដ្ឋភាគីត្រូវ ៖

(ក) ធានាថា សុំកូនអនុញ្ញាតបានតែដោយអាជ្ញាធរមានសមត្ថកិច្ចជាអ្នកសម្រេច ស្របតាមច្បាប់ និងនីតិវិធីជាធរមាន និងផ្អែកលើមូលដ្ឋានព័ត៌មានពាក់ព័ន្ធ និងគួរជឿទុកចិត្តទាក់ទងនឹងករណីនេះ និងធានាថា សុំកូនអាចអនុញ្ញាតឲ្យធ្វើដោយគិតពីស្ថានភាពកុមារទាក់ទងនឹងឪពុក ម្តាយ ញាតិសន្តាន ឬអ្នកអាណាព្យាបាលស្របច្បាប់ និងបើចាំបាច់ ត្រូវធានាថា ជនពាក់ព័ន្ធបានដឹង និងបាន

ផ្តល់ការយល់ព្រម បន្ទាប់ពីបានទទួលដំណឹងពីផលប៉ះពាល់នានាចំពោះសុំកូន ដោយផ្អែកលើការផ្តល់ការពិគ្រោះយោបល់ តាមការចាំបាច់។

(ខ) ទទួលស្គាល់ថា សុំកូនអន្តរប្រទេស អាចចាត់ទុកជាមធ្យោបាយជំនួសមួយនៃការថែទាំកុមារបាន បើសិនជានៅក្នុងប្រទេសដើមកំណើតរបស់ខ្លួន កុមារមិនអាចរស់នៅតាមគ្រួសារធម៌ ឬក្នុងគ្រួសារចិញ្ចឹម ឬមិនអាចទទួលបាននូវការថែទាំឲ្យសមស្របនោះទេ។

(គ) ធានាថា កុមារពាក់ព័ន្ធនឹងកូនសុំអន្តរប្រទេស បានទទួលការធានានិងបទដ្ឋានដូចគ្នានឹងការធានា និងបទដ្ឋានដែលមានស្រាប់ក្នុងករណីសុំកូនក្នុងប្រទេស។

(ឃ) ចាត់វិធានការសមស្របនានាដើម្បីធានាក្នុងករណីសុំកូនអន្តរប្រទេសថា ការផ្តល់កូននេះពុំបណ្តាលឲ្យផលចំណេញផ្នែកហិរញ្ញវត្ថុ ដោយមិនត្រឹមត្រូវដល់រាល់បុគ្គលដែលមានការទាក់ទិនក្នុងរឿងនេះឡើយ។

(ង) ត្រូវលើកស្ទួយទិសដៅនៃមាត្រានេះតាមការធ្វើកិច្ចសម្រុះសម្រួល ឬចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី តាមករណីនីមួយៗ និងប្រឹងប្រែងក្នុងក្របខ័ណ្ឌនេះ ដើម្បីធានាថា ការទុកដាក់នៅក្រៅប្រទេសនេះ ត្រូវបានអនុវត្តដោយអាជ្ញាធរ ឬអង្គការមានសមត្ថកិច្ច។

តាមរយៈមាត្រានេះ គឺចង់បង្ហាញថាដើម្បីកិច្ចគាំពារពីការធ្វើពេស្យាកម្ម និង រូបភាពអាសអាភាសនោះ ត្រូវតែអនុវត្តឲ្យបានតឹងរឹងបំផុត ចំពោះការអនុវត្តនៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឲ្យមានប្រសិទ្ធិភាពបំផុត ដោយក្នុងនោះយោងតាមមាត្រា២១នេះ គឺមានតែអាជ្ញាអរមានសមត្ថកិច្ចដែលអាចកំណត់ឲ្យមានការអនុញ្ញាតពីការសុំកូន បង្ហាញឲ្យឃើញពីអត្ថប្រយោជន៍ដែលកុមារអាចទទួលបានដែលកើតចេញពីការសុំកូនអន្តរប្រទេស ការការពារកុមារដែលក្លាយជាកម្មវត្ថុនៃកូនសុំដោយយោងទៅលើបទដ្ឋានអន្តរជាតិ និងបទដ្ឋានជាតិ ការចាត់វិធានការពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចករណីកូនសុំមិនគោរពតាមនីតិវិធី ពិសេសគឺការអនុវត្តមាត្រានេះឲ្យមានប្រសិទ្ធិភាពបំផុតពីអាជ្ញាធរ ឬអង្គការមានសមត្ថកិច្ច។ ពិសេសអាជ្ញាធរ ឬអង្គការមានសមត្ថកិច្ចត្រូវយកចិត្តទុកដាក់ឲ្យបានខ្ពស់បំផុតពីការសុំកូន ដាច់ខាតយ៉ាងណាកុំឲ្យយកកុមារទៅធ្វើជាកម្មវត្ថុនៃការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។

មាត្រា៣២ កថាខណ្ឌទី១ រដ្ឋភាគី ទទួលស្គាល់សិទ្ធិការពារកុមារ ប្រឆាំងការកេងប្រវ័ញ្ចសេដ្ឋកិច្ច និងការឲ្យធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬដែលអាចប៉ះពាល់ដល់ការសិក្សារបស់កុមារ ឬដែលអាចបំផ្លាញសុខភាព ឬការអភិវឌ្ឍន៍រាងកាយ សតិបញ្ញា ស្មារតីសីលធម៌ឬសង្គមរបស់កុមារ។ យោងទៅលើមាត្រាមួយនេះ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារគឺ ចង់ឆ្លុះបញ្ចាំងឲ្យឃើញពីការការពារកុមារទៅលើការកេងប្រវ័ញ្ចនានា តែទៅលើមាត្រាមួយនេះគឺបង្ហាញពីការកេងប្រវ័ញ្ចខាងផ្នែកសេដ្ឋ

កិច្ចតាមរយៈការធ្វើឲ្យការងារ ដែលគ្រោះថ្នាក់បំផុតដោយប៉ះពាល់ទៅនឹងការសិក្សា សុខភាព និងរាល់ការលូតលាស់ផ្សេងៗនៃសារពាង្គកាយកុមារ។ ហើយតាមរយៈមាត្រានេះការងារដែលកុមារត្រូវធ្វើនោះគឺវាក៏អាចជាការងារដែលពាក់ព័ន្ធទៅនឹងផ្លូវភេទរបស់កុមារនោះផងដែរ។ ដោយការងារនោះវាអាចយកកុមារឲ្យធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសដែលវានាំឲ្យប៉ះពាល់ដល់ការអភិវឌ្ឍន៍រាងកាយ សតិ បញ្ញា ស្មារតី សីលធម៌ និង សង្គមរបស់កុមារ។ កាលណាកុមារក្លាយទៅជាកម្មវត្ថុនៃពេស្យាកម្ម និងរូបភាពអាសអាភាស នោះហើយដែលជាហេតុឲ្យកុមារនោះបាត់បង់នូវការលូតលាស់ ទាំងខាងផ្នែករាងកាយ និងខាងផ្នែកផ្លូវចិត្ត។

មាត្រា៣៣ រដ្ឋភាគីត្រូវចាត់វិធានការសមស្រប រួមបញ្ចូលទាំងវិធានការខាងផ្លូវច្បាប់ រដ្ឋបាលសង្គម និងការអប់រំ ដើម្បីការពារកុមារឲ្យផុតពីការប្រើប្រាស់ខុសច្បាប់នូវថ្នាំញៀន និងសារជាតិសណ្តំស្មារតី ដូចមានកំណត់ក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធ និងដើម្បីទប់ស្កាត់ការប្រើប្រាស់កុមារក្នុងការផលិត និងការជួញដូរខុសច្បាប់នូវសារជាតិទាំងនេះ។ ចំពោះមាត្រានេះគឺចង់ឲ្យមានការចូលរួមពីសំណាក់រដ្ឋជាភាគី ទាំងអស់ត្រូវតែខិតខំប្រឹងប្រែងក្នុងការចាត់វិធានការសមស្រប ទាំងខាងផ្លូវច្បាប់ និងផ្លូវរដ្ឋបាលសង្គម និងជាពិសេសគឺអប់រំដល់កុមារ អាណាព្យាបាល អ្នកដែលមានប្រយោជន៍ពាក់ព័ន្ធនឹងកុមារត្រូវតែយកចិត្តទុកដាក់ឲ្យបានខ្ពស់ចំពោះបញ្ហាគ្រឿងញៀន និងសារជាតិសណ្តំផ្សេងៗ ។ ពិសេសកុំឲ្យកុមារទទួលរងនូវសារជាតិទាំងអស់នេះ ព្រោះថាសារជាតិទាំងអស់នេះក៏ជាដើមហេតុដែលនាំឲ្យកុមារនោះទទួលរងនូវការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសផងដែរ។ ដោយហេតុនេះដើម្បីកាត់បន្ថយ និងលុបបំបាត់រាល់ការធ្វើពេស្យាកម្ម និង រូបភាពអាសអាភាសត្រូវតែលុបបំបាត់បញ្ហាគ្រឿងញៀន និងសារជាតិសណ្តំនានាលើកុមារ។

មាត្រា៣៤ រដ្ឋភាគី រ៉ាប់រងការពារកុមារ ឲ្យផុតពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និង ការរំលោភបំពានផ្លូវភេទ។ ក្នុងទិសដៅនេះ រដ្ឋភាគី ជាពិសេស ត្រូវចាត់វិធានការសមស្របនានា ក្នុងក្របខ័ណ្ឌជាតិ ក្របខ័ណ្ឌទ្វេភាគី និងពហុភាគីដើម្បីទប់ស្កាត់:

(ក) ការប្រើប្រាស់កុមារក្នុងពេស្យាកម្មកេងប្រវ័ញ្ច ឬប្រព្រឹត្តដោយខុសច្បាប់ខាងផ្លូវភេទផ្សេងទៀត។

(ខ) ការប្រើប្រាស់កុមារដោយកេងប្រវ័ញ្ច នៅក្នុងការសម្តែងអាសអាភាស និងផលិតសម្ភារៈ ឬរូបភាពអាសអាភាស។

ចំពោះមាត្រានេះគឺមានការលើកទឹកចិត្តដល់រដ្ឋភាគី អោយបង្កើនការយកចិត្តទុកដាក់ក្នុងការពារកុមារពីគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងការប្រើប្រាស់កុមារ ជាកម្មវត្ថុក្នុងទាញយកប្រយោជន៍ខាងផ្លូវភេទ និងការរំលោភបំពានផ្លូវភេទផងដែរ ដោយការប្រើប្រាស់កុមារក្នុងរូបភាពកេងប្រវ័ញ្ច ឬ

សម្ដែងជារូបភាពដែលក្នុងន័យពាក់ព័ន្ធផ្លូវភេទ ឬផលិតជាសម្ភារៈ ឬក៏សម្ដែងដើម្បីថតជារូបភាពអាសអាភាស។

មាត្រា៣៥ រដ្ឋភាគី ត្រូវចាត់វិធានការសមស្របក្នុងក្របខ័ណ្ឌជាតិ ទ្វេភាគី និងពហុភាគី ដើម្បីទប់ស្កាត់ការចាប់ពង្រត់ ការលក់ ឬការជួញដូរកុមារ ទោះក្នុងគោលបំណងអ្វី ឬ ទម្រង់ណាក៏ដោយ។ ក្នុងមាត្រាចង់លើកទឹកចិត្តឲ្យរដ្ឋជាភាគីត្រូវតែចាត់វិធានការសមស្របតាមរយៈមធ្យោបាយផ្សេងៗ ទោះបីក្នុងក្របខ័ណ្ឌជាតិក្ដី ទ្វេភាគី និងពហុភាគីក្ដី គឺចង់ទប់ស្កាត់កុំឲ្យមានការចាប់ពង្រត់យកកុមារធ្វើជាឧបករណ៍នៃការលក់ ឬការជួញដូរដោយក្នុងគោលបំណង ឬទម្រង់ណាក៏ដោយ។ ជាពិសេសនោះគឺ ការប្រើប្រាស់កុមារដើម្បីនឹងយកទៅធ្វើជាការប្រព្រឹត្តចំពោះពេស្យាកម្ម និងរូបភាពអាសអាភាស។

មាត្រា៣៦ រដ្ឋភាគីត្រូវការពារកុមារប្រឆាំងនឹងទម្រង់ ផ្សេងទៀតទាំងអស់នៃការកេងប្រវ័ញ្ចដែលប៉ះពាល់ដល់គ្រប់ទិដ្ឋភាពណាមួយនៃសុខុមាលភាពរបស់កុមារ។ ហេតុនេះក្នុងរដ្ឋជាភាគីនៃអនុសញ្ញាត្រូវការពាររាល់ការប្រឆាំងកុមារទាក់ទងនឹងការកេងប្រវ័ញ្ចលើកុមារទាំងអស់ ដែលវាជាហេតុនាំឲ្យប៉ះពាល់ដល់សុខុមាលភាពរបស់កុមារ។ ដូចនេះកម្ពុជាក៏ជារដ្ឋភាគីនៃអនុសញ្ញានេះផងដែរត្រូវការពារកុមារឲ្យបានល្អ ពីការកេងប្រវ័ញ្ចខាងផ្លូវភេទ ដើម្បីឲ្យកុមារអភិវឌ្ឍខ្លួនបានល្អ។ ពិសេស គឺការការពារទៅនឹងការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារ។

### **១.២ ពិធីសារបន្ថែម**

ពិធីសារបន្ថែម គឺជាឯកសារបន្ថែមលើសន្និសញ្ញាគោលដែលរដ្ឋនីមួយៗអាចជ្រើសរើសដើម្បីចូលជាសមាជិកប្រសិនបើរដ្ឋនោះ យល់ព្រមទទួលកាតព្វកិច្ចបន្ថែមតាមពិធីសារនោះដោយមិនគិតដល់អនុសញ្ញាដើមឡើយ។ [36]អនុសញ្ញាស្ដីពីសិទ្ធិកុមារ មានពិធីសារបន្ថែមចំនួនពីរ ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីខែឧសភា ឆ្នាំ២០០០ដូចគ្នា។ ចំពោះពិធីសារបន្ថែមពីរនោះគឺមានពិធីសារមួយសំដៅទៅលើការប្រឆាំងនឹងការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារហើយកម្ពុជាបានក្លាយជារដ្ឋភាគីនៃពិធីសារបន្ថែមនេះនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០២។ គោលបំណងដែលនាំឲ្យបង្កើតពិធីសារបន្ថែមមួយនេះគឺដើម្បីឲ្យសម្រេចនូវគោលបំណងនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារឲ្យកាន់តែបានច្រើន ពង្រីកវិធានការ គឺជាការសមស្របនឹងការសន្យារបស់រដ្ឋជាភាគី ដើម្បីធានា ការការពារកុមារប្រឆាំងនឹងការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសកុមារ។ មួយវិញទៀតពិធីសារនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រាប់នឹងការពារកុមារពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស

[36] ទំព័រ ១១ និង ១២នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងពិធីសារបន្ថែមឆ្នាំ១៩៨៩

តែម្តងដោយសារតែរដ្ឋដែលជាភាគីមានកង្វល់យ៉ាងខ្លាំង ចំពោះកំណើនកើនឡើងគួរឲ្យកត់សម្គាល់នៃការជួញដូរកុមារជាអន្តរជាតិ ដើម្បីពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ។ មួយវិញទៀតសោតក៏ព្រោះតែភាពងាយរកបានច្រើនយ៉ាងឡើងនៃរូបភាពអាសអាភាសកុមារតាមប្រព័ន្ធអ៊ីនធឺណែត និង បច្ចេកវិទ្យាផ្សេងទៀតដែលកំពុងវិវត្តហេតុនេះទើបជាហេតុនាំឲ្យបង្កើតពិធីសារបន្ថែមមួយនេះ ដើម្បីជាការការពារកុមារពីការធ្វើពេស្យាកម្ម និង រូបភាពអាសអាភាស។[37]

លើសពីនេះក៏ព្រោះតែមានការបារម្ភយ៉ាងជ្រាលជ្រៅ ចំពោះការអនុវត្តយ៉ាងរីករាលដាល និងជាបន្តនៃទេសចរណ៍ផ្លូវភេទ ដែលកុមារងាយរងគ្រោះច្រើនជាងគេដោយហេតុថា ទេសចរណ៍ផ្លូវភេទជំរុញដោយផ្ទាល់ ឲ្យមានការធ្វើពេស្យាកម្មកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសលើកុមារ។ ហើយតាមរយៈពិធីសារមួយនេះក៏មានការជឿជាក់ផងដែរថា រាល់ទម្រង់នៃការធ្វើពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ នឹងត្រូវបានសម្រួល តាមរយៈការអនុម័តយកវិធីសាស្ត្រចម្រុះផ្នែកព្រមគ្នា ដោយដោះស្រាយកត្តារួមចំណែក មានជាអាទិ៍ ភាពអន់ថយ ភាពក្រីក្រ គម្លាតខាងសេដ្ឋកិច្ច រចនាសម្ព័ន្ធខាងសង្គម និងសេដ្ឋកិច្ច ដែលមានវិសមធម៌ ភាពមិនប្រក្រតីនៃគ្រួសារ កង្វះខាតខាងការអប់រំ ការផ្លាស់ទីលំនៅពីជនបទមកទីក្រុងការរើសអើងភេទការប្រព្រឹត្តខាងផ្លូវភេទរបស់មនុស្សពេញវ័យដែលគ្មានការទទួលខុសត្រូវការអនុវត្តជាទម្លាប់ប្រកបដោយគ្រោះថ្នាក់។

ពិធីសារមួយនេះបង្កើតឡើងហើយក៏មានការជឿជាក់ផងដែរថា ការខិតខំលើកកំពស់ការយល់ដឹងជាសាធារណៈគឺជាការចាំបាច់ ដើម្បីកាត់បន្ថយតម្រូវការអតិថិជន ចំពោះការធ្វើពេស្យាកម្មលើកុមារ និងរូបភាពអាសអាភាសឬសម្ភារៈអាសអាភាសលើកុមារ និងមានជំនឿលើសារៈសំខាន់នៃការពង្រឹងភាពជាដៃគូនៅទូទាំងពិភពលោក ជាមួយតួអង្គទាំងអស់ និងការលើកកម្ពស់ការអនុវត្តច្បាប់ជាតិ។ ដោយសារកម្ពុជាជាភាគីនៃពិធីសារនេះផងដែរនោះកម្ពុជាត្រូវចាត់វិធានការ និងរៀបចំជាលិខិតបទដ្ឋានថ្នាក់ជាតិយ៉ាងណាការពារកុមារឲ្យរួចផុតពីការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ។[38]

តាមរយៈពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារបានបញ្ញត្តិយ៉ាងជាក់លាក់អំពីគោលបំណងនៃការបង្កើតពិធីសារបន្ថែមនេះ ឆ្លុះបញ្ចាំងឲ្យយល់ពីនិយមន័យនៃពេស្យាកម្ម និងរូបភាពឬសម្ភារៈ

[37] ទំព័រ ៦៥ និង ៦៦ នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារឆ្នាំ២០០២

[38] ទំព័រ៦៦ និង៦៧នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារឆ្នាំ២០០២

អាសអាភាសកុមារ បញ្ជាក់ឲ្យយល់ច្បាស់ពីសកម្មភាពដែលចាត់ទុកថាជាការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសកុមារ។[39] អ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺក្នុងពិធីសារបន្ថែមមួយនេះបានប្បញ្ញត្តិ និងលើកទឹកចិត្តដល់រដ្ឋជាភាគីនៃពិធីសារបន្ថែមត្រូវតែចាត់វិធានការឲ្យបានសមស្របនិងរៀបចំយុត្តាធិការរបស់ខ្លួនឲ្យបានល្អប្រសើរបំផុត ករណីដែលមានបទល្មើសបានកើតឡើងពីសកម្មភាពដែលចាត់ទុកថាវាជាការធ្វើពេស្យាកម្ម និងរូបភាព ឬសម្ភារៈអាសអាភាសលើកុមារ។ ហើយរដ្ឋជាភាគីនៃពិធីសារបន្ថែមត្រូវចាត់វិធានការផងដែរករណីដែលជនល្មើសបានប្រព្រឹត្តបទល្មើសមានទីលំនៅស្ថិតនៅរដ្ឋដែលខ្លួនបានប្រព្រឹត្តបទល្មើសនោះ ហើយរដ្ឋនោះមិនបត្យាប័ននៃបទល្មើសនោះឡើយ ដោយព្រោះថាវាជាការគ្រប់គ្រាន់ដែលរដ្ឋនោះអាចចាត់វិធានការលើការគ្រប់គ្រងទៅលើបទល្មើសនោះបាន។[40]

ដោយឡែកក្នុងពិធីសារបន្ថែមមួយនេះក៏បានឆ្លុះបញ្ចាំងផងដែរថាករណីមានការប្រព្រឹត្តបទល្មើសមួយដែរពាក់ព័ន្ធនឹងការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ បានលុះត្រាតែរដ្ឋជាភាគីបានចុះកិច្ចសន្យារវាងរដ្ឋជាភាគីស្របតាមលក្ខខណ្ឌប្បញ្ញត្តិក្នុងសន្ធិសញ្ញាដែរចាត់ចូលជាបទល្មើសអាចធ្វើបត្យាប័ន។បើរដ្ឋភាគីដែលធ្វើ បត្យាប័នកំណត់តាមអត្ថិភាពនៃសន្ធិសញ្ញាមួយ បានទទួលការស្នើសុំបត្យាប័នពីរដ្ឋភាគីមួយទៀតដែលមិនមានសន្ធិសញ្ញាបត្យាប័នជាមួយគ្នារដ្ឋនោះ អាចចាត់ទុកពិធីសារនេះ ជាមូលដ្ឋានគតិយុត្តសម្រាប់ធ្វើបត្យាប័នចំពោះបទល្មើសនោះ។

ការធ្វើបត្យាប័ន ត្រូវស្ថិតក្រោមលក្ខខណ្ឌប្បញ្ញត្តិដែរកំណត់ដោយច្បាប់របស់រដ្ឋដែរទទួលពាក្យសុំ។ ដោយឡែករដ្ឋភាគីដែលមិនធ្វើបត្យាប័នកំណត់តាមអត្ថិភាពនៃសន្ធិសញ្ញាណាមួយត្រូវទទួលស្គាល់បទល្មើសទាំងនោះ ជាពិសេសបទល្មើសដែលអាចធ្វើបត្យាប័នរវាងរដ្ឋភាគី អាស្រ័យតាមលក្ខខណ្ឌប្បញ្ញត្តិដែលកំណត់ដោយច្បាប់របស់រដ្ឋដែលទទួលពាក្យសុំ។

ករណីធ្វើបត្យាប័នរវាងរដ្ឋជាភាគី បទល្មើសដែលទាក់ទងនឹងការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ ជាបទល្មើសទាំងអស់ដែរចាត់ទុកថាប្រព្រឹត្តមិនត្រឹមតែនៅកន្លែងកើតបទល្មើសនោះទេ ប៉ុន្តែនៅក្នុងទឹកដីរបស់រដ្ឋ ដែលបានកំណត់ជាយុត្តាធិការនៃរដ្ឋទាំងនោះ ហើយបើករណីមានការស្នើសុំឲ្យ មានការធ្វើបត្យាប័នចំពោះបទល្មើសពាក់ព័ន្ធ នឹងការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ តែរដ្ឋភាគីដែលទទួលការស្នើសុំនោះមិនព្រមធ្វើបត្យាប័នឬនឹងមិនធ្វើបត្យាប័ន ដោយមកពីសញ្ជាតិរបស់ចារីនៃបទល្មើស រដ្ឋនោះត្រូវចាត់វិធានការ

[39] មាត្រា២ និងមាត្រា៣នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ

[40] មាត្រា៤នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ

សមស្រប ដើម្បីប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់។[41] បន្ទាប់ពីមានការបញ្ជាក់ពីនីតិវិធីនៃការធ្វើ ឬមិនធ្វើបត្យាប័ននៃបទល្មើសដោយយោងលើវិធាននៃច្បាប់ជាតិ និងអន្តរជាតិក្នុងនោះពិធីសារបន្ថែមស្តីពី អនុសញ្ញាសិទ្ធិកុមារពាក់ព័ន្ធនឹងការជួញដូរកុមារ ពេស្យាកម្មកុមារ និង រូបភាពឬសម្ភារៈអាសអាភាសកុមារក៏បានបង្ហាញឲ្យឃើញពីការខិតខំជួយគ្នាទៅវិញទៅមកឲ្យបានទូលំទូលាយបំផុតទាក់ទងនឹងការស៊ើបអង្កេត ឬនីតិវិធីខាងព្រហ្មទណ្ឌ ឬ នីតិវិធីធ្វើបត្យាប័នចំពោះបទល្មើសដែរបានកំណត់ក្នុងកថាខណ្ឌទី១ មាត្រា៣នៃពិធីសារបន្ថែម រួមមានទាំងការជួយផ្តល់ភស្តុតាងដែលខ្លួនមាន និងដែលចាំបាច់សម្រាប់ដំណើរការរឿងក្តី។

លើសពីនេះទៀតនោះចំពោះការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារបើយោងទៅលើពិធីសារបន្ថែមនេះក៏មានបញ្ញត្តិបង្ហាញឲ្យឃើញ ពីវិសាលភាពនៃច្បាប់ជាតិរបស់រដ្ឋមួយនៃពិធីសារបន្ថែម ទៅលើដែនដីដែលជាទីកន្លែងនៃ ការប្រព្រឹត្តិបទល្មើសរបស់រដ្ឋមួយផ្សេងទៀត (មាត្រា៧)។[42] ទន្ទឹមនឹងនេះពិធីសារបន្ថែមក៏មានបង្ហាញឲ្យឃើញពីចូលរួមរបស់រដ្ឋជាភាគី ត្រូវតែចាត់វិធានការសមស្របដើម្បីការពារសិទ្ធិកុមារ ដែលត្រូវបានហាមឃាត់ក្នុងពិធីសារបន្ថែមនេះ។

ក្នុងនោះត្រូវទទួលស្គាល់ភាពងាយរងគ្រោះនៃកុមាររងគ្រោះ និង ការសម្របសម្រួលនីតិវិធីដើម្បីទទួលស្គាល់តម្រូវការពិសេសរបស់កុមារ ការប្រាប់កុមាររងគ្រោះអំពីសិទ្ធិ តួនាទីរបស់ពួកគេ និងវិសាលភាព កាលវិភាគ និងការវិវត្តទៅមុខនៃនីតិវិធី និងអំពីចំណាត់ការរឿងក្តីរបស់កុមារនោះ កាអនុញ្ញាតឲ្យមានការបង្ហាញ និងការពិចារណាអំពីទស្សនៈ សេចក្តីត្រូវការ និងកង្វល់របស់កុមាររងគ្រោះ ក្នុងនីតិវិធីដែលប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់កុមារ ផ្តល់សេវាកម្មសមស្របដល់កុមាររងគ្រោះក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីខាងផ្លូវច្បាប់ការពារជីវិតឯកជននិងអត្តសញ្ញាណរបស់កុមាររងគ្រោះ និងចាត់វិធានការស្របតាមច្បាប់ជាតិ ជៀសវាងការផ្សព្វផ្សាយព័ត៌មានមិនសមស្របដែលនាំឲ្យស្គាល់អត្តសញ្ញាណរបស់កុមារ ផ្តល់សុវត្ថភាពដល់កុមាររងគ្រោះ ព្រមទាំងគ្រួសារ និងសាក្សីរបស់កុមាររងគ្រោះ លើសពីនេះត្រូវចាត់វិធានការឲ្យបានលឿនបំផុត ក្នុងករណីមានបទល្មើសកើតឡើង ពិសេសជៀសវាងការយឺតយ៉ាវដោយមិនចាំបាច់ ក្នុងចំណាត់ការរឿងក្តី និងការអនុវត្តដីការ ឬសេចក្តីសម្រេចផ្តល់សំណងចំពោះកុមាររងគ្រោះ។ រដ្ឋជាភាគីត្រូវធានា មន្ទិលសង្ស័យអំពីអាយុពិតរបស់ជនរងគ្រោះមិនរារាំងដល់ការផ្តើមស៊ើបអង្កេតព្រហ្មទណ្ឌ រួមទាំងការស៊ើបអង្កេត ដើម្បីកំណត់អាយុជនរងគ្រោះឡើយ ។

[41] មាត្រា៥មាត្រា៨នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារឆ្នាំ២០០២

[42] មាត្រា៦ កថាខណ្ឌទី១ និងមាត្រា ៧នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារឆ្នាំ២០០២

ចំណុចនេះគឺ មានការលើកឡើងពីបញ្ហាអាយុរបស់កុមារតាមច្បាប់របស់រដ្ឋនីមួយៗដែលជាភាគី។

លើសពីនេះរដ្ឋជាភាគីត្រូវចាត់វិធានការ ដើម្បីធានាពីការប្រតិបត្តិប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកុមារដែលរងគ្រោះនៃបទល្មើស ធ្វើការបណ្តុះបណ្តាលសមស្របជាពិសេស ការបណ្តុះបណ្តាលផ្នែកច្បាប់ និងចិត្តសាស្ត្រដល់ជនទាំងឡាយដែលធ្វើការជាមួយជនរងគ្រោះពីបទល្មើសដែលហាមឃាត់ក្នុងពិធីសារនេះ។ពិសេសនោះរដ្ឋជាភាគីត្រូវអនុម័តវិធានការ ដើម្បីការពារសុវត្ថិភាព និងបូរណភាពរបស់ជនទាំងឡាយ និងអង្គការដែលពាក់ព័ន្ធក្នុងការងារបង្ការ និងការការពារ និងស្តារនីតិសម្បទាជនរងគ្រោះនៃបទល្មើសទាំងនេះ។[43]រដ្ឋជាភាគីត្រូវអនុម័ត ឬ ពង្រឹងការអនុវត្ត និងផ្សព្វផ្សាយច្បាប់ វិធានការរដ្ឋបាល នយោបាយ និងកម្មវិធីសង្គម ដើម្បីបង្ការបទល្មើសដូចមានចែងក្នុងពិធីសារបន្ថែមនេះ។ ត្រង់ចំណុចនេះកម្ពុជាក៏ត្រូវចាត់វិធានការដូចនេះដើម្បីលុបបំបាត់ការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារផងដែរព្រោះថាកម្ពុជាក៏ជាភាគីនៃពិធីសារបន្ថែមនេះ។ រដ្ឋត្រូវផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់ការការពារកុមារដែលរងគ្រោះបំផុត។ រដ្ឋជាភាគីត្រូវលើកកំពស់ការយល់ដឹង ដល់សាធារណជនទាំងអស់រួមមានកុមារផងដែរតាមរយៈការផ្សព្វផ្សាយព័ត៌មាន តាមគ្រប់មធ្យោបាយសមស្រប ការអប់រំ និងការបណ្តុះបណ្តាលវិធានការបង្ការ និងអំពីឥទ្ធិពលប្រកបដោយគ្រោះថ្នាក់នៃបទល្មើសដែលមានចែងក្នុងពិធីសារនេះ។ រដ្ឋជាភាគីត្រូវចាត់វិធានការដែលអាចធ្វើទៅបាន ដោយធានាឲ្យមានជំនួយសមស្របដល់កុមាររងគ្រោះនៃបទល្មើស រួមមានការធ្វើសមាហរណកម្មពេញលេញនៃជនទាំងនោះទៅក្នុងសង្គម និងការស្តារសម្បទាខាងរាងកាយ និងផ្លូវចិត្តនៃកុមារទាំងនោះផង។

រដ្ឋជាភាគីត្រូវធានាគ្រប់កុមារដែររងគ្រោះនៃបទល្មើសដោយពិធីសារនេះ មានសិទ្ធិទទួលបាននីតិវិធីគ្រប់គ្រាន់ ដោយមិនមានការរើសអើង ដើម្បីទទួលបានសំណងការខូចខាតពីជនទាំងឡាយដែលទទួលខុសតាមផ្លូវច្បាប់។ ម៉្យាងរដ្ឋជាភាគីនៃពិធីសារនេះ ត្រូវចាត់វិធានការ សំដៅហាមឃាត់ប្រកបដោយប្រសិទ្ធិភាពនូវការផលិត និងផ្សព្វផ្សាយសម្ភារៈដែលផ្សាយពាណិជ្ជកម្មពីបទល្មើសនៃពិធីសារបន្ថែមនេះ។[44] រដ្ឋជាភាគីត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមការព្រមព្រៀងពហុភាគី ថ្នាក់តំបន់ និងទ្វេភាគីដើម្បីបង្ការ ស្វែងរកស៊ើបអង្កេត ចោទប្រកាន់ និង ផ្តន្ទាទោសជនដែលទទួលខុសត្រូវចំពោះអំពើពាក់ព័ន្ធ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។ រដ្ឋភាគីត្រូវលើកស្ទួយផងដែរនូវសហប្រតិបត្តិការ និងការ

[43] មាត្រា៨ នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារឆ្នាំ២០០២

[44] មាត្រា៩នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារឆ្នាំ២០០២

សម្របសម្រួលអន្តរជាតិ រវាងអាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអង្គការអន្តរជាតិ។ រដ្ឋភាគីត្រូវលើកស្ទួយសហប្រតិបត្តិការអន្តរជាតិ ដើម្បីជួយកុមាររងគ្រោះក្នុងការស្តារសម្បទាខាងផ្លូវកាយ និងផ្លូវចិត្ត ការធ្វើសមាហរណកម្មទៅក្នុងសង្គម និង ការធ្វើមាតុភូមិនិវត្តន៍។ រដ្ឋភាគីត្រូវពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយមូលហេតុជាឫសគល់ដូចជាភាពក្រីក្រ និងភាពអន់ថយ ដែលរួមចំណែកឲ្យកុមារងាយរងគ្រោះ ពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។ រដ្ឋភាគីដែរមានលទ្ធភាពធ្វើទៅបាន ត្រូវផ្តល់ជំនួយហិរញ្ញវត្ថុ បច្ចេកទេស ឬជំនួយផ្សេងទៀត តាមរយៈកម្មវិធីពហុភាគី ថ្នាក់តំបន់ទ្វេភាគីឬកម្មវិធីផ្សេងទៀតដែលអាចមាន។[45]

### ផ្នែកទី២ បរិបទច្បាប់ជាតិ

ទន្ទឹមនឹងមានលិខិតុបករណ៍មួយចំនួនដែលបានប្បញ្ញត្តិ ទាក់ទងនឹងការការពារកុមារពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសក៏ដោយ ដោយឡែកប្រទេសកម្ពុជាក៏ឃើញមានច្បាប់មួយចំនួនដែលបានប្បញ្ញត្តិឡើងដើម្បីនឹងធ្វើការយកចិត្តទុកដាក់ និងដើម្បីធ្វើការការពាររកយុត្តិធម៌ជូនចំពោះកុមារដែលបានរងគ្រោះដោយសារការធ្វើពេស្យាកម្ម និងកុមារដែលបានក្លាយទៅជាកម្មវត្ថុនៃរូបភាពអាសអាភាស។

#### ២.១ ច្បាប់ជាតិ

ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ដែលបានប្បញ្ញត្តិឡើង សម្រាប់ការការពារដល់កុមាររងគ្រោះពីការធ្វើពេស្យាកម្ម និង រូបភាពអាសអាភាសមានច្បាប់ ៖

**រដ្ឋធម្មនុញ្ញ**

នៅក្នុងច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា យើងឃើញមានមាត្រាចំនួនពីរដែលបានប្បញ្ញត្តិយ៉ាងច្បាស់ជាក់លាក់ស្តីពីការការពារកុមារពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។ម្យ៉ាងទៀតមាត្រាចំនួនពីរនោះក៏បានបញ្ជាក់យ៉ាងច្បាស់ពីការគោរពសិទ្ធិរបស់កុមារ ការធានារក្សាការពារសិទ្ធិកុមារ ពិសេសគឺការគាំពារប្រឆាំងទៅនឹងអាជីវកម្ម សេដ្ឋកិច្ច និងកាមគុណលើកុមារដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាពឬសុខុមាលភាពរបស់កុមារ។

មាត្រា៣១ " ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងការគោរពសិទ្ធិមនុស្សដូចដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឲ្យ

[45] មាត្រា១០នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ

ឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តិតាម លក្ខខណ្ឌកំណត់ក្នុងច្បាប់"។

មាត្រា៤៨ " រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការសិក្សារៀនសូត្រ សិទ្ធិត្រូវទទួលបានការគាំពារក្នុង ស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋ គាំពារប្រឆាំងនឹងការងារទាំងឡាយណា ដែលនាំឲ្យខូចខាតដល់ការអប់រំ និងការរៀនសូត្ររបស់ កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ"។

**ក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា**

ដោយយោងទៅលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ពី វិធានស្តីពីសុំកូនធម្មតា និងសុំកូនពេញលេញនៅក្នុងប្រទេស។ សុំកូនពេញលេញសំដៅដល់សុំកូន ដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ជាឪពុកម្តាយនិងកូនរវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមនិងកូនសុំ ដើម្បីបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើតឬ អាណាព្យាបាលសម្រាប់អនីតិជនរបស់ខ្លួន។ ចំពោះសុំកូនធម្មតាញាតិភាពរវាងកូននិងឪពុកម្តាយ បង្កើតត្រូវបន្តអត្ថិភាព ហើយកូនសុំនិងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក មានសិទ្ធិទាមទារនិងករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។[46] មួយវិញទៀតមូលហេតុដែលនាំឲ្យ មានវត្តមាននៃរបបសុំកូននៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជាក្នុងគោលបំណង ក្រៅពីទំនាក់ទំនងបុត្តភាព តាមបែបធម្មជាតិ ក្រមរដ្ឋប្បវេណីក៏ទទួលស្គាល់ទំនាក់ទំនងបុត្តភាពតាមរយៈកូនសុំ។

គោលបំណងនៃការបង្កើតឲ្យមានប្រព័ន្ធសុំកូន ដើម្បីបង្កើតសន្តតិជននៃទ្រព្យសម្បត្តិរបស់ គ្រួសារឪពុកម្តាយចិញ្ចឹម ហេតុនេះតាមរយៈសុំកូនគេអាចទទួលបាននូវសន្តតិជនដែលជាអ្នកបន្ត សន្តតិកម្មរបស់ឪពុកម្តាយចិញ្ចឹម។ សុំកូនក៏មានគោលបំណងបង្កើតអ្នកមានកំលាំងការងារ និង មើលថែរក្សាគ្រួសារឪពុកម្តាយចិញ្ចឹមដែរ ហេតុនេះតាមរយៈសុំកូន ឪពុកម្តាយចិញ្ចឹមដែលពុំមាន កូន អាចទទួលបានកូន ដើម្បីទទួលបានការមើលថែទាំពីកូន។ លើសពីនេះទៅទៀតនោះ សុំកូន មានគោលបំណងបង្កើតឲ្យមានឪពុកម្តាយ ក្នុងការថែរក្សាកូនជាគោលបំណងដែលគិតគូរដល់ផល ប្រយោជន៍របស់កុមារដែលពុំមានការថែរក្សាដោយសមរម្យពីឪពុកម្តាយបង្កើត។ គោលបំណង ទាំងបីនេះត្រូវបានលើកយកមក វិនិច្ឆ័យក្នុងការសុំកូន ប៉ុន្តែគោលបំណងដែលមានអាទិភាពជាងគេ

[46] មាត្រា១០០៧ និងមាត្រា១០២៦នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

គឺផលប្រយោជន៍របស់កូនសុំ ហេតុនេះក្រមរដ្ឋប្បវេណី ក្រៅពីបញ្ញត្តិជាមូលដ្ឋាននៃលក្ខខណ្ឌក្នុងការបង្កើតកូនសុំ ក៏មានបញ្ញត្តិជាមូលដ្ឋានដែលជាគោលការណ៍ទូទៅក្នុងការបង្កើតសុំកូនដូចមានចែងនៅក្នុងមាត្រា១០១២ ១០២៣ និង១០២៤។ បើមើលទៅលើគោលបំណងនៃរបបសុំកូនហាក់ដូចជាមិនមានការជាប់ពាក់ព័ន្ធនឹងការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារនោះឡើយ ចុះមូលហេតុអ្វីបានជាក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាមានបញ្ញត្តិអំពីរបបសុំកូន ដោយយើងអះអាងថាវាជាប់ពាក់ព័ន្ធនឹងការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារ នោះគឺដោយសាររបបសុំកូនមានគោលបំណងបញ្ជាក់យ៉ាងច្បាស់ពីរបបសុំកូននេះគឺដើម្បីផលប្រយោជន៍របស់កុមារ(អនីតិជន) នៃរបបសុំកូននោះ។ ប៉ុន្តែមូលហេតុបញ្ញត្តិនេះជាប់ពាក់ព័ន្ធនឹងការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសនោះដោយសារយើងយល់ថាតាមរយៈរបបសុំកូន កូនសុំនោះត្រូវបានអ្នកសុំមិនបានគោរពទៅតាមគោលបំណងនិងកម្មវត្ថុនៃរបបសុំកូនទៅតាមនីតិវិធីច្បាប់ តែបែរជាយកកុមារ(អនីតិជន)ពីរបបសុំកូននោះទៅធ្វើជាកម្មវត្ថុនៃការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសទៅវិញ។

**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ**

ច្បាប់នេះមានគោលបំណងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បង្កើននូវសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងរក្សាការពារ លើកកម្ពស់នូវទំនៀមទំលាប់ប្រពៃណីល្អរបស់ជាតិ។ តាមរយៈច្បាប់នេះក៏បានកំណត់ពីនិយមន័យច្បាស់លាស់ពីការកេងប្រវ័ញ្ចក្នុងនោះពេស្យាកម្មជនដទៃ រូបភាពឬសម្ភារៈអាសអាភាសក៏ជាប្រភេទមួយនៃការកេងប្រវ័ញ្ចផងដែរ។គួរកត់សម្គាល់ជនដទៃក្នុងន័យនេះក៏សំដៅទៅលើអនីតិជន(កុមារ)ផងដែរ។ ច្បាប់នេះក៏បានកំណត់ពីការប្រព្រឹត្តដោយមិនស្របច្បាប់ទៅលើកុមារ (អនីតិជន) ដែលមានដូចជា៖

**ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ**

ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទដូចមានការធ្វើពេស្យាកម្ម និងផលិតរូបភាពអាសអាភាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ២០(ម្ភៃ)ឆ្នាំ។

**ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច**

ការជ្រើសរើសដោយមិនស្របច្បាប់មានន័យថា ការបញ្ចុះបញ្ចូលការជួលឬការឲ្យជនណាមួយបម្រើការក្រោមទម្រង់ នៃការកេងប្រវ័ញ្ចផ្សេងទៀត តាមមធ្យោបាយបង្ខិតបង្ខំផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំទៅ២០(ម្ភៃ)ឆ្នាំ។

**អំពើលក់ដូរមនុស្សដោយមានគោលដៅ**

ជនណាដែលលក់ ដូរជនដទៃដោយមានគោលដៅស្វែងរកប្រយោជន៍ ដោយយកជនទាំងនោះទៅធ្វើជាកម្មវត្ថុនៃការឈ្លានពានខាងផ្លូវភេទ និងផលិតរូបភាពអាសអាភាសក៏ត្រូវផ្តន្ទាទោសពី១៥(ដប់ប្រាំ)ឆ្នាំទៅ២០(ម្ភៃ)ឆ្នាំ។[47]

លើសពីនេះទៅទៀតនោះនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទបានប្បញ្ញត្តិថា ៖

**បទប្បញ្ញត្តិព្រហ្មទណ្ឌទាក់ទងនឹងការធ្វើពេស្យាកម្មកុមារដែលមានកំណត់នៅក្នុងច្បាប់នេះ**

ការធ្វើពេស្យាកម្មលើកុមារ ត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាស្តីពីការបង្ក្រាប់អំពើការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ការធ្វើពេស្យាកម្មលើកុមារនៅក្នុងច្បាប់នេះមានន័យថាជាអំពើរួមភេទ ឬ អំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទរវាងអនីតិជនជាមួយជនដទៃដើម្បីផ្តោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ។ បទប្បញ្ញត្តិទាក់ទងនឹងពេស្យាកម្មកុមារមានជាអាទិ៍៖

មាត្រា៣៣ ចែងថា" ជនណាប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងមាត្រា៣០(ការដឹកនាំពេស្យាចារ) មាត្រា៣១(ការដឹកនាំគ្រឹះស្ថានពេស្យាចារ) និងមាត្រា៣២(ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ)នៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី៧ (ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើបទល្មើសដែលបានប្រព្រឹត្តនោះទាក់ទងនឹងពេស្យាចារកុមារ"។

មាត្រា៣៥ ចែងថា " ជនណាអូសទាញជនដទៃសម្រាប់អំពើពេស្យាចារកុមារឬផ្សាយពាណិជ្ជកម្មពីអំពើពេស្យាចារកុមារ ក្នុងគោលបំណងធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី២ (ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០ ( បួនលាន) រៀល ដល់ ១០ ០០០ ០០០ (ដប់លាន)រៀល។ ជនណាប្រព្រឹត្តបទល្មើសខាងលើធ្វើជាមុខរបរត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំ"។

មាត្រា៣៦ ចែងថា"ជនណាឲ្យជនដទៃខ្ចីប្រាក់ឬ វត្ថុមានតម្លៃអ្វីមួយដោយភ្ជាប់ទៅនឹលក្ខខណ្ឌដែលតម្រូវឲ្យអនីតិជនប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ។ ជនណាឲ្យអនីតិជនខ្ចីប្រាក់ឬវត្ថុមានតម្លៃអ្វីមួយដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឲ្យអនីតិជននោះប្រកបរបរពេស្យាចារត្រូវផ្តន្ទាទោសដូចគ្នា នឹងកថាខណ្ឌទី១នៃមាត្រានេះ"។

មាត្រា៣៧ ចែងថា"ជនណាធ្វើកិច្ចសន្យាជាមួយជនដទៃដែលក្នុងកិច្ចសន្យានោះតម្រូវឲ្យនីតិជនប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ៥(ប្រាំ)ឆ្នាំ ដល់ ១០(ដប់)ឆ្នាំ។ ជនណា

[47] ទំព័រ ១០៣ ដល់ ១០៥ នៃកម្រងច្បាប់ គោលនយោបាយ និងមុខងារពាក់ព័ន្ធនឹងការការពារកុមារ

ធ្វើកិច្ចសន្យាជាមួយអនីតិជន ដែលក្នុងកិច្ចសន្យានោះតម្រូវឲ្យអនីតិជនប្រកបរបរពេស្យាចារត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ នៃមាត្រានេះ"។

**បទប្បញ្ញត្តិព្រហ្មទណ្ឌទាក់ទងនឹងរូបភាពអាសអាភាសកុមារដែល កំណត់នៅក្នុងច្បាប់នេះ៖**

មាត្រា៤១ ចែងថា" ជនណាចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាពនិងសម្ភារៈអាសអាភាសកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី២ (ពីរ)ឆ្នាំ ទៅ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ដល់ ១០ ០០០ ០០០ (ដប់លាន) រៀល ។ ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើត្រូវផ្តន្ទាទោសដូចគ្នា។ ជនណាផលិតរូបភាពអាសអាភាស នៃកុមារក្នុងគោលបំណងយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី១០ (ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ។[48]

**ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា**

ក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ បានកំណត់បទប្បញ្ញត្តិព្រហ្មទណ្ឌដែលគ្របដណ្តប់លើគ្រប់អំពើ ឬសកម្មភាពជាក់លាក់ដែលបានរៀបរាប់នៅក្នុងវាក្យខណ្ឌទី១ នៃមាត្រា៣នៃពិធីសារនេះ។ បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះរួមមាន៖

មាត្រា៣២១ ចែងថា" អំពើរបស់បុគ្គលមានអំណាចថែរក្សា ដែលបោះបង់អនីតិជនអាយុតិចជាង១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី១ (មួយ)ឆ្នាំ ទៅ៥ (ប្រាំ)ឆ្នាំ និង ពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល ប្រសិនបើអំពើបោះបង់នោះនាំឲ្យអន្តរាយដល់សុខភាព ឬសន្តិសុខរបស់អនីតិជននោះ។

មាត្រា៣២៦ ចែងថា "អំពើប្រព្រឹត្តដោយគំនិតទុច្ចរិត មិនព្រមប្រគល់អនីតិជនទៅឲ្យបុគ្គលដែលមានសិទ្ធិទាមទារនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី១(មួយ)ខែទៅ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន) រៀល ទៅ ២ ០០០ ០០០(ពីរលាន)រៀល។

មាត្រា៣២៧ ចែងថា "អំពើដកហូតអនីតិជនដោយផ្ទុយនឹងច្បាប់ ពីបុគ្គលមួយដែលថែរក្សាស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០(ពីរលាន)រៀល។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន)រៀល ទៅ ៦ ០០០

[48] ទំព័រ ៣០និង ទំព័រ ៤៣ នៃរបាយការណ៍ជាតិលើកទី១និងលើកទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់ឆ្នាំ២០១០

០០០( ប្រាំមួយលាន)រៀល ប្រសិនបើអនីតិជនត្រូវបានរក្សាទុកនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា"។

មាត្រា៣៣០ ចែងថា "អំពើនៅក្នុងគោលដៅចង់បានប្រាក់កម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬដល់ឪពុក ឬដល់ម្តាយឲ្យបោះបង់ទារកដែលកើតមកហើយឬដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី១ (មួយ)ខែ ទៅ៦ (ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ១ ០០០ ០០០ (មួយលាន)រៀល"។

មាត្រា៣៣១ ចែងថា "អំពើនៅក្នុងគោលដៅចង់បានប្រាក់កម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមនិងឪពុកម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ១ ០០០ ០០០(មួយលាន)រៀល"។

មាត្រា៣៣២ ចែងថា "អំពើនៅក្នុងគោលបំណងចង់បានកម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមនិង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះឲ្យទៅអ្នកសុំ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ១ ០០០ ០០០(មួយលាន) រៀល"។

មាត្រា៣៣៣ ចែងថា "អំពើដែលយកទារកមួយជំនួសទារកមួយទៀត ក្លែងឬលាក់កំបាំងអត្តិភាពនៃទារក កាលបើអំពើនេះនាំឲ្យមានការក្លែងបន្លំអត្រានុកូលដ្ឋាន ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ២ ០០០ ០០០(ពីរលាន)រៀល"។

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានកំណត់ពីបទល្មើសនៃការធ្វើពេស្យាកម្ម។ បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះរួមមាន៖

មាត្រា២៨៥ ចែងថា "អំពើធ្វើជាអន្តរការីរវាងបុរស ឬស្ត្រីពេស្យា ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល"។

មាត្រា២៨៦ ចែងថា " ចំពោះបុគ្គលដែលមិនអាចបញ្ជាក់អំពីប្រភពធនធានរបស់ខ្លួន ដោយរស់នៅជាមួយជនដែលធ្វើសកម្មភាពពេស្យាចារជាប្រចាំ ឬ ដោយសារមានទំនាក់ទំនងជាទម្លាប់ជាមួយជនម្នាក់ឬ ច្រើននាក់ដែលធ្វើសកម្មភាពពេស្យាចារត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល"។

មាត្រា២៨៧ ចែងថា " អំពើរារាំងដល់ការបង្ការការជួយឬការអប់រំជាថ្មី ដោយសេវាសាធារណៈ ឬ ដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីអនុគ្រោះដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារឬកំពុងមានគ្រោះថ្នាក់ដោយការធ្វើពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ព ន្ធធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន)រៀល"។

មាត្រា២៩១ ចែងថា "អំពើគ្រប់គ្រង ធ្វើអាជីវកម្ម ដឹកនាំ ធ្វើឲ្យដំណើរការ ឬចេញប្រាក់ឲ្យគ្រឹះស្ថានពេស្យាចារដោយផ្ទាល់ ឬតាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និង ពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន)រៀល ទៅ ១០ ០០០ ០០០ ( ដប់លាន) រៀល"។

មាត្រា២៩២ ចែងថា "ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន)រៀល អំពើអ្នកគ្រប់គ្រងធ្វើអាជីវកម្ម ដឹកនាំ ឬធ្វើឲ្យដំណើរការនូវគ្រឹះស្ថានណាមួយដែលបើកចំហដល់សាធារណជនដោយផ្ទាល់ឬតាមរយៈអន្តរការី ដែលបានយល់ព្រមឬ បានអនុគ្រោះឲ្យបុគ្គលណាម្នាក់ប្រព្រឹត្តជាប្រចាំនូវពេស្យាចារនៅក្នុងគ្រឹះស្ថានឬនៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន និងឲ្យបុគ្គលណាម្នាក់រកជាប្រចាំនូវភ្ញៀវដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថានឬនៅក្នុងឧបសម្ពន្ធរបស់គ្រឹះស្ថាន"។

មាត្រា២៩៣ "ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី២(ពីរ) ឆ្នាំទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន)រៀល ចំពោះបុគ្គលដែលលក់ ឬដាក់ឲ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែងដែលមិនមែនប្រើប្រាស់ដោយសាធារណជន ដោយដឹងជាក់ច្បាស់ថាបុគ្គលនោះនឹងប្រើប្រាស់ទីកន្លែងនោះសម្រាប់ធ្វើសកម្មភាពពេស្យាចារ"។

**ច្បាប់ស្តីពីសុំកូនអន្តរប្រទេស**

ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ប្បញ្ញត្តិហាមឃាត់នូវអំពើ ដែលមានចែងក្នុងមាត្រា៣៣០ មាត្រា៣៣១ និងមាត្រា៣៣២នៃក្រមព្រហ្មទណ្ឌខាងលើ។ ក្រសួងទទួលបន្ទុកសង្គមកិច្ច អាចព្យួរឬដកហូតការទទួលស្គាល់ ឬបដិសេធការទទួលស្គាល់ទីភ្នាក់ងារអន្តរជាតិសុំកូនអន្តរប្រទេសសារជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឲ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេសរំលោភបំពានបទប្បញ្ញត្តិនៃមាត្រាទាំងបីនេះ។ ចំពោះច្បាប់ស្តីពីសុំកូនអន្តរប្រទេសមានវិសាលភាពលើការសុំកុមារមានសញ្ជាតិខ្មែរ ដែលមានទីលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធដែលមានទីលំនៅឋានអចិន្ត្រៃយ៍ នៅក្នុងប្រទេសណាមួយផ្សេងទៀតដើម្បីយកទៅចិញ្ចឹមជាកូន

ដែលទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ។ ហេតុដែលច្បាប់ស្តីពីសុំកូនអន្តរប្រទេសជាប់ពាក់ព័ន្ធនឹងការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសទៅលើកុមារនោះក៏ព្រោះថាពេលខ្លះកុមារទៅរស់នៅក្នុងគ្រួសារថ្មីមួយដោយបញ្ចប់ ញាតិជាមួយគ្រួសារចាស់តាមរយៈរបបសុំកូនអន្តរប្រទេស ។

ដោយឡែកកុមារនោះមិនបានក្លាយទៅជាកម្មវត្ថុដ៏ពិតប្រាកដនៃរបបមួយនោះតែ បែរជាក្លាយទៅជាកម្មវត្ថុនៃការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសទៅវិញ។ ដោយមើលឃើញពីរូបភាពអសកម្មរបៀបនេះ ទើបបានជាព្រះរាជាណាចក្រកម្ពុជាអនុម័តច្បាប់ស្តីពីសុំកូនអន្តរប្រទេសដើម្បីជាការការពារដល់ឧត្តមប្រយោជន៍នៃកុមាររងគ្រោះទាំងអស់ពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។ បើយោងទៅលើច្បាប់ស្តីពីសុំកូនអន្តរប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជាយើងឃើញបានប្បញ្ញត្តិពីគោលការណ៍ទូទៅ លក្ខខណ្ឌសុំកូន តួនាទីរបស់អាជ្ញាធរនៅក្នុងការសុំកូន និងនីតិវិធីនៃរបបសុំកូនអន្តរប្រទេសផងដែរ។

ដោយឡែកយើងមិនបានសង្កត់ធ្ងន់ទៅលើនីតិវិធីនៃការសុំកូនអន្តរប្រទេស ដោយយោងទៅលើច្បាប់មួយនេះនោះទេ យើងគ្រាន់តែចង់បង្ហាញពាក់ព័ន្ធ នឹងគោលការទូទៅ លក្ខខណ្ឌនៃសុំកូន និងតួនាទីរបស់អាជ្ញាធរនៅក្នុងការសុំកូនប៉ុណ្ណោះ ដោយវាពាក់ព័ន្ធនឹងឧត្តមភាពនៃកុមារតាមរយៈការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។ ទោះបីជាវាមិនអាចជួយបំពេញជាលក្ខខណ្ឌគ្រប់គ្រាន់តែវាក៏អាចជាយានដើម្បីឲ្យព្រះរាជាណាចក្រកម្ពុជាអាចនឹងមានច្បាប់គ្រប់គ្រាន់ក្នុង ការការពារកុមារពាក់ព័ន្ធនឹងការធ្វើពេស្យាចារនិងរូបភាពអាសអាភាស។ យោងទៅលើច្បាប់ស្តីពីសុំកូនអន្តរប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជាមានគោលការណ៍ទូទៅ លក្ខខណ្ឌ និងតួនាទីរបស់អាជ្ញាធរនៃរបបសុំកូនដូចតទៅៈ

**គោលការណ៍ទូទៅនៃរបបសុំកូនអន្តរប្រទេស**

**ដំណោះស្រាយក្នុងគ្រួសារ និងក្នុងប្រទេស**

កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រលាញ់ និងការយោគយល់ ដើម្បីឲ្យមានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន។ សុំកូនអន្តរប្រទេស អនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឲ្យកុមាររស់នៅគ្រួសារកំណើត និង ក្រោយពីបានពិចារណាអំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ការមិនរើសអើង ឧត្តមប្រយោជន៍ និងការគោរពទស្សនៈកុមារ**

កុមារទាំងឡាយដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាពឬ

ស្ថានភាពផ្សេងទៀតរបស់កុមារ ឬរបស់ឪពុកម្តាយ ឬរបស់ឪពុក ឬរបស់ម្តាយ ឬរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។ រាល់ការសម្រេច និងសកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេសត្រូវគិតគូរឲ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ។ តុលាការ និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេសត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថកិច្ចអាចដឹងខុសត្រូវ ត្រូវបានពិគ្រោះយោបល់ និងពន្យល់ណែនាំឲ្យបានត្រឹមត្រូវអំពីអានុភាពនានាដែលកើតចេញពីសុំកូន នេះដោយគិតគូរដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារដើម្បីឧត្តមប្រយោជន៍របស់កុមារ។

**គោលដៅមិនគិតកម្រៃ**

ហាមការធ្វើអាជីវកម្ម ឬធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស។ អាជីវកម្ម ឬសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមានដូចជា អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬឪពុក ឬម្តាយឲ្យបោះបង់ទារកដែលកើតមកហើយ ឬដែលនឹងកើត ដើម្បីឲ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស ។ អំពើក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងឪពុក ឬម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹងកើត។ អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឲ្យអ្នកសុំ។

**ការហាមឃាត់ការទទួលហិរញ្ញវត្ថុដោយខុសច្បាប់**

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឲ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និងត្រូវបង្ការមិនឲ្យមានការចាប់ពង្រត់ ការលក់ និងការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស។ មានតែប្រាក់ចំណាយសោហ៊ុយ និងវិភាគទាន ដែលកំណត់ដោយប្បញ្ញត្តិនៃច្បាប់នេះត្រូវបង់។ អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់ជួយឧបត្ថម្ភដល់ជម្រើសនានានៃការថែទាំជំនួស និងការជួយឧបត្ថម្ភទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ មិនត្រូវយកថ្លៃសោហ៊ុយសុំកូនពីអ្នកសុំកូន ឬភ្នាក់ងាររបស់អ្នកសុំកូន។ សោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗនឹងត្រូវបញ្ជូនទៅមជ្ឈមណ្ឌលកុមារកំព្រា។ មិនអនុញ្ញាតឲ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬទៅតាមសោហ៊ុយ

ស្មុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅមណ្ឌលកុមារកំព្រាណាមួយ ឬមិនអនុញ្ញាតឲ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្ដល់សោហ៊ុយ អំណោយ ឬការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយឲ្យទៅមណ្ឌលកុមារកំព្រាដែលកុមារនៅទៅនោះត្រូវបានសុំយកទៅចិញ្ចឹម ឬទៅឲ្យបុគ្គលិកនាយក ឬ សមាជិកនៃគណៈគ្រប់គ្រង ទោះជាដោយផ្ទាល់ ឬដោយប្រយោលក្ដី។[49]

**លក្ខខណ្ឌសម្រាប់ស្មុំកូនអន្តរប្រទេស**

**លក្ខខណ្ឌគ្រិះសម្រាប់កុមារដែលជាកម្មវត្ថុនៃស្មុំកូនអន្តរប្រទេស**

- កុមារដែលមានសញ្ជាតិខ្មែរ។
- កុមារដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។
- កុមារត្រូវតែមានអាយុកំណត់ដូចខាងក្រោម គិតត្រឹមថ្ងៃទទួលពាក្យសុំរបស់អ្នកសុំដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដោយជាទូទៅ កុមារដែលត្រូវសុំត្រូវមានអាយុក្រោម៨(ប្រាំបី)ឆ្នាំ ។ ហើយក្នុងករណីកុមារត្រូវការថែទាំពិសេស (កុមារពិការស្មារតី ឬរាងកាយធ្ងន់ធ្ងរឬមានជម្ងឺរ៉ាំរ៉ៃអាចអនុញ្ញាតបានដល់ក្រោម១៨ (ដប់ប្រាំបី)ឆ្នាំ។
  - ករណីកុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម៨(ប្រាំបី)ឆ្នាំ អាចអនុញ្ញាតឲ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនដែលមានអាយុក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។
  - ករណីស្មុំកូនដោយសាច់ញាតិដែលជាពូ មីង តា យាយ ឬចាស់ព្រឹទ្ធាចារ្យរបស់កុមារ ស្មុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។
- កុមារត្រូវតែរស់នៅកន្លែងដែលមានការគ្រប់គ្រងថែរក្សាដូចខាងក្រោមនេះ៖
  - កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា (ទាំងមណ្ឌលកុមារកំព្រារបស់រដ្ឋ និងមណ្ឌលកុមារកំព្រាអង្គការមិនមែនរដ្ឋាភិបាល)។
  - រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត(ឧទាហរណ៍ការថែទាំដោយគ្រួសារធម៌)ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។
  - ក្នុងករណីស្មុំកូនដោយសាច់ញាតិដែលជាពូ មីង តា យាយ ឬចាស់ព្រឹទ្ធាចារ្យរបស់កុមារដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា។
- កុមារត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់អាណាព្យាបាលផ្សេងទៀតដូចខាងក្រោម៖
  - កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត។
  - កុមារទាំងនោះស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជន។

[49] ទំព័រ ៥៤ និង ៥៥នៃច្បាប់ស្ដីពីស្មុំកូនអន្តរប្រទេស ក្នុងកម្រងច្បាប់ គោលនយោបាយ និងមុខងារពាក់ព័ន្ធនឹងការការពារកុមារ

- កុមារត្រូវបានប្រកាសថាទទួល ឬអាចអនុញ្ញាតឲ្យសុំកូនអន្តរប្រទេសបាន ដោយអាជ្ញាធរកណ្តាលឬក្រសួងទទួលបន្ទុកសង្គមកិច្ច ។

**លក្ខខណ្ឌសុំកូនក្នុងករណីកុមារត្រូវបានគេបោះបង់ចោល**

- ក្នុងករណីមានកុមារត្រូវបានរកឃើញ និងបញ្ជូនទៅមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអាណាព្យាបាលសម្រាប់កុមារនោះ ប្រធានមណ្ឌល កុមារកំព្រាត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្តអំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌលយ៉ាងយូរបំផុតរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការគិតពីពេលដែលកុមារមកដល់មណ្ឌល។
- មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូល ឈ្មោះកុមារទៅក្នុងបញ្ជីស្តីពីកុមារដែលត្រូវបានរាយការណ៍ថា ត្រូវបានគេបោះបង់ចោល។
- មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬ សាច់ញាតិ និង អាណាព្យាបាលសម្រាប់កុមារមុននៅទូទាំងព្រះរាជាណាចក្រកម្ពុជាដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពដូចជា ទូរទស្សន៍ វិទ្យុ ឬសារព័ត៌មាន និងរូបភាពរបស់កុមារនោះ។
- បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល៥(ប្រាំ)ថ្ងៃ នៅតែរកមិនឃើញឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់កុមារមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីខិតខំស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបានគេបោះបង់ចោល។
- ចាប់ពីពេលដែលកុមារត្រូវបានរកឃើញរហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់កុមារបណ្តោះអាសន្ន។ អ្នកអាណាព្យាបាលសម្រាប់កុមារបណ្តោះអាសន្នគ្មានសិទ្ធិផ្តល់ការយល់ព្រមលើសុំកូនទេ។

**លក្ខខណ្ឌសុំកូន ក្នុងករណីកុមារត្រូវបានលះបង់ពីការគ្រប់គ្រងនៃអំណាចមេបា**

- ប្រសិនបើអ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុង ស្ថានភាពលំបាកបំផុតបានធ្វើការទុកដាក់កុមារឲ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឲ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

**លក្ខខណ្ឌបន្ទាប់បន្សំនៃកូនសុំ**

- ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវខិតខំឲ្យអស់ពីលទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត។
- ក្នុងករណីមិនអាចធ្វើទៅបានក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវដាក់កុមារតាមរយៈសុំកូនក្នុងស្រុកក្នុងព្រះរាជាណាចក្រកម្ពុជាមុននឹង ពិនិត្យរកលក្ខណៈសម្បត្តិសុំកូនអន្តរប្រទេសរបស់កុមារ។
- នៅពេលវិធានការនានាត្រូវបានបញ្ចប់ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចនឹងត្រូវបានបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជីស្ដីពីកុមារដែលកំណត់ថាមានលក្ខណៈសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស។

**លក្ខខណ្ឌព្រមព្រៀងនៃកូនសុំ**

សុំកូនអន្តរប្រទេសប្រព្រឹត្តទៅបានលុះត្រាតែសុំកូនអនុវត្តទៅបានតាមនីតិវិធីដូចខាងក្រោមៈ

- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និងម្ដាយការយល់ព្រមត្រូវផ្ដល់ដោយឪពុក និងម្ដាយរបស់កុមារនោះ ឬក្នុងករណីដែលឪពុក ឬម្ដាយណាមួយរបស់កុមារបានស្លាប់ ឬស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបានឬត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្ដល់ដោយឪពុកឬម្ដាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់។
- ក្នុងករណីដែលឪពុកម្ដាយរបស់កុមារបានស្លាប់ ឬស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្ដល់ដោយអ្នកអាណាព្យាបាលសម្រាប់កុមាររបស់កុមារនោះ។
- ឪពុកម្ដាយ ឬឪពុកឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្ដល់ការយល់ព្រម (ឧទាហរណ៍ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវប្រាប់យ៉ាងច្បាស់លាស់ដល់អ្នកដែលត្រូវផ្ដល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាពព្រមទាំងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់កុមារ) និងត្រូវប្រាប់អំពីបែបបទ និងរយៈពេលបញ្ឈប់ការយល់ព្រម។
- ការយល់ព្រមខាងលើត្រូវផ្ដល់ឲ្យដោយសេរី និងច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយ ដូចជាការបង្ខិតបង្ខំ ការឆបោក ឬការបញ្ចុះបញ្ចូលផ្សេងៗទៀត។

- ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរនៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងទីលំនៅរស់ឪពុក ម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។
- ដំណើរការស្មុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែផុតកំណត់ពេល ៩០(កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការក្រោយការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់កុមាររបស់កុមារ។
- ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់កុមាររបស់កុមារអាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបានរហូតដល់មុនពេលសេចក្តី សម្រេចរបស់តុលាការស្តីពីស្មុំកូនអន្តរប្រទេស។[50]

**តួនាទីរបស់អាជ្ញាធរកណ្តាលនៅក្នុងការស្មុំកូន**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស ដែលមានតួនាទីដូចតទៅ៖

- រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ជា និងនីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការស្មុំកូនអន្តរប្រទេស។
- ធ្វើកិច្ចសហប្រតិបត្តិការ និង ធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នាទាក់ទងនឹងកិច្ចការស្មុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេសនៃប្រទេសទទួល។
- ចាត់វិធានការសមស្របដើម្បីបង្ការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងស្មុំកូនអន្តរប្រទេស។
- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការស្មុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។
- ពិនិត្យលើសំណើរបស់រដ្ឋបាល ស្មុំកូនអន្តរប្រទេសទាក់ទងនឹងករណីស្មុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់។
- ធ្វើអធិការកិច្ចលើកិច្ចការពារពាក់ព័ន្ធស្មុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

[50] ទំព័រ ៥៨ ដល់ ៦០នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសក្នុងកម្រងច្បាប់ គោលនយោបាយ និងមុខងារពាក់ព័ន្ធនឹងការការពារកុមារ

- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចយល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស។

ទន្ទឹមនឹងនេះ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានរដ្ឋបាលសុំកូនអន្តរប្រទេសជាសេនាធិការ។ មន្ត្រីបម្រើការក្នុងរដ្ឋបាលសុំកូនអន្តរប្រទេសរួមមានអ្នកធ្វើការងារផ្នែកសង្គមកិច្ច អ្នកចិត្តសាស្ត្រ និងអ្នកជំនាញខាងច្បាប់បានទទួលការបណ្តុះបណ្តាលពិសេសស្តីពីសុំកូន និងសិទ្ធិកុមារ។ រដ្ឋបាលសុំកូនមានតួនាទីនិងភារកិច្ចដូចតទៅៈ

- រៀបចំ ថែរក្សាបញ្ជីសម្ងាត់ និង សំណុំឯកសាររបស់កុមារដែលមានលក្ខណៈសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស។
- វាយតម្លៃស្ថានភាពកុមារទាំងអស់ដែលមានឈ្មោះ ក្នុងបញ្ជីសម្ងាត់ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹម ថែទាំសមស្របបំផុតសម្រាប់កុមារ និង ធានាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ។
- ប្រឹងប្រែងរកដំណោះស្រាយឲ្យអស់លទ្ធភាពក្នុងប្រទេស ក្នុងការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារឬនៅជាមួយអ្នកអាណាព្យាបាលមុន នឹងដំណើរការសុំកូនអន្តរប្រទេស។
- ពិនិត្យចាត់ការពាក្យសុំកូនអន្តរប្រទេសនិងឯកសារពាក់ព័ន្ធផ្សេងទៀតរបស់អ្នកសុំ។
- ផ្គូរផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណៈសម្បត្តិ សមស្របសម្រាប់សុំកូនអន្តរប្រទេស និង ផ្តល់មតិយោបល់លើករណីសុំកូនអន្តរប្រទេសជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។
- ផ្តល់ដំណឹងទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលឮបានទទួលការអនុញ្ញាតពីប្រទេសទទួលអំពីនីតិវិធីសុំកូន និងការវិវត្តន៍នៃករណីសុំកូន។
- សម្របសម្រួលការប្រគល់កុមារទៅឲ្យអ្នកសុំ និងរៀបចំឯកសារដើម្បីឲ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ។ផ្តល់ ឬ សម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារ អ្នកសុំ និងគ្រួសារបង្កើតតាមការចាំបាច់។
- ផ្តល់មតិយោបល់ទាក់ទងនឹងការផ្តល់ការអនុញ្ញាតឲ្យ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ឬការដកហូតការអនុញ្ញាតជូនអាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស។[51]

[51] ទំព័រ ៥៦ និង ៥៧នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសក្នុងកម្រងច្បាប់ គោលនយោបាយ និងមុខងារពាក់ព័ន្ធនឹងការការពារកុមារ

## ២.២ លិខិតបទដ្ឋាននានា

ទន្ទឹមនឹងមានច្បាប់ជាតិមួយចំនួនបានប្បញ្ញត្តិពី ការការពារនិងគាំពារកុមារពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសក៏ដោយ ក្នុងនោះយើងក៏ឃើញមានលិខិតបទដ្ឋាននានាមួយចំនួនទៀតបានប្បញ្ញត្តិឡើងដើម្បីនឹងការពារកុមារពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាស។ លិខិតបទដ្ឋានទាំងនោះមានដូចជា៖

**ព្រះរាជក្រឹត្យលេខ ១២០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

ព្រះរាជក្រឹត្យមួយនេះគឺចង់សំដៅទៅដល់ការបង្កើត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដោយក្នុងគោលបំណងនៃការបង្កើតគឺ ដើម្បីលើកស្ទួយកុមារដើម្បីកុំឲ្យងាយរងគ្រោះតទៅទៀតតាមរយៈកិច្ចប្រតិបត្តិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ហៅកាត់ថា (ក. ជ. ក ) គឺជាយន្តការផ្លូវការរបស់រាជរដ្ឋាភិបាលទទួលបន្ទុកសម្របសម្រួល និងធ្វើរបាយការណ៍ស្តីពីសកម្មភាពទាក់ទងនឹង ការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារសុខុមាលភាព និងការចូលរួមរបស់កុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមាននាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស និងដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាប្រធាន ជាមួយនឹងអនុប្រធានប្រាំមួយរូបទៀតពីក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាលនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។លើសពីនេះក្រុមប្រឹក្សាជាតិដើម្បីកុមារមានតួនាទី និង ភារកិច្ចដូចតទៅ៖

- ពិគ្រោះយោបល់ សម្របសម្រួលបញ្ហាទាំងឡាយណាទាក់ទងនឹងកុមារ
- ពិនិត្យ តាមដាន វាយតម្លៃ ការអនុវត្តអនុសញ្ញាសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនៅកម្ពុជា
- ផ្សព្វផ្សាយច្បាប់ អនុសញ្ញាសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហាកុមារ
- រៀបចំគោលនយោបាយ ផែនការ កម្មវិធី និងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍កុមារ
- ទំនាក់ទំនងជាមួយសហគមន៍ជាតិ និងអន្តរជាតិដើម្បីរកជំនួយឧបត្ថម្ភ និង ផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ដែលទាក់ទងនឹងគោលដៅរួម ក្នុងការកែលម្អស្ថានភាពកុមារ
- ស្រាវជ្រាវ និងផ្តល់ព័ត៌មានស្តីពីសេចក្តីត្រូវការ និងបញ្ហាពាក់ព័ន្ធនឹងកុមារកម្ពុជា
- រៀបចំគោលនយោបាយស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងកុមារ

**អនុក្រឹត្យលេខ១៦២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាប អំពើជួញដូរមនុស្ស**

ការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទលើកុមារ គឺដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលជាប្រធាន ដោយមានអនុប្រធានចំនួន៤នាក់ពីក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទលើកុមារមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយដែលមាននាយកដ្ឋានប្រឆាំងការជួញដូរ និងការការពារកុមារនៃក្រសួងមហាផ្ទៃ ក្រុមការងារបច្ចេកទេសទាំង៦ និងគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទថ្នាក់រាជធានី ខេត្ត ជាសេនាធិការក្នុងការអនុវត្តភារកិច្ចសម្រេចផែនការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទលើកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងប្រទេសកម្ពុជា។ គណកម្មាធិការជាតិដឹកនាំការបង្ក្រាបការអំពើជួញដូរមនុស្ស និង ការធ្វើអាជីវកម្មមានភារកិច្ចជាសេនាធិការរាជរដ្ឋាភិបាលដូចខាងក្រោម៖

- ដឹកនាំសម្របសម្រួលជាមួយក្រសួងស្ថាប័នជាដៃគូ និងប្រទេសពាក់ព័ន្ធនានាដើម្បីការពារប្រជាពលរដ្ឋជាពិសេសកុមារពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ
- ការត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រប្រឆាំង នឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- ពិនិត្យ ដោះស្រាយសំណូមពរនិងអនុសាសន៍នានា ផ្តល់មតិណែនាំ និងដឹកនាំឲ្យលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសទាំងអស់អនុវត្ត និងចាត់វិធានការតាមមុខសញ្ញារៀងៗខ្លួន
- ផ្តល់ការណែនាំដល់គណៈកម្មាធិការ ដឹកនាំការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- ការពារគុណភាពនៃការផ្តល់សេវាសម្រាប់ការស្តារ ធ្វើសមាហរណកម្ម និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ពិសេសគឺកុមារ
- លុបបំបាត់និទណ្ឌភាពដោយលើកទឹកចិត្តឲ្យមានការស៊ើបអង្កេត និងការផ្តន្ទាទោស
- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋជាពិសេសជនរងគ្រោះ ដើម្បីបង្កើនទំនុកចិត្តរបស់ពួកគេលើសេវាសាធារណៈ និងការចូលរួមរបស់ពួកគេលើការអនុវត្តច្បាប់
- សម្របសម្រួលក្រុមការងារពាក់ព័ន្ធនិងជំរុញការអនុវត្តផែនការ នៅក្នុងសាមីក្រសួងដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ

- ដាក់របាយការណ៍ជាទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល ស្តីពីស្ថានភាពនៃគម្រោងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ

**អនុក្រឹត្យលេខ៤០ ស្តីពីការបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការការពារអនីតិជននៃក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការការពារអនីតិជន ត្រូវបានបង្កើតឡើងនៅក្រោមនាយកដ្ឋានកណ្តាលមន្ត្រីនគរបាលយុត្តិធម៌នៃអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ ក្នុងគោលបំណងដើម្បីផ្តល់សេវាបច្ចេកទេសដើម្បីបង្ការ ទប់ស្កាត់ និងបង្រ្កាបសកម្មភាពជួញដូរមនុស្សអាជីវកម្មផ្លូវភេទលើកុមារតាមនីតិវិធីច្បាប់។ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការការពារអនីតិជនមានភារកិច្ចដូចខាងក្រោម៖

- លើកឡើងនូវគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក់ព័ន្ធទៅនឹងការជួញដូរ និងអំពើអាជីវកម្មផ្លូវភេទលើកុមារ និងកាមសាស្ត្រលើកុមារ
- ចាប់ខ្លួនចារី សហចារី និងដកហូតយកសម្ភារៈវត្ថុតាងពាក់ព័ន្ធកសាងសំណុំរឿងបញ្ជូនទៅតុលាការ
- អនុវត្តសាលក្រម សាលដីការបស់តុលាការពាក់ព័ន្ធនឹងករណីការធ្វើអាជីវកម្មផ្លូវភេទ
- សហការជាមួយនឹងភ្នាក់ងារមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិទាក់ទងអាជីវកម្មផ្លូវភេទទាំងក្នុងប្រទេស និងសកម្មភាពឆ្លងដែន
- សម្របសម្រួលជាមួយនឹងព្រះរាជអាជ្ញាតុលាការដើម្បីការអនុវត្តច្បាប់និងកិច្ចប្រតិបត្តិការរបស់នាយកដ្ឋាន
- គ្រប់គ្រង និងផ្លាស់ប្តូរព័ត៌មានពីមុខសញ្ញាក្នុងប្រទេស និងមុខសញ្ញាឧក្រិដ្ឋអន្តរជាតិពាក់ព័ន្ធនឹងការងារនិងសកម្មភាពប្រតិបត្តិការរបស់នាយកដ្ឋាន
- រៀបចំរបាយការណ៍ជាទៀងទាត់តាមការកំណត់ និងជាបន្ទាន់ទាក់ទងនឹងការអនុវត្តភារកិច្ចរបស់ខ្លួនសម្រាប់អគ្គស្នងការនគរបាលជាតិ

**អនុក្រឹត្យលេខ៦៣ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យសិល្បៈ ភាពយន្ត និងវីដេអូ**

អនុក្រឹត្យមានគោលបំណងគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត វីដេអូ លើកកម្ពស់ផលិតផលភាពយន្តក្នុងស្រុកក្នុងគោលបំណងអភិរក្ស ការពារវប្បធម៌ជាតិ និងធានាបាននូវការគោរពសីលធម៌សង្គម។ យោងតាមរយៈអនុក្រឹត្យនេះ ការផលិត ការថត ការថតចម្លង ឬការកែប្រែសម្រួលក្នុងគោលដៅអាជីវកម្ម ក៏ជាការជួល ការលក់នាំចេញ នាំចូល ការបញ្ចាំងជាសាធារណៈ ឬ

ការផ្សាយនៃផលិតផលភាពយន្តនិងវីដេអូក្នុងទម្រង់ជាខ្សែភាពយន្តខ្សែវីដេអូឌីស ឡាស៊ែរ វីដេអូស៊ីឌី ឌីវីឌី រួមទាំងការបង្កើតខារ៉ាអូខេត្រូវមានការផ្តល់អាជ្ញាបណ្ណនិងការត្រួតពិនិត្យដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**អនុក្រឹត្យលេខ ៥៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺជាយន្តការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំ និងគ្រប់គ្រងវិស័យអតីតយុទ្ធជន វិស័យសង្គមកិច្ច និងវិស័យយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមរយៈអនុក្រឹត្យនេះក្រសួងមានតួនាទីនិងភារកិច្ចដូចជា៖

**វិស័យសង្គមកិច្ច**

- សហការជាមួយស្ថាប័នពាក់ព័ន្ធចាត់វិធានការផ្លូវច្បាប់ ក្នុងការទប់ស្កាត់អំពើពេស្យាចារ ការរំលោភផ្លូវភេទលើកុមារ
- សហការជាមួយស្ថាប័ន និងអង្គការពាក់ព័ន្ធនឹងការអនុវត្តន៍សិទ្ធិកុមារ

**វិស័យយុវនីតិសម្បទា**

- គ្រប់គ្រងកុមារអាយុ ៧ទៅក្រោមអាយុ ១៨ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើស និងការស្តារនីតិសម្បទា និងការអប់រំពួកគេទៅជាពលរដ្ឋល្អ
- បង្កើតមជ្ឈមណ្ឌលអប់រំសម្រាប់កុមារ ដែលបានប្រព្រឹត្តបទល្មើស និងការអនុញ្ញាតឲ្យកុមារទាំងនេះទទួលបាននូវការអប់រំ និងការបណ្តុះបណ្តាល
- សហការជាមួយក្រសួងពាក់ព័ន្ធ ស្ថាប័នជាតិ និងអង្គការអន្តរជាតិនៅក្នុងការរៀបចំនូវកម្មវិធីអប់រំ និងបណ្តុះបណ្តាលសម្រាប់អនីតិជន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់អ្នកទោស

អនុលោមតាមអនុក្រឹត្យនេះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាយើងឃើញមានអគ្គនាយកដ្ឋានបច្ចេកទេសដែលអនុវត្តប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយ សម្របសម្រួល និងការគ្រប់គ្រងជំនាញបច្ចេកទេសសុខុមាលភាពកុមារ។ តាមរយៈកិច្ចប្រតិបត្តការរបស់អគ្គនាយកដ្ឋានបច្ចេកទេស យើងឃើញមាននាយកដ្ឋានទាក់ទងសុខុមាលភាពកុមារដែលមានតួនាទី ដូចជា៖

- រៀបចំច្បាប់គោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធដល់សុខុមាលភាពកុមារ

- អនុវត្តគោលនយោបាយរាជរដ្ឋាភិបាល អនុសញ្ញាអន្តរជាតិ សន្ធិសញ្ញា ពាក់ព័ន្ធនឹងសិទ្ធិកុមារដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា និង បានចូលជាសមាជិក
- រៀបចំផែនការសកម្មភាព និង កម្មវិធីដើម្បីផ្តល់នូវសេវាសម្រាប់កុមារដែលចង់បានតម្រូវការការពារពិសេសនៅក្នុងសហគមន៍ និងគ្រួសារ
- រៀបចំ និងគ្រប់គ្រងមូលនិធិជួយឧបត្ថម្ភសុខុមាលភាពកុមារ
- ជម្រុញការអនុវត្តច្បាប់ស្តីពីសុំកូនអន្តរប្រទេស

**អនុក្រឹត្យលេខ ០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងកុមាររយៈពេល ខ្លី មធ្យម និង វែង
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមផ្សេងទៀតដែលពាក់ព័ន្ធនឹងកុមារ និងកម្មវិធីជាតិសម្រាប់កុមារ
- ពិនិត្យ តាមដានស្ថានភាពកុមារ និងផ្តល់អនុសាសន៍ ដោយផ្អែកលើគោលនយោបាយជាតិស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារនានាពាក់ព័ន្ធនឹងកុមារ និងកម្មវិធីជាតិដាក់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ផ្សព្វផ្សាយខ្លឹមសារអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្នាក់ក្រោមជាតិ
- សិក្សាស្រាវជ្រាវច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកុមារ ក្នុងគោលបំណងដើម្បីតាមដាន វាយតម្លៃ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ធ្វើកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាដើម្បីលើកអនុសាសន៍ជូនក្រុមប្រឹក្សាជាតិដើម្បីកុមារពិនិត្យសម្រេច និងធ្វើជូនរាជរដ្ឋាភិបាល
- ចងក្រងព័ត៌មាន និងឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

**ប្រកាសលេខ ៣៥៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ក្រុង**

ប្រកាសនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីខេត្តដែលមានភារកិច្ចដូចតទៅ៖

**រដ្ឋបាល**

- ផ្សព្វផ្សាយគោលការណ៍ណែនាំ និងគោលនយោបាយរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទៅកាន់ផ្នែកដែលពាក់ព័ន្ធ និងអង្គភាពមូលដ្ឋានទាំងអស់នៅក្រោមសាលារាជ
- ធានី ខេត្ត ក៏ដូចជាអង្គការជាតិ អង្គការអន្តរជាតិ និងក្រុមសហគមន៍។
- ផ្តល់ការបណ្តុះបណ្តាល ចំណេះដឹង និងជំនាញដល់មន្ត្រីរាជការស៊ីវិល ដើម្បីបំពេញមុខងាររបស់ពួកគេ
- តាមដាន គ្រប់គ្រង និងប៉ាន់ប្រមាណពីកម្មវិធីរាជធានី ខេត្ត និងសកម្មភាពអង្គការជាតិ អង្គការអន្តរជាតិដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**សង្គមកិច្ច**

- ដឹកនាំ និងគ្រប់គ្រងរាល់សេវាសង្គមកិច្ច ដើម្បីជួយប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះតួយ៉ាងដូចជាកុមារដែលជាពេស្យាជនជាដើម
- ចាត់វិធានការផ្លូវច្បាប់ បង្ការការប្រព្រឹត្តពេស្យាចារកុមារ
- ដោះដូរព័ត៌មាន និងផ្តល់សេវាសង្គមដោយសហការជាមួយអង្គការជាតិ និងអង្គការអន្តរជាតិដែលធ្វើលើវិស័យសង្គមកិច្ចក្នុងរាជធានី ខេត្ត
- កសាងភាពជាដៃគូ និងបង្កើនការចូលរួមក្នុងចំណោមអង្គការមនុស្សធម៌ និងសហគមន៍មូលដ្ឋានដើម្បីបង្កើតមូលនិធិសង្គមកិច្ច ជួយដល់ជនងាយរងគ្រោះ ពិសេសគឺកុមារ

**យុវនីតិសម្បទា**

- ណែនាំកុមារដែលមានអាយុចាប់ពី៧ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសកុមារទំនាស់នឹងច្បាប់ ដើម្បីអប់រំពួកគេឲ្យក្លាយជាពលរដ្ឋល្អ
- គ្រប់គ្រងមជ្ឈមណ្ឌលស្តារនីតិសម្បទា ដោយទទួលយក ណែនាំ អប់រំ និងបណ្តុះបណ្តាលកុមារជាជនល្មើស
- បង្កើតកម្មវិធីអប់រំ បណ្តុះបណ្តាលសម្រាប់អនីតិជន ដោយសហការជាមួយអង្គការអន្តរជាតិ និងអង្គការជាតិដែលពាក់ព័ន្ធ
- រៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ទណ្ឌិត ដោយសហការជាមួយអង្គការពាក់ព័ន្ធ

# សេចក្តីសន្និដ្ឋាន

ប៉ុន្មានឆ្នាំកន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជាទទួលបានលទ្ធផលគួរជាទីមោទនៈក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច រួមទាំងការអភិវឌ្ឍវិស័យសុខុមាលភាពកុមារ ការការពារកុមារជាទូទៅនិងដោយឡែកគឺមានការទប់ស្កាត់ការធ្វើពេស្យាកម្មកុមារ និង រូបភាពឬសម្ភារៈអាសអាភាសទៅលើកុមារ។ បច្ចុប្បន្ននេះមានការផ្លាស់ប្តូរការយល់ដឹង គួរឲ្យកត់សម្គាល់ក្នុងមជ្ឈមណ្ឌលសាធារណៈទាក់ទង នឹងការទប់ស្កាត់ការធ្វើពេស្យាកម្មនិងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ ហើយរាជរដ្ឋាភិបាលបាននឹង កំពុងយកចិត្តទុកដាក់លើការទប់ស្កាត់តាមរយៈវិធានការតឹងរ៉ឹងនានា និងការអនុវត្តច្បាប់។ ថ្នាក់ដឹកនាំនៅគ្រប់លំដាប់ថ្នាក់ និងស្ថាប័ននានាកាន់តែមានការយកចិត្តទុកដាក់និងចូលរួមចំណែកយ៉ាងសកម្មក្នុងការការពារកុមារ និងត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅក្នុងសង្គមជារួម និងដោយឡែកមានជាយុទ្ធនាការស្តីពីការការពារកុមារ។ ការទប់ស្កាត់ការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសទទួលបានការចូលរួមពីសង្គមយ៉ាងទូលំទូលាយ ចាប់តាំងពីស្ថាប័ននីតិប្បញ្ញត្តិរហូតដល់ប្រព័ន្ធយុត្តិធម៌និងស្ថាប័នពាក់ព័ន្ធក្នុងការការពារកុមារ ពីការធ្វើពេស្យាកម្ម និង រូបភាពឬសម្ភារៈអាសអាភាស ឲ្យកាន់តែមានប្រសិទ្ធិភាពឡើង។

ទន្ទឹមនឹងលទ្ធផលខាងលើព្រះរាជាណាចក្រកម្ពុជា ក៏នៅជួបបញ្ហាមួយចំនួនទៀតដែលពាក់ព័ន្ធនឹងការកំណើននៃការធ្វើពេស្យាកម្មនិងរូបភាពឬសម្ភារៈអាសអាភាសទៅលើកុមារ។ ដោយហេតុនេះព្រះរាជាណាចក្រកម្ពុជាត្រូវបន្តពុះពារថែមទៀតក្នុង ការការពារនិងអភិវឌ្ឍវិស័យសុខុមាលភាពរបស់កុមារដោយក្នុងនោះត្រូវផ្តោតសំខាន់ទៅលើ ការលើកស្ទួយកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នអនុវត្តច្បាប់ យុត្តិធម៌ និងសង្គមកិច្ច លើកកម្ពស់ការយល់ដឹងអំពីច្បាប់ ការអនុវត្តច្បាប់ ការទប់ស្កាត់បទល្មើស និងបញ្ហាសង្គម។ បង្កើតឲ្យមានកម្មវិធីរួមគ្នាដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហាទាក់ទងការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសលើកុមារ ។ ចំពោះបទល្មើសដែលកើតឡើងពីការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសនេះមិនសូវជាមានការអន្តរាគមន៍បានល្អនូវឡើយទេ ហេតុនេះករណីមានការរកឃើញបទល្មើសត្រូវតែពន្លឿនការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសជនល្មើសដែលជួញដូរកុមារទៅតាមផ្លូវច្បាប់។ ក្នុងនេះផងដែរគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ពិសេសការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ត្រូវតែបន្តពង្រឹងតួនាទី ភារកិច្ច នឹងការដឹកនាំរបស់ខ្លួនឲ្យបានល្អ។ លើសពីនេះត្រូវបន្តកិច្ចសហប្រតិបត្តិការល្អនិងមានភាពជិតស្និតជាមួយនឹងដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអន្តរជាតិក្នុងការទប់ស្កាត់និងកាត់បន្ថយកំណើននៃការធ្វើពេស្យាកម្មនិងរូបភាពឬសម្ភារៈអាសអាភាសលើកុមារនៅកម្ពុជា។

# អនុសាសន៍

ឆ្លងកាត់តាមរយៈកិច្ចការស្រាវជ្រាវនេះ យើងខ្ញុំបានមើលឃើញពីកិច្ចខិតខំប្រឹងប្រែងយ៉ាងរបស់រាជរដ្ឋាភិបាល ដូចជាការប្រឹងប្រែងរៀបចំប្រព័ន្ធប្រមូលទិន្នន័យជាដើម ទោះបីជាមានខិតខំប្រឹងប្រែងយ៉ាងនេះក្តីយើងមើលឃើញថាប្រព័ន្ធប្រមូលទិន្នន័យរបស់រដ្ឋនៅមានភាពខ្វះចន្លោះ ដូចជាទិន្នន័យមិនទាន់ជាទិន្នន័យរួមមួយព្រោះស្ថាប័នរដ្ឋមានទិន្នន័យមិនទាន់ស្របគ្នានៅឡើយ ម្យ៉ាងវិញទៀត ទិន្នន័យមិនទាន់មានគុណភាពល្អទាំងស្រុងនោះទេ ដោយសារពេលខ្លះសង្គមស៊ីវិលនឹងរដ្ឋាភិបាលមិនទាន់មានការយល់ស្របចំពោះទិន្នន័យរបស់រាជរដ្ឋាភិបាល។ ជាអានុសាសន៍រដ្ឋាភិបាលគួរតែមានប្រព័ន្ធប្រមូលទិន្នន័យរួមមួយ ពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន ដែលធានាបាននូវគុណភាព។

រាជរដ្ឋាភិបាលបានរៀបចំតាក់តែងច្បាប់ជាតិជាច្រើន ដោយមានការអនុម័តពីសភាជាតិដើម្បីធានាបាននូវការគោរពសិទ្ធិកុមារជាពិសេស ក៏បានបង្កើតឲ្យមានជាអនុក្រឹត្យបង្កើតគណៈកម្មាធិការមួយចំនួនទៀតដើម្បីដោះស្រាយបញ្ហាទាំងនោះប៉ុន្តែជាក់ស្តែងការអនុវត្តច្បាប់ នឹងការអនុវត្តការងាររបស់គណៈកម្មាធិការទាំងនោះនៅមានកម្រិតតិចតួចនៅឡើយ។ ជាក់ស្តែងដូចជាគណៈកម្មាធិការសុំកូនអន្តរប្រទេសនៅមិនទាន់មានដំណើរការសកម្មនៅឡើយ ម្យ៉ាងវិញទៀតដូចជាអនុក្រឹត្យដោះស្រាយបញ្ហាកុមារអនាថាគ្មានទីពឹង តែជាក់ស្តែងយើងនៅតែឃើញមានកុមារដែលរស់នៅតាមទីសាធារណៈដូចជាតាមស្តុបនៅផ្លូវសំខាន់ៗមួយចំនួននៅឡើយ។ ជាអនុសាសន៍រដ្ឋាភិបាលគួរតែពង្រឹងការអនុវត្តច្បាប់ ឲ្យមានប្រសិទ្ធភាពខ្ពស់ជាងនេះជាជាងការបង្កើតច្បាប់ថ្មីកាន់តែច្រើនហើយគ្មានប្រិសិទ្ធិភាពពាក់ព័ន្ធនឹងការអនុវត្តទៅវិញ។

ថ្លែងក្នុងក្នុងខួបអនុស្សាវរីយ៍លើកទី៦៤នៃការបង្កើតគណបក្សប្រជាជន សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានថ្លែងឲ្យដឹងថាកម្រិតជីវភាព របស់ប្រជាជនកម្ពុជាមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ជាក់ស្តែងក្នុងឆ្នាំ២០១៤ កម្រិតចំណូលប្រចាំឆ្នាំរបស់ប្រជាជនកម្ពុជាក្នុងមួយនាក់មានចំនួន១១២៣ដុល្លារក្នុងមួយនាក់នឹងក្នុង ឆ្នាំ២០១៥ មានចំនួន១២២០ដុល្លារ នេះពិតជាភាពជោគជ័យមួយដ៏ប្រសើរសម្រាប់ប្រទេសកម្ពុជាដែលជាមោទនភាពសម្រាប់ប្រជាជនកម្ពុជា។ ប៉ុន្តែទន្ទឹមនឹងនេះយើងឃើញថា ប្រជាជនកម្ពុជាភាគច្រើននៅតែមិនទាន់មានការងារចំណែកកសិករដែលធ្វើស្រែចំការមិនមានទីផ្សារ ហើយតម្លៃស្រូវអង្ករមានការធ្លាក់ចុះជាដើម ដែលនេះជាហេតុនាំអោយមានការធ្វើការចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសដើម្បីជីវភាពគ្រួសារ ដែលនេះក៏ជាមូលហេតុចំបងដែលនាំអោយកើតនូវបញ្ហាជាច្រើនដូចជាការប្រឈមមុខនឹងការកេងប្រវ័ញ្ចផ្លូវភេទ ការជិះជាន់កម្លាំងពលកម្មដែលជាការព្រួយបារម្ភខ្លាំងបំផុត

ចំពោះកុមារ ដែលធ្វើចំណាកស្រុកទៅតាមក្រុមគ្រួសាររបស់ពួកគេ។ ជាពិសេសក៏បង្កើនវិជ្ជាជីវៈដល់ប្រជាជនក្រីក្រនិងលើកកម្ពស់ដល់អាជីវកម្មខ្នាតតូចនិងអាជីវកម្មលក្ខណៈគ្រួសារ។ ដើម្បីឆ្លើយតបនឹង បញ្ហាខាងលើនេះរដ្ឋាភិបាលគួរតែបង្កើនមុខរបរដល់ប្រជាជនរបស់ខ្លួនឲ្យបានកាន់តែច្រើន។

បច្ចុប្បន្ននេះសង្គមមានការរីកចម្រើនយ៉ាងខ្លាំងជាពិសេសគឺប្រព័ន្ធអ៊ីនធឺណែត ដែលនេះជាមូលហេតុនាំអោយមានបញ្ហាពាក់ព័ន្ធនឹងបញ្ហាពេស្យាកម្មនិងរូបភាពអាសអាភាសផងដែរ ហើយរាជរដ្ឋាភិបាលគួរតែមានការគិតគូរពិចារណារៀបចំអោយមានការត្រួតពិនិត្យ ប៉ុន្តែមិនមែនការត្រួតពិនិត្យក្នុងគោលដៅលុបបំបាត់សិទ្ធិសេរីភាពបញ្ចេញមតិយោបល់របស់ពលរដ្ឋនោះទេ។ ម្យ៉ាងវិញទៀតការផ្សព្វផ្សាយពាណិជ្ជកម្មតាមរយៈទូរទស្សន៍ដែលមានលក្ខណៈស្រើបស្រាល រួមទាំងខ្សែភាពយន្តមួយចំនួនដែលមានលក្ខណៈស្រើបស្រាល ដែលនេះជាដើមហេតុនាំអោយកើតមានបញ្ហាពេស្យាចារនិងរូបភាពអាសអាភាសលើកុមារផងដែរ។ ដូច្នេះក្រសួងវប្បធម៌និងវិចិត្រសិល្បៈរួមទាំងក្រសួងព័ត៌មានគួរតែមានការរឹតបន្តឹងការត្រួតពិនិត្យបន្ថែមទៀតចំពោះបញ្ហាខាងលើនេះ។

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព និង បណ្តាញសុវត្ថិភាពគ្រួសារដែលនេះជាមោទនភាពមួយ ដែលរាជរដ្ឋាភិបាលបានបង្កើនការយកចិត្តទុកដាក់ចំពោះប្រជាជនជាពិសេសលើការការពារសុវត្ថិភាពប្រជាជន។ ប៉ុន្តែទន្ទឹមនឹងនេះយើងនូវតែឃើញមានបញ្ហាអំពើហិង្សាកើតមានមិនថាជាបញ្ហារំលោភបំពានផ្លូវភេទនិង អំពើហិង្សាលើរាងកាយផងដែរ។ ប្រជាជនភាគច្រើនជាពិសេសអ្នកដែលរស់នៅតាមទីជនបទ នៅតែមិនទាន់បានយល់ដឹងពីគោលនយោបាយនេះជាពិសេសមិនដឹងពីរបៀបរាយការណ៍ពេលមានបញ្ហាកើតឡើង ដែលនេះជាការបង្ហាញពីភាពមិនទាន់បានជោគជ័យទាំងស្រុងចំពោះគោលនយោបាយ និង បណ្តាញសុវត្ថិភាពគ្រួសារនៅឡើយ។ ជាអនុសាសន៍រដ្ឋាភិបាលគួរតែអប់រំដល់ប្រជាជនអោយបានយល់ដឹងជាពិសេសចំពោះប្រជាជនដែលរស់នៅទីដាច់ស្រយាល និង ពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធិភាព។

ស្ថាប័ននីតិប្បញ្ញត្តិគួរតែធ្វើការសិក្សាស្វែងយល់ និងពិចារណាទៅលើលិខិតបទដ្ឋានអន្តរជាតិនានាឲ្យបានស៊ីជម្រៅ។ ហើយអ្វីដែលពិសេសនោះគួរតែយកលិខិតអន្តរជាតិទាំងនោះ មកបញ្ចូលជាគ្រឹះក្នុងច្បាប់ជាតិរបស់ខ្លួន ដើម្បីជាការអនុវត្តនិងពង្រឹងទៅលើភាពខ្វះចន្លោះរបស់ខ្លួន។ តួយ៉ាងដូចជាការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសទៅលើកុមារច្បាប់ជាតិរបស់យើងពុំទាន់បានកំណត់យ៉ាងស៊ីជម្រៅនូវឡើយទេចំពោះនិយមន័យ សកម្មភាពដែលទាក់ទងនឹងការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ ដែលមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបការជួញដូរ

មនុស្ស និងអំពើអាជីវកម្មផ្លូវភេទរបស់ព្រះរាជាណាចក្រកម្ពុជាយើង។ ដោយឡែកនៅក្នុងពិធីសារបន្ថែមស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារបានកំណត់ច្បាស់លាស់ពាក់ព័ន្ធនឹងនិយមន័យ និងសកម្មភាពពាក់ព័ន្ធនឹងការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសទៅលើកុមារ។ មួយវិញទៀតចំពោះបញ្ហាពាក់ព័ន្ធនឹងការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារយើងពុំទាន់មានឃើញច្បាប់ជាតិរបស់ព្រះរាជាណាចក្រកម្ពុជាយើងបានកំណត់ច្បាស់លាស់ពីការការពារនូវឡើយទេ គឺគ្រាន់តែយើងជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម។ ហេតុនេះជាអនុសាសន៍ព្រះរាជាណាចក្រកម្ពុជាគួរតែសិក្សាស្វែងយល់ពីលិខិតបទដ្ឋានអន្តរជាតិ ហើយយកមកបញ្ចៀបជាមូលដ្ឋានគ្រឹះក្នុងច្បាប់ជាតិរបស់ខ្លួន។

នៅក្នុងគោលនយោបាយដឹកនាំរដ្ឋ រាជរដ្ឋាភិបាលគួរតែកុំផ្តោតសំខាន់លើការការពារកុមារ និងការការពារយុត្តិធម៌កុមារ ឃើញថារាជរដ្ឋាភិបាលកម្ពុជាពុំទាន់បានយកចិត្តទុកដាក់បានល្អនូវឡើយទេ។ ដោយហេតុនេះរាជរដ្ឋាភិបាលកម្ពុជាគួរតែយកចិត្តទុកដាក់លើបញ្ហាកុមារជាពិសេស ។ ស្របតាមយុត្តិសាស្ត្រចតុកោណគឺមានចតុស្កម្កមួយ ដែលធ្វើការអភិវឌ្ឍទៅលើធនធានមនុស្ស។ ដោយឡែកយើងមើលថាកម្ពុជានៅមានកម្រិតនៅឡើយ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលធនធានមនុស្ស ដោយសារវាមានមូលហេតុជាច្រើនដែលនាំឲ្យកម្ពុជាប្រឈមនឹងបញ្ហាមួយនេះ។ ហេតុនេះធនធានមនុស្សអាចបណ្តុះបណ្តាលបានគឺចាប់ផ្តើមពីកុមារទៅ ព្រោះថាកុមារជាក្រដាសសមួយដែលគ្មាននរណាម្នាក់គូសវាស ហេតុនេះកុមារគួរតែអប់រំឲ្យបានត្រឹមត្រូវ លើសពីនេះកុមារត្រូវតែយកចិត្តទុកដាក់ខ្ពស់ពីរដ្ឋដើម្បីការពារពីការធ្វើពេស្យាកម្ម និងរូបភាពឬសម្ភារៈអាសអាភាសលើកុមារ។

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារឆ្នាំ១៩៨៩
- ពិធីសារបន្ថែមនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារពាក់ព័ន្ធ ការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ ចូលជាធរមានថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០២
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩
- ព្រះរាជក្រឹត្យលេខ១២០១ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០០៩
- អនុក្រឹត្យលេខ១៦២ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបការជួញដូរមនុស្ស ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨
- អនុក្រឹត្យលេខ៤០ស្តីពីការបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០២
- អនុក្រឹត្យលេខ៦៣ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យសិល្បៈ ភាពយន្ត វីដេអូ ខែ កញ្ញា ឆ្នាំ ២០០០
- អនុក្រឹត្យលេខ៥៤ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ថ្ងៃទី ២៤ ខែមិនា ឆ្នាំ ២០១១
- អនុក្រឹត្យលេខ០២ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ កម្ពុជាដើម្បីកុមារ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១០
- ប្រកាសលេខ៣៥៩ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តក្រុង ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០៥
- របាយការណ៍ជាតិលើកទី១និងលើកទី២ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិ កុមារស្តីពីការជួញដូរមនុស្ស ការធ្វើពេស្យាកម្ម និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២ ដល់២០១០
- របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាឆ្លើយតបសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារនៃ អង្គការសហប្រជាជាតិពាក់ព័ន្ធរបាយការណ៍លើកទី២និងលើកទី៣របសស់កម្ពុជាស្តីពីការ អនុវត្តសិទ្ធកុមារ ខែ ឧសភា ឆ្នាំ២០១១
- ការដាក់របាយការណ៍ឆ្លើយតបរបាយការណ៍ត្រួតពិនិត្យជាសកលតាមកាលកំណត់ដោយ សម្ពន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារឆ្នាំ២០០៩ដល់ឆ្នាំ២០១៣

- របាយការណ៍របស់ក្រុមការងារអំពីការត្រួតពិនិត្យជាសកល តាមកាលកំណត់ ចុះថ្ងៃ២៧ ខែមិនា ឆ្នាំ២០១៤
- របាយការណ៍អង្កេតនិងសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារពាក់ព័ន្ធបញ្ហាសិទ្ធិកុមារ ថ្ងៃ២៨ មិថុនា ឆ្នាំ២០០០
- កម្រងច្បាប់គោលនយោបាយ និងមុខងារពាក់ព័ន្ធនឹងការការពារកុមាររៀបរៀងដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រោមការឧបត្ថម្ភដោយអង្គការ យូនីសែហ្វ
- គេហទំព័ររបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ: http://www.ohchr.org/EN/HRBodies/CRC/Pages/CRCIndex.aspx ថ្ងៃទី ០៦ខែ មេសា ឆ្នាំ ២០១៥ (ចូលមើល )
- គេហទំព័ររបស់សម្ពន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ:http://www.ngocrc.org/ ថ្ងៃទី ២០ខែ មេសា ឆ្នាំ ១០១៥ (ចូលមើល)
- គេហទំព័ររបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា: http://www.mosvy.gov.kh/ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ (ចូលមើល)